01647453

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គបុរេជំនុំជម្រះ
Pre-Trial Chamber
Chambre Preliminaire

ឯកសារ **D362/6**

*គាំទនាមប្រជារាស្ត្រខ្មែរ និងគាំទនាមអង្គការសហប្រជាជាតិ និងអនុលោមតាមច្បាប់ស្តីពី ការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្ម ដែលបានប្រព្រឹត្តឡើងក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ*

**សំណុំរឿងព្រហ្មទណ្ឌលេខ: ០០៤/២/០៧-០៩-២០០៩-អវតក/កសចស (អបជ៥៨)**

ចំពោះមុខ: **ចៅក្រម ប្រាក់ គីមសាន ប្រធាន**
**ចៅក្រម** Olivier BEAUVALLET
**ចៅក្រម ន័យ ថុល**
**ចៅក្រម** Kang Jin BAIK
**ចៅក្រម ហួត វុទ្ធី**

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 30 / 06 / 2020
ម៉ោង (Time/Heure): 16:00
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA

កាលបរិច្ឆេទ: **ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២០**

---

**សាធារណៈ**

**សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចអំពីភាពអាចទទួលយកបាននៃអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី**

---

**<u>សហព្រះរាជអាជ្ញា</u>**
ជា លាង
Brenda HOLLIS

**<u>សហមេធាវីការពារក្តី អោ អាន</u>**
មុំ លុជ្យ
Richard ROGERS
Göran SLUITER

**<u>មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី</u>**
ជេត វណ្ណលី
ហុង គីមសួន
គីម ម៉េងឃី
ឡោ ជុនធី
សំ សុគង់
Laure DESFORGES
Isabelle DURAND
Emmanuel JACOMY
Martine JACQUIN
Daniel MCLAUGHLIN
Lyma NGUYEN
Nushin SARKARATI

ស៊ិន សុវ៉ន

ទី ស្រ៊ីនណា

វ៉ែន ពៅ

# មាតិកា


I. ប្រវត្តិនីតិវិធី ..... 1

II. បទដ្ឋាននៃការត្រួតពិនិត្យឡើងវិញ ..... 13

III. ភាពអាចទទួលយកបាន ..... 14

IV. គោលការណ៍គតិយុត្តិនៃភាពអាចទទួលយកបានជាដើមបណ្តឹងរដ្ឋប្បវេណី ..... 15

V. អង្គសេចក្តី ..... 18

VI. សេចក្តីសម្រេច ..... 19

VII. យោបល់របស់ចៅក្រមប្រាក់ គីមសាន ចៅក្រមន៉យ ថុល និងចៅក្រម ហួត វុទ្ធី ..... 20

VIII. យោបល់របស់ចៅក្រមBAIK និងចៅក្រម BEAUVALLET ..... 22

ក. មូលដ្ឋានទី ១÷ សហចៅក្រមស៊ើបអង្កេតអន្តរជាតិមានកំហុសលើអង្គច្បាប់ និងអង្គហេតុ ដោយគ្រាន់តែកំណត់អត្តសញ្ញាណឧក្រិដ្ឋកម្មទាំងឡាយដែលត្រូវបានប្រព្រឹត្តនៅក្នុងភូមិភាគកណ្តាលថាជាប់ពាក់ព័ន្ធទៅនឹងលក្ខខណ្ឌតម្រូវពីទំនាក់ទំនង អនុលោមតាមវិធាន ២៣ស្ទួន(១)(ខ) នៃវិធានផ្ទៃក្នុង ..... 22

១. សារណា ..... 22

*២. ការពិភាក្សា* ..... 27

*ក. ច្បាប់ជាធរមាន* ..... 28

*ខ. មូលដ្ឋានទី ១(ក)* ..... 29

*គ. មូលដ្ឋានទី១(ខ)* ..... 35

ខ. មូលដ្ឋានទី ២÷ ការបំបែកសំណុំរឿង ០០៤/២ ចេញពីសំណុំរឿង ០០៤ មិនគួរជាកត្តាកំណត់លើភាពអាចទទួលបាននៃដើមបណ្តឹងរដ្ឋប្បវេណីនោះទេ ..... 39

*១. សារណា* ..... 39

*២ . ការពិភាក្សា* ..... 42

**គ. មូលដ្ឋានទី៣. ការមិនបានចេញសេចក្តីសម្រេច ដោយមានសំអាងហេតុ សម្រាប់ការច្រានចោលពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី** ........ 46

*១. សារណា* ........ 46

*២. ការពិភាក្សា* ........ 48

**ឃ. មូលដ្ឋានទី៤÷ ការចោទប្រកាន់ពីការមិនបានផ្តល់ព័ត៌មានគ្រប់គ្រាន់** ........ 54

*១. សារណា* ........ 54

*២. ការពិភាក្សា* ........ 56

**ង. មូលដ្ឋានទី ៥÷ ការចោទប្រកាន់ពីការរំលោភលើសិទ្ធិរបស់ជនរងគ្រោះក្នុងការទទួលបាន ព័ត៌មាន** ........ 59

*១. សារណា* ........ 59

*២. ការពិភាក្សា* ........ 61

**សេចក្តីសន្និដ្ឋាន** ........ 68

01647457

## តារាងអក្សរកាត់

| ពាក្យ | ពាក្យបំព្រួញ/អក្សរកាត់ |
|---|---|
| កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាទាក់ទងនឹងការកាត់សេចក្ដីនៅក្រោមច្បាប់កម្ពុជានូវឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ | កិច្ចព្រមព្រៀង អ.វ.ត.ក |
| ច្បាប់ស្តីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា | ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក |
| អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា | អ.វ.ត.ក |
| តុលាការព្រហ្មទណ្ឌអន្តរជាតិ | តុលាការ ICC |
| បក្សកុម្មុយនីស្តកម្ពុជា | ប.ក.ក |

**អង្គបុរេជំនុំជម្រះ** នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ("អ.វ.ត.ក") បានទទួល "បណ្តឹងឧទ្ធរណ៍ជំទាស់ដីកាសម្រេច លើភាពអាចទទួលស្គាល់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី" ដែលបានដាក់នៅថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១៨ ("បណ្តឹងឧទ្ធរណ៍")[1]។

## I. ប្រវត្តិនីតិវិធី

1. នៅថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០៨ សហព្រះរាជអាជ្ញាអន្តរជាតិបានដាក់ករណីខ្វែងយោបល់គ្នាជូនអង្គបុរេជំនុំជម្រះអនុលោមតាមវិធាន ៧១(២) នៃវិធានផ្ទៃក្នុង ដោយរាយការណ៍ថា សហព្រះរាជអាជ្ញាជាតិមិនយល់ស្រប នឹងការចោទប្រកាន់បទឧក្រិដ្ឋថ្មីៗ ដែលបានរៀបរាប់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម[2]។ នៅថ្ងៃទី១៨ ខែសីហា ឆ្នាំ២០០៩ អង្គបុរេជំនុំជម្រះបានចេញសេចក្តីពិចារណាលើករណីខ្វែងយោបល់នេះ[3]។

2. នៅថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០០៩ សហព្រះរាជអាជ្ញាអន្តរជាតិស្តីទីបានដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទី៣ ដោយស្នើសុំឱ្យសហចៅក្រមស៊ើបអង្កេតបើកកិច្ចស៊ើបសួរប្រឆាំង អោ អាន ជាផ្នែកនៃសំណុំរឿង ០០៤ ទាក់ទិននឹងការចោទប្រកាន់មួយចំនួនពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ អំពើប្រល័យពូជសាសន៍ និងការរំលោភបំពានលើក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៥៦ ("ក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦")[4]។ បន្ទាប់មកសហព្រះរាជអាជ្ញាអន្តរជាតិបាន

---

[1] សំណុំរឿង ០០៤/២/០៧-០៩-២០០៩-អវតក/កសចស ("សំណុំរឿង ០០៤/២") បណ្តឹងឧទ្ធរណ៍ជំទាស់ដីកាសម្រេចលើភាពអាចទទួលស្គាល់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១៨ បានជូនដំណឹងជាភាសាខ្មែរនៅថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០១៨ ឯកសារ D362/5 ("បណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (D362/5)")។

[2] ករណីខ្វែងយោបល់គ្នា ០០១/១៨-១១-២០០៨-អវតក/អបជ ឯកសារអំណះអំណាងជាលាយលក្ខណ៍អក្សររបស់សហព្រះរាជអាជ្ញាអន្តរជាតិ អំពីហេតុការណ៍ និងសំអាងហេតុនៃករណីខ្វែងយោបល់គ្នា ស្របតាមវិធាន ៧១(២) ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០៨ ឯកសារលេខ ១។

[3] ករណីខ្វែងយោបល់គ្នា ០០១/១៨-១១-២០០៨-អវតក/អបជ សេចក្តីពិចារណារបស់អង្គបុរេជំនុំជម្រះ ពាក់ព័ន្ធនឹងករណីខ្វែងយោបល់គ្នារវាងសហព្រះរាជអាជ្ញា អនុលោមតាមវិធាន ៧១ នៃវិធានផ្ទៃក្នុង ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០០៩ ឯកសារD1/1.3។

[4] សំណុំរឿង ០០៤/២០-១១-២០០៨-អវតក/កសចស ("សំណុំរឿង ០០៤") ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទី៣របស់សហព្រះរាជអាជ្ញា ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០៨ ឯកសារD1 ("ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទី៣ (D1)")។

ដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមចំនួន ៦ ដើម្បីពង្រីកវិសាលភាពកិច្ចស៊ើបសួរក្នុងសំណុំរឿង ០០៤ អនុលោមតាមវិធាន ៥៥(៣) នៃវិធានផ្ទៃក្នុង[5]។

3. ចាប់តាំងពីពេលចាប់ផ្ដើមការស៊ើបអង្កេត មានមនុស្សចំនួន ១៩២០ នាក់បានដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី[6]។

4. នៅក្នុងអំឡុងពេលស៊ើបអង្កេតសំណុំរឿង ០០៤/២ ការិយាល័យសហចៅក្រមស៊ើបអង្កេតបានទទួលព័ត៌មានថា អ្នកដាក់ពាក្យសុំចំនួន ៤២ នាក់នៅក្នុងសំណុំរឿង ០០៤/២ បានទទួលមរណភាព[7]។ សិទ្ធិវ័ន្តរបស់អ្នកដាក់ពាក្យសុំម្នាក់ដែលទទួលមរណភាព បានបង្ហាញឆន្ទៈចង់ក្លាយជាអ្នកបន្តបណ្ដឹងជំនួសអ្នកស្លាប់[8]។ អ្នកដាក់ពាក្យសុំចំនួនបីនាក់ បានដកពាក្យវិញ[9]។

5. នៅថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១១ សហចៅក្រមស៊ើបអង្កេតបានប្រកាសថាពាក្យសុំតាំងខ្លួនជាដើម

---

[5] សំណុំរឿង ០០៤ ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញាទាក់ទងទៅនឹងទីតាំងឧក្រិដ្ឋកម្មនានានៅក្នុងតំបន់១ និងការធ្វើទុក្ខបុកម្នេញចំពោះខ្មែរក្រោម ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១១ ឯកសារ D27។ សំណុំរឿង ០០៤ ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញាទាក់ទងទៅនឹងទីតាំងឧក្រិដ្ឋកម្មនានានៅក្នុងតំបន់១ និងការធ្វើទុក្ខបុកម្នេញចំពោះខ្មែរក្រោម ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១១ ឯកសារ D65។ សំណុំរឿង ០០៤ ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញាទាក់ទងនឹងអាពាហ៍ពិពាហ៍ដោយបង្ខំ ឬអំពើហិង្សាយេនឌ័រ ចុះថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១៤ ឯកសារ D191។ សំណុំរឿង ០០៤ ចម្លើយតបទៅនឹងដីកាបញ្ជូនរឿងទៅពិនិត្យឯកសារ D237 ចុះថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០១៥ ឯកសារ D237/1។ សំណុំរឿង ០០៤ ចម្លើយតបទៅនឹងដីកាបញ្ជូនរឿងទៅពិនិត្យ និង ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមពាក់ព័ន្ធនឹងវត្តអង្គតាមាក់ ចុះថ្ងៃទី០៤ ខែសីហា ឆ្នាំ២០១៥ ឯកសារ D254/1។ សំណុំរឿង ០០៤ ចម្លើយតបទៅនឹងដីកាបញ្ជូនរឿងទៅពិនិត្យចុះថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០១៥ និង ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមពាក់ព័ន្ធនឹងស៊ើបសួរទៅក្នុងអាពាហ៍ពិពាហ៍ដោយបង្ខំនៅក្នុងតំបន់១ និងតំបន់៤ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០១៥ ឯកសារ D272/1។ *សូមមើលផងដែរ* សំណុំរឿង ០០៤ សេចក្ដីសម្រេចស្ដីអំពីដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមទាក់ទងនឹងទីតាំងឧក្រិដ្ឋកម្មនានានៅក្នុងតំបន់១ និង ការធ្វើទុក្ខបុកម្នេញចំពោះខ្មែរក្រោម ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១១ ឯកសារ D27/3។

[6] *សូមមើល* សំណុំរឿង ០០៤/២ ដីកាសម្រេចលើភាពអាចទទួលស្គាល់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់សហចៅក្រមស៊ើបអង្កេត ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៨ ឯកសារ D362 ("ដីកាសម្រេចលើដើមបណ្ដឹងរដ្ឋប្បវេណី (អន្តរជាតិ) (D362)") កថាខណ្ឌ ២។

[7] *សូមមើល* ដីកាសម្រេចលើដើមបណ្ដឹងរដ្ឋប្បវេណី (អន្តរជាតិ) (D362) កថាខណ្ឌ ៨។

[8] *សូមមើល* ដីកាសម្រេចលើដើមបណ្ដឹងរដ្ឋប្បវេណី (អន្តរជាតិ) (D362) កថាខណ្ឌ ៨។

[9] *សូមមើល* ដីកាសម្រេចលើដើមបណ្ដឹងរដ្ឋប្បវេណី (អន្តរជាតិ) (D362) កថាខណ្ឌ ៨។

បណ្ដឹងរដ្ឋប្បវេណីរបស់លោក Robert HAMILL និង សេង ចាន់ធារី មិនអាចទទួលយកបាន[10]។ អ្នកដាក់ពាក្យសុំទាំងពីរនាក់បានប្ដឹងឧទ្ធរណ៍ជំទាស់នឹងដីកាសម្រេចមិនទទួលយក[11]។ នៅថ្ងៃទី១៤ និងទី២៨ ខែកុម្ភៈ ឆ្នាំ២០១២ អង្គបុរេជំនុំជម្រះបានចេញសេចក្ដីពិចារណារបស់ខ្លួនពាក់ព័ន្ធនឹងបណ្ដឹងឧទ្ធរណ៍ពីអ្នកដាក់ពាក្យសុំទាំងពីរនាក់ ដោយប្រកាសថា អង្គជំនុំជម្រះមិនអាចទទួលបានសំឡេងគាំទ្រភាគច្រើនដែលចាំបាច់ ដើម្បីចេញសេចក្ដីលើបណ្ដឹងឧទ្ធរណ៍ទេ[12]។ នៅថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០១១ សេង ចាន់ធារី បានដកពាក្យសុំរបស់ខ្លួនដែលត្រូវបានទទួលស្គាល់ដោយក្រឡាបញ្ជីនៃការិយាល័យសហចៅក្រមស៊ើបអង្កេត តាមរយៈលិខិតចុះថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០១៤[13]។ នៅថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១១ លោក Robert HAMILL បានស្នើសុំឱ្យសហចៅក្រមស៊ើបអង្កេតពិចារណាសាជាថ្មីទៅលើដីកាសម្រេចរបស់ខ្លួន[14]។ សហចៅក្រមស៊ើបអង្កេតមិនបានចេញដីកាសម្រេចថ្មីទៅលើភាពអាចទទួលស្គាល់រូបគាត់ជាដើមបណ្ដឹងរដ្ឋប្បវេណី
នៅពេលនោះទេ។

---

[10] សំណុំរឿង ០០៤ ដីកាសម្រេចស្ដីពីការទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ សេង ចាន់ធារី ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១១ ឯកសារ D5/1/3។ សំណុំរឿង ០០៤ ដីកាសម្រេចស្ដីពីការទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់លោក រ៉ប ហាមីល (Rob HAMILL) ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១១ ឯកសារ D5/2/3។

[11] សំណុំរឿង ០០៤ បណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចស្ដីពីការទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ សេង ចាន់ធារី ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១១ ឯកសារ D5/1/4/1។ សំណុំរឿង ០០៣ បណ្ដឹងឧទ្ធរណ៍ប្រឆាំងដីកាសម្រេចស្ដីការទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់លោក រ៉ូប៊ឺត ហាមីល (Rob HAMILL) (D11/2/3) (សំណុំរឿង ០០៣ និង ០០៤) ចុះថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១១ ឯកសារ D5/2/4/2។

[12] សំណុំរឿង ០០៤ សេចក្ដីពិចារណារបស់អង្គបុរេជំនុំជម្រះ ទាក់ទិននឹងបណ្ដឹងឧទ្ធរណ៍ប្រឆាំងដីកាសម្រេចស្ដីការទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់លោក Robert HAMILL ចុះថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០១២ ឯកសារ D5/2/4/3។ សំណុំរឿង ០០៤ សេចក្ដីពិចារណារបស់អង្គបុរេជំនុំជម្រះ ទាក់ទិននឹងបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចស្ដីពីការទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ សេង ចាន់ធារី ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១២ ឯកសារ D5/1/4/2។

[13] អ៊ីមែលពីលោក សំ សុគង់ និង លោក Emmanuel JACOMY សហមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីនៅផ្នែកគាំពារជនរងគ្រោះ ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០១៤ ឯកសារ D5/1/5។ *សូមមើលផងដែរ* ដីកាសម្រេចលើដើមបណ្ដឹងរដ្ឋប្បវេណី (អន្តរជាតិ) (D362) កថាខណ្ឌ ៥។

[14] សំណុំរឿង ០០៤ សំណើសុំឱ្យសហចៅក្រមស៊ើបអង្កេតពិចារណាសាជាថ្មី ចំពោះការទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់លោក Robert HAMILL (D11/2/3) សំណុំរឿង ០០៣ និង ០០៤) ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១១ ឯកសារ D5/2/5។

01647461



6. នៅថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១១ សហចៅក្រមស៊ើបអង្កេតបានចេញសេចក្ដីប្រកាសព័ត៌មានមួយ ដោយជូនដំណឹងដល់សាធារណជន និងអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី អំពីទីតាំងឧក្រិដ្ឋកម្មនានា ដែលត្រូវបានបញ្ចូលទៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទី៣ នៅក្នុងសំណុំរឿង ០០៤[15]។

7. នៅថ្ងៃទី០១ ខែឧសភា ឆ្នាំ២០១២ សហចៅក្រមស៊ើបអង្កេតបម្រុងអន្តរជាតិបានទទួលយកអ្នកដាក់ពាក្យសុំចំនួន ៣០ នាក់ជាដើមបណ្ដឹងរដ្ឋប្បវេណី[16]។

8. នៅថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១២ ក្រោយពីបានទទួលដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមទាក់ទិននឹងការស៊ើបអង្កេតបន្ថែមក្នុងសំណុំរឿង ០០៤ សហចៅក្រមស៊ើបអង្កេតបានចេញសេចក្ដីប្រកាសមួយ ដោយជូនដំណឹងដល់សាធារណជនពីទីតាំងឧក្រិដ្ឋកម្មចំនួន ១៤ ថែមទៀតដែលស្ថិតក្រោមការស៊ើបអង្កេតក្នុងសំណុំរឿង ០០៤[17]។

9. សំណុំរឿងរបស់ អោ អាន ស្ថិតក្នុងករណីខ្វែងយោបល់ជាសម្ងាត់មួយចំនួនរវាងសហចៅក្រមស៊ើបអង្កេត (ដែលបានចុះបញ្ជីនៅថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១៣, ថ្ងៃទី០៥ ខែមេសា ឆ្នាំ២០១៣, ថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៧ និង ថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១៨)[18]។ ពុំមានករណីខ្វែង

---

15 សេចក្ដីប្រកាសព័ត៌មានរបស់ អ.វ.ត.ក "សេចក្ដីប្រកាសព័ត៌មានរបស់សហចៅក្រមស៊ើបអង្កេតទាក់ទិននឹងដើមបណ្ដឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿង ០០៤ (០០៤/០៧-០៩-២០០៩/អ.វ.ត.ក/ក.ស.ច.ស)" ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១១ អាចរកបាននៅលើគេហទំព័រ៖ https://www.eccc.gov.kh/en/document/public-affair/press-release-co-investigating-judges-regarding-civil-parties-case-004។

16 *សូមមើល* ដីកាសម្រេចលើដើមបណ្ដឹងរដ្ឋប្បវេណី (អន្តរជាតិ) (D362) កថាខណ្ឌ ៧ និង ជើងទំព័រ ៧។

17 សេចក្ដីប្រកាសព័ត៌មានរបស់ អ.វ.ត.ក "សេចក្ដីប្រកាសរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិទាក់ទងនឹងទីតាំងឧក្រិដ្ឋកម្មបន្ថែមនៅក្នុងសំណុំរឿង ០០៤" ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១២ អាចរកបាននៅលើគេហទំព័រ៖ https://www.eccc.gov.kh/en/document/public-affair/statement-international-co-investigating-judge-regarding-additional-crime-sit។

18 *សូមមើល* សំណុំរឿង ០០៤/២ ដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៨ ឯកសារ D360 ("ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (D360)") កថាខណ្ឌ ១។ សំណុំរឿង ០០៤/២ ដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតជាតិ (ដីកាសម្រេចលើកលែងចោទប្រកាន់) ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៨ ឯកសារ D359 ("ដីកាដំណោះស្រាយ (ដីកាសម្រេចលើកលែងចោទប្រកាន់) (D359)") កថាខណ្ឌ ២២, ៤៩។

យោបល់ណាមួយក្នុងចំណោមករណីខ្វែងយោបល់ទាំងនេះត្រូវបានបញ្ជូនមកអង្គបុរេជំនុំជម្រះទេ។

10. នៅថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១៤ ស្របពេលនឹងការដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមដែលបានចុះកាលបរិច្ឆេទដូចគ្នា[19] សហព្រះរាជអាជ្ញាអន្តរជាតិបានប្រកាសថា គាត់បានស្នើសុំឱ្យធ្វើការស៊ើបអង្កេតទៅលើអំពើហិង្សាផ្លូវភេទ ឬអំពើហិង្សាយេនឌ័រ និងអាពាហ៍ពិពាហ៍ដោយបង្ខំជាផ្នែកនៃសំណុំរឿង ០០៤[20]។

11. នៅថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១៥ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានចោទប្រកាន់ អោ អាន ពីអំពើឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងការរំលោភបំពានលើមាត្រា ៥០១ និង ៥០៦ នៃក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ (អំពើមនុស្សឃាតគិតទុកជាមុន)[21]។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានចេញសេចក្តីប្រកាសព័ត៌មានមួយនៅថ្ងៃដដែលនោះ[22]។

12. នៅថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១៦ សហចៅក្រមស៊ើបអង្កេតអន្តរជាតិសម្រេចចោទប្រកាន់ អោ អាន ពីឧក្រិដ្ឋកម្មថែមទៀត រួមមាន អំពើប្រល័យពូជសាសន៍ និង ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិថែមទៀត[23]។ នៅថ្ងៃដដែលនោះ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានចេញសេចក្តីថ្លែងការណ៍ មួយជាសាធារណៈ ដោយប្រកាសពីបទចោទថ្មីៗទាំងនេះ[24]។

---

[19] សំណុំរឿង ០០៤ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញា ទាក់ទងនឹងអាពាហ៍ពិពាហ៍ដោយបង្ខំ ឬអំពើហិង្សាយេនឌ័រ ចុះថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១៤ ឯកសារ D191។

[20] សេចក្តីប្រកាសព័ត៌មានរបស់ អ.វ.ត.ក "សេចក្តីថ្លែងការណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ Nicholas Koumjian ស្តីពីសំណុំរឿង ០០៤" ចុះថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១៤ អាចរកបាននៅលើគេហទំព័រ៖ https://www.eccc.gov.kh/en/node/30196។

[21] សំណុំរឿង ០០៤ កំណត់ហេតុនៃការបង្ហាញខ្លួនលើកដំបូងរបស់ អោ អាន ចុះថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១៥ ឯកសារ D242។

[22] សេចក្តីប្រកាសព័ត៌មានរបស់ អ.វ.ត.ក "សេចក្តីថ្លែងការណ៍របស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិទាក់ទងនឹងសំណុំរឿង ០០៤" ចុះថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១៥ អាចរកបាននៅលើគេហទំព័រ៖ https://www.eccc.gov.kh/en/node/32148។

[23] សំណុំរឿង ០០៤ កំណត់ហេតុនៃការបង្ហាញខ្លួនម្តងទៀតរបស់ អោ អាន ចុះថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១៦ ឯកសារ D303។

[24] សេចក្តីប្រកាសព័ត៌មានរបស់ អ.វ.ត.ក "សេចក្តីថ្លែងការណ៍របស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិទាក់ទងនឹងសំណុំរឿង ០០៤" ចុះថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១៦ អាចរកបាននៅលើគេហទំព័រ៖ https://www.eccc.gov.kh/en/document/public-affair/additional-charges-announced-against-ao។

01647463



13. នៅថ្ងៃទី១៩ ខែមេសា ឆ្នាំ២០១៦ តាមរយៈសំណើសុំសេចក្ដីអធិប្បាយរបស់ខ្លួនទាក់ទងអង្គហេតុដែលត្រូវបានចោទប្រកាន់ ដែលនឹងពុំត្រូវបានស៊ើបសួរបន្ថែម សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានជូនដំណឹងដល់ភាគីថា គាត់បានដកអង្គហេតុមួយចំនួនចេញពីការស៊ើបអង្កេត និងបានស្នើសុំមតិយោបល់ពីភាគីស្ដីពីបញ្ហានេះ[25]។ នៅថ្ងៃទី០៩ ខែវិច្ឆិកា ឆ្នាំ២០១៦ ក្រោយពេលបានទទួលយោបល់ពី អោ អាន និងសហព្រះរាជអាជ្ញាអន្តរជាតិរួច សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានជូនដំណឹងជាផ្លូវការដល់ភាគី អំពីចេតនារបស់គាត់ក្នុងការដកបទចោទមួយចំនួនចេញពីអង្គហេតុដែលបានចោទប្រកាន់[26]។

14. នៅថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១៦ និងថ្ងៃទី៣១ ខែមករា ឆ្នាំ២០១៧ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានបង្គាប់ឲ្យមានតំណាងតាមផ្លូវច្បាប់ សម្រាប់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីទាំងអស់[27]។

15. នៅថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៦ សហចៅក្រមស៊ើបអង្កេតបានជូនដំណឹងដល់ភាគីពីការបញ្ចប់ការស៊ើបអង្កេតប្រឆាំង អោ អាន[28]។ នៅថ្ងៃដដែលនោះ សហចៅក្រមស៊ើបអង្កេតក៏បានចេញដីកាមួយដែរ ដោយបង្គាប់ឲ្យបំបែកការស៊ើបអង្កេតប្រឆាំង អោ អាន ចេញពីសំណុំរឿង ០០៤ ហើយ

---

[25] សំណុំរឿង ០០៤ សំណើសុំសេចក្ដីអធិប្បាយទាក់ទងអង្គហេតុដែលត្រូវបានចោទ ដែលនឹងពុំត្រូវបានស៊ើបសួរបន្ថែម ចុះថ្ងៃទី១៩ ខែមេសា ឆ្នាំ២០១៦ ឯកសារ D307 ("សំណុំរឿង ០០៤៖ សំណើសុំសេចក្ដីអធិប្បាយ (D307)")។

[26] សំណុំរឿង ០០៤ សេចក្ដីជូនដំណឹងយោងតាមវិធានផ្ទៃក្នុង ៦៦*ស្ទួន*(២) ចុះថ្ងៃទី០៩ ខែវិច្ឆិកា ឆ្នាំ២០១៦ ឯកសារ D307/4 ("សំណុំរឿង ០០៤៖ សេចក្ដីជូនដំណឹងតាមវិធាន ៦៦*ស្ទួន*(២) (D307/4)")។

[27] សំណុំរឿង ០០៤/២ ដីកាសម្រេចចាត់តាំងមេធាវីតំណាងអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១៦ ឯកសារ D330 (*សូមមើល* ឧទាហរណ៍ ឯកសារ D330 កថាខណ្ឌ ៣ នៅពេលសហចៅក្រមស៊ើបអង្កេតអន្តរជាតិចាត់តាំង "មេធាវីឲ្យតំណាងអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីដែលមិនទាន់មានមេធាវីតំណាង និងអ្នកដាក់ពាក្យសុំដែល[លិខិតប្រគល់សិទ្ធិតំណាងដោយអាណត្តិ]មិនមានសុពលភាព អស់សុពលភាព ខុសគ្នា ឬមិនពេញលេញ" និងបញ្ជាក់សុពលភាពម្ដងទៀតចពោះ "មេធាវីតំណាងអ្នកដាក់ពាក្យសុំដែល[លិខិតប្រគល់សិទ្ធិតំណាងដោយអាណត្តិ]មានសុពលភាព")។ សំណុំរឿង ០០៤/២ ដីកាសម្រេចទទួលស្គាល់មេធាវី និងការចាត់តាំងមេធាវីតំណាងអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០១៧ ឯកសារ D346។

[28] សំណុំរឿង ០០៤ សេចក្ដីជូនដំណឹងអំពីការបិទកិច្ចស៊ើបសួរប្រឆាំង អោ អាន ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៦ ឯកសារ D334 ("សេចក្ដីជូនដំណឹងតាមវិធាន ៦៦(១) លើកទីមួយ (D334)")។

បង្កើតជាសំណុំរឿងថ្មីមួយគឺសំណុំរឿង ០០៤/២[29]។ ក្រៅពីនោះ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានចេញដីកាសម្រេចរបស់ខ្លួន ដកអង្គហេតុដែលបានចោទប្រកាន់ចេញពីការស៊ើបអង្កេត អនុលោមតាមវិធាន ៦៦*ស្ទួន* នៃវិធានផ្ទៃក្នុង ដូចបានជូនដំណឹងពីមុន[30]។ ពុំមានភាគីណាមួយប្តឹងឧទ្ធរណ៍ជំទាស់ទៅនឹងដីកាសម្រេចនេះទេ។

16. នៅថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១៧ សហចៅក្រមស៊ើបអង្កេតបានចេញសេចក្តីជូនដំណឹងលើកទី ២ អំពីការបិទកិច្ចស៊ើបសួរប្រឆាំង អោ អាន[31]។

17. នៅថ្ងៃទី២៨ ខែមេសា ឆ្នាំ២០១៧ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានបដិសេធរាល់សំណើសុំវិធានការការពារទាំងអស់ដែលអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីបានស្នើសុំ នៅក្នុងសំណុំរឿង ០០៤/២[32]។

18. នៅថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១៧ សហចៅក្រមស៊ើបអង្កេតបានបញ្ជូនសំណុំរឿងទៅឱ្យសហព្រះរាជអាជ្ញាពិនិត្យ អនុលោមតាមវិធាន ៦៦(៤) នៃវិធានផ្ទៃក្នុង ដោយអញ្ជើញសហព្រះរាជអាជ្ញាឱ្យដាក់ដីកាសន្និដ្ឋានស្ថាពររបស់ខ្លួនក្នុងរយៈពេលបីខែ[33]។

19. នៅថ្ងៃទី១៨ ខែសីហា ឆ្នាំ២០១៧ សហព្រះរាជអាជ្ញាជាតិបានចេញដីកាសន្និដ្ឋានស្ថាពរ ដោយស្នើសុំឱ្យលើកលែងចោទប្រកាន់ទាំងអស់ប្រឆាំង អោ អាន[34] ម្យ៉ាងវិញទៀត នៅក្នុងដីកាសន្និដ្ឋាន

---

[29] សំណុំរឿង ០០៤ ដីកាសម្រេចបំបែកសំណុំរឿង អោ អាន ចេញពីសំណុំរឿង ០០៤ ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៦ ឯកសារ D334/1។

[30] សំណុំរឿង ០០៤/២ ដីកាសម្រេចកាត់បន្ថយវិសាលភាពនៃកិច្ចស៊ើបសួរយោងតាមវិធានផ្ទៃក្នុង ៦៦*ស្ទួន* ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៦ ឯកសារ D337 ("ដីកាសម្រេចកាត់បន្ថយវិសាលភាពនៃកិច្ចស៊ើបសួរ (D337)")។

[31] សំណុំរឿង ០០៤/២ សេចក្តីជូនដំណឹងលើកទី ២ អំពីការបិទកិច្ចស៊ើបសួរប្រឆាំង អោ អាន ចុះថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១៧ ឯកសារ D334/2 ("សេចក្តីជូនដំណឹងតាមវិធាន ៦៦(១) លើកទី ២ (D334/2)")។

[32] សំណុំរឿង ០០៤/២ ដីកាសម្រេចលើសំណើសុំវិធានការការពាររបស់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ចុះថ្ងៃទី២៨ ខែមេសា ឆ្នាំ២០១៧ ឯកសារ D348។

[33] សំណុំរឿង ០០៤/២ ដីកាបញ្ជូនសំណុំរឿងទៅពិនិត្យ អនុលោមតាមវិធាន ៦៦(៤) នៃវិធានផ្ទៃក្នុង ចុះថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១៧ ឯកសារ D351។

[34] សំណុំរឿង ០០៤/២ ដីកាសន្និដ្ឋានស្ថាពរទាក់ទងករណី អោ អាន អនុលោមតាមវិធាន ៦៦ នៃវិធានផ្ទៃក្នុង ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០១៧ ឯកសារ D351/4។

ស្តាពររបស់ខ្លួនចុះថ្ងៃទី២១ ខែសីហា ឆ្នាំ២០១៧ សហព្រះរាជអាជ្ញាអន្តរជាតិបានស្នើសុំចោទប្រកាន់ និងបញ្ជូន អោ អាន ទៅជំនុំជម្រះ (រួមគ្នាហៅថា "ដីកាសន្និដ្ឋានស្តាពរ")[35]។ នៅថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៧ សហមេធាវីការពារក្តី អោ អាន បានដាក់ចម្លើយតបមួយទៅនឹងដីកាសន្និដ្ឋានស្តាពររបស់សហព្រះរាជអាជ្ញា[36]។

20. នៅថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៨ សហចៅក្រមស៊ើបអង្កេតបានចេញដីកាដំណោះស្រាយដែលផ្ទុយគ្នា។ សហចៅក្រមស៊ើបអង្កេតជាតិបានចេញដីកាដំណោះស្រាយ (ដីកាសម្រេចលើកលែងចោទប្រកាន់) ដោយលើកលែងរាល់បទចោទទាំងអស់ប្រឆាំង អោ អាន ដោយផ្អែកលើមូលដ្ឋានថាគាត់មិនស្ថិតក្រោមយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក ក្នុងនាមជា "មេដឹកនាំជាន់ខ្ពស់" ឬក្នុងចំណោម "អ្នកទទួលខុសត្រូវខ្ពស់បំផុត" នោះទេ[37]។ ផ្ទុយទៅវិញ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានចេញដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ដោយបញ្ជូន អោ អាន ទៅជំនុំជម្រះចំពោះបទចោទនានាស្តីពី អំពើប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងការរំលោភបំពានលើក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ ហើយបានសន្និដ្ឋានថា អោ អាន ស្ថិតក្រោមយុត្តាធិការរបស់ អ.វ.ត.ក ក្នុងនាមជា "អ្នកទទួលខុសត្រូវខ្ពស់បំផុត" ចំពោះឧក្រិដ្ឋកម្មក្នុងសម័យខ្មែរក្រហម[38]។ ដីកាសម្រេចលើកលែងចោទប្រកាន់បានដាក់ជាភាសាខ្មែរតែមួយភាសា ហើយដីកាបញ្ជូនរឿងទៅជំនុំជម្រះបានដាក់ជាភាសាអង់គ្លេសតែមួយភាសា រីឯការបកប្រែបានដាក់តាមក្រោយ។

21. នៅថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៨ ដដែលនោះ សហចៅក្រមស៊ើបអង្កេតជាតិបានចេញដីការបស់ខ្លួនបដិសេធពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី *[sic]* ("ដីកាសម្រេចលើដើមបណ្តឹងរដ្ឋប្បវេណី (ជាតិ)") ដោយបដិសេធពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់នៅក្នុង

---

[35] សំណុំរឿង ០០៤/២ ដីកាសន្និដ្ឋានស្តាពររបស់សហព្រះរាជអាជ្ញាអន្តរជាតិអនុលោមតាមវិធាន ៦៦ នៃវិធានផ្ទៃក្នុង ចុះថ្ងៃទី២១ ខែសីហា ឆ្នាំ២០១៧ ឯកសារ D351/5។

[36] សំណុំរឿង ០០៤/២ ចម្លើយតបរបស់ អោ អាន ទៅនឹងដីកាសន្និដ្ឋានស្តាពររបស់សហព្រះរាជអាជ្ញាអនុលោមតាមវិធាន ៦៦ ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៧ ឯកសារ D351/6។

[37] ដីកាដំណោះស្រាយ (ដីកាសម្រេចលើកលែងចោទប្រកាន់) (D359)។

[38] ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (D360)។

សំណុំរឿង ០០៤/២ ដោយផ្អែកលើមូលដ្ឋានថា បទចោទទាំងអស់ប្រឆាំង អោ អាន ត្រូវបានលើកលែង ដោយសារពុំមានយុត្តាធិការ[39]។ ដីការបស់សហចៅក្រមស៊ើបអង្កេតជាតិមិនបានពិនិត្យជាក់លាក់ទៅលើភាពអាចទទួលយកបាន នៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនីមួយៗទេ។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានចេញដីកាសម្រេច លើភាពអាចទទួលស្គាល់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីដាច់ដោយឡែកមួយ ("ដីកាសម្រេចលើដើមបណ្តឹងរដ្ឋប្បវេណី (អន្តរជាតិ)") ដោយប្រកាសថា ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីដែលមាននៅក្នុងឧបសម្ព័ន្ធ ក នៃដីកា អាចទទួលយកបាន ខណៈដែលបដិសេធពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីដែលមាននៅក្នុងឧបសម្ព័ន្ធ ខ នៃដីកា មិនអាចទទួលយកបាន រួមទាំងពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់លោក Robert HAMILL[40]។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានពន្យល់ថា គាត់បានវាយតម្លៃសាជាថ្មី ហើយក្នុងករណីចាំបាច់ គាត់បានពិចារណាសាជាថ្មីទៅលើសេចក្តីសន្និដ្ឋានស្តីពីភាពអាចទទួលយកបានដែលបានធ្វើនៅថ្ងៃទី០១ ខែឧសភា ឆ្នាំ២០១២ ដោយសហចៅក្រមស៊ើបអង្កេតបម្រុងអន្តរជាតិ "យោងលើការវិវត្តនៃកិច្ចស៊ើបសួរ"[41]។

22. នៅថ្ងៃទី២០ ខែសីហា ឆ្នាំ២០១៨ សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីមួយក្រុមបានដាក់សំណើរួមគ្នាសុំការពន្យារពេល និងបន្ថែមចំនួនទំព័រ សម្រាប់បណ្តឹងឧទ្ធរណ៍របស់ខ្លួនអនុលោមតាមវិធាន ៧៧*ស្ទួន* នៃវិធានផ្ទៃក្នុង ប្រឆាំងនឹងការមិនទទួលយកជាដើមបណ្តឹងរដ្ឋប្បវេណី និងសុំការអនុញ្ញាតដាក់តែមួយភាសាសិន ចំណែកការបកប្រែនឹងដាក់តាមក្រោយ[42]។ នៅថ្ងៃទី២១ ខែសីហា ឆ្នាំ២០១៨ សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីមួយក្រុមទៀតបានដាក់សារណាមួយ ដោយចូលរួម និងផ្តល់ការគាំទ្របន្ថែមទៀតដល់សំណើសុំការពន្យារពេល និងបន្ថែមចំនួនពីរ

[39] សំណុំរឿង ០០៤/២ ដីកាសម្រេចបដិសេធពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី [*sic*] ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៨ ឯកសារ D361 ("ដីកាសម្រេចលើដើមបណ្តឹងរដ្ឋប្បវេណី (ជាតិ) (D361)")។

[40] ដីកាសម្រេចលើដើមបណ្តឹងរដ្ឋប្បវេណី (អន្តរជាតិ) (D362)។

[41] ដីកាសម្រេចលើដើមបណ្តឹងរដ្ឋប្បវេណី (អន្តរជាតិ) (D362) កថាខណ្ឌ ៧។

[42] សំណុំរឿង ០០៤/២ សំណើជាបន្ទាន់របស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ស្នើសុំពន្យារពេល និងបន្ថែមចំនួនទំព័រ ក្នុងការដាក់បណ្តឹងឧទ្ធរណ៍ជំទាស់ទៅនឹងសេចក្តីសម្រេចពីភាពអាចទទួលយកបាន នៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ក្នុងសំណុំរឿង ០០៤/២ ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១៨ ឯកសារ D362/1។ សំណើនេះបានដាក់ជាភាសាអង់គ្លេសនៅថ្ងៃទី២០ ខែសីហា ឆ្នាំ២០១៨ និងជូនដំណឹងជាភាសាអង់គ្លេស និងភាសាខ្មែរនៅថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៨។

ខាងដើម[43]។

23. នៅថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៨ អង្គបុរេជំនុំជម្រះបានទទួលយកសំណើសុំពន្យារពេលវេលា និងបន្ថែមចំនួនទំព័រ ដោយពន្យារពេលចុងក្រោយដើម្បីដាក់បណ្ដឹងឧទ្ធរណ៍រយៈពេល ៣០ ថ្ងៃ ចាប់ពីថ្ងៃជូនដំណឹងអំពីដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ជាភាសាខ្មែរ បង្កើនចំនួនទំព័រកំណត់សម្រាប់បណ្ដឹងឧទ្ធរណ៍ដល់ទៅ ៤៥ ទំព័រ ជាភាសាអង់គ្លេស ឬភាសាបារាំង ឬចំនួន ៩០ ទំព័រជាភាសាខ្មែរ និងអនុញ្ញាតឲ្យសហមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីដាក់តែមួយភាសាសិន ភាសាអង់គ្លេស ឬភាសាខ្មែរ រីឯការបកប្រែនឹងដាក់តាមក្រោយ[44]។

24. ការបកប្រែជាភាសាខ្មែរនៃដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) និងការបកប្រែជាភាសាអង់គ្លេសនៃដីកាដំណោះស្រាយ (ដីកាសម្រេចលើកលែងចោទប្រកាន់) បានជូនដំណឹងនៅថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៨ និងថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០១៨។

25. នៅថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១៨ សហមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីបានដាក់បណ្ដឹងឧទ្ធរណ៍ ជំទាស់ដីកាសម្រេចលើភាពអាចទទួលស្គាល់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ជូនអង្គបុរេជំនុំជម្រះ ដោយស្នើសុំឲ្យបដិសេធដីកាសម្រេចលើដើមបណ្ដឹងរដ្ឋប្បវេណី (អន្តរជាតិ) (ហៅថា "ដីកាសម្រេចដែលរងការជំទាស់" ផងដែរ)។ នៅក្នុងបណ្ដឹងឧទ្ធរណ៍របស់ខ្លួន សហមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីលើកឡើងថា ដីកាសម្រេចដែលរងការជំទាស់មានកំហុសលើអង្គច្បាប់ និងអង្គហេតុ ហើយស្នើសុំក្នុងចំណោមនោះឲ្យអង្គបុរេជំនុំជម្រះពិចារណាសាជាថ្មី ដល់ភាពអាចយកទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ដែលបាន

---

[43] សំណុំរឿង ០០៤/២ សារណាចូលរួម និងផ្ដល់ការគាំទ្របន្ថែមទៅលើ "សំណើជាបន្ទាន់របស់សហមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី ស្នើសុំពន្យារពេល និងបន្ថែមចំនួនទំព័រ ក្នុងការដាក់បណ្ដឹងឧទ្ធរណ៍ជំទាស់ទៅនឹងសេចក្ដីសម្រេចពីភាពអាចទទួលយកបាន នៃពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីក្នុងសំណុំរឿង ០០៤/២" ចុះថ្ងៃទី២១ ខែសីហា ឆ្នាំ២០១៨ ឯកសារ D362/2។ សំណើនេះបានជូនដំណឹងជាភាសាអង់គ្លេសនៅថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៨ និងជាភាសាខ្មែរនៅថ្ងៃទី២៤ ខែសីហា ឆ្នាំ២០១៨។

[44] សំណុំរឿង ០០៤/២ (អបជ ៥៨) សេចក្ដីសម្រេចលើសំណើរបស់មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីសុំពន្យាររយៈពេលកំណត់ និងចំនួនទំព័រ ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៨ ឯកសារ D362/4។

បដិសេធ[45]។ ពុំមានភាគីណាមួយដាក់ចម្លើយតបទៅនឹងបណ្ដឹងឧទ្ធរណ៍របស់សហមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីទេ។

26. នៅថ្ងៃទី០៥ ខែតុលា ឆ្នាំ២០១៨ សហមេធាវីការពារក្ដី អោ អាន បានដាក់ការជូនដំណឹងអំពីការប្ដឹងឧទ្ធរណ៍លើដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ)[46]។ នៅថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០១៨ សហព្រះរាជអាជ្ញាអន្តរជាតិបានដាក់សេចក្ដីជូនដំណឹងអំពីបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (ដីកាសម្រេចលើកលែងចោទប្រកាន់)[47] ហើយសហព្រះរាជអាជ្ញាជាតិបានដាក់សេចក្ដីជូនដំណឹងអំពីបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ)[48]។ ភាគីបានដាក់សារណាលើបណ្ដឹងឧទ្ធរណ៍ និងចម្លើយតបនានាជាច្រើន[49]។ ភាគីបាន

---

[45] បណ្ដឹងឧទ្ធរណ៍របស់ដើមបណ្ដឹងរដ្ឋប្បវេណី (D362/5) (សហមេធាវីស្នើសុំថា អង្គបុរេជំនុំជម្រះ (១) សម្រេចថា អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី "បន្តអនុវត្តសិទ្ធិជាដើមបណ្ដឹងរដ្ឋប្បវេណីក្នុងពេលអវត្តមានសេចក្ដីសម្រេចដោយមតិភាគច្រើនលើសលប់" ឬ ជាជម្រើសម្យ៉ាងទៀត (២) បដិសេធដីកាដែលរងការជំទាស់ និងពិចារណាឡើងវិញលើពាក្យសុំនៅក្នុងឧបសម្ព័ន្ធ ក (៣) ទទួលយកព័ត៌មានបន្ថែមដែលត្រូវបានដាក់ជូនដោយសហមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី (៤) ផ្ដល់ឋានៈជាដើមបណ្ដឹងរដ្ឋប្បវេណីដល់ម្ចាស់បណ្ដឹងឧទ្ធរណ៍ និង (៥) ជាជម្រើសម្យ៉ាងទៀត ទទួលស្គាល់ម្ចាស់ដើមបណ្ដឹងឧទ្ធរណ៍ដែលមិនបានទទួលឋានៈជាដើមបណ្ដឹងរដ្ឋប្បវេណីក្នុងសំណុំរឿង ០០៤/២ ជា "ដើមបណ្ដឹង/អ្នកប្ដឹង")។

[46] សំណុំរឿង ០០៤/២ ការជូនដំណឹងអំពីការប្ដឹងឧទ្ធរណ៍លើដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ២០១៨ ឯកសារ D360/5។

[47] សំណុំរឿង ០០៤/២ សេចក្ដីជូនដំណឹងអំពីបណ្ដឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹងដីកាសម្រេចរបស់ [សហចៅក្រមស៊ើបអង្កេតជាតិ] លើកលែងការចោទប្រកាន់ប្រឆាំងនឹង អោ អាន (D359) ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ D359/3។

[48] សំណុំរឿង ០០៤/២ សេចក្ដីជូនដំណឹងរបស់សហព្រះរាជអាជ្ញាជាតិ អំពីបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) របស់[សហចៅក្រមស៊ើបអង្កេតអន្តរជាតិ] ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ D360/8។

[49] សំណុំរឿង ០០៤/២ បណ្ដឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិទាក់ទងនឹងដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេត (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ក្នុងសំណុំរឿង ០០៤/២ ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៨ ឯកសារ D360/8/1។ សំណុំរឿង ០០៤/២ បណ្ដឹងឧទ្ធរណ៍របស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ប្រឆាំងនឹងដីកាសម្រេចលើកលែងចោទប្រកាន់ អោ អាន (D359) ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៨ ឯកសារ D359/3/1។ សំណុំរឿង ០០៤/២ បណ្ដឹងឧទ្ធរណ៍របស់ អោ អាន លើដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) របស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៨ ឯកសារ D360/5/1។ សំណុំរឿង ០០៤/២ ចម្លើយតបរបស់ អោ អាន ទៅនឹងបណ្ដឹងឧទ្ធរណ៍របស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិប្រឆាំងនឹងដីកាសម្រេចលើកលែងចោទប្រកាន់ អោ អាន (D359) ចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០១៩ បានជូនដំណឹងជាភាសាអង់គ្លេសនៅថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៩ និងជាភាសាខ្មែរនៅថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១៩ ឯកសារ D359/3/4។ សំណុំរឿង

ធ្វើអំណះអំណាងដោយផ្ទាល់មាត់ ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសវនាការអសាធារណៈ នៅថ្ងៃទី១៩, ២០ និង ២១ ខែមិថុនា ឆ្នាំ២០១៩[50]។

27. នៅថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៩ អង្គបុរេជំនុំជម្រះបានចេញសេចក្តីពិចារណារបស់ខ្លួនលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ដោយសន្និដ្ឋានក្នុងចំណោមថា ការចេញដីកាដំណោះស្រាយផ្ទុយគ្នានៅក្នុងពេលដំណាលគ្នា ជាការរំលោភបំពានទៅលើក្របខណ្ឌគតិយុត្តិនៅ អ.វ.ត.ក[51]។ អង្គបុរេជំនុំជម្រះមិនអាចរកបានសំឡេងគាំទ្រភាគច្រើនលើសលប់ពីចៅក្រម ដើម្បីសម្រេចថាតើ គួរបញ្ជូន អោ អាន ទៅជំនុំជម្រះ ឬយ៉ាងណាទេ។ ទោះបី ចៅក្រមជាតិសម្រេចតម្កល់ដីកាដំណោះស្រាយ (ដីកាសម្រេចលើកលែងចោទប្រកាន់) និងទុកជាមោឃៈនូវដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ប្រឆាំង អោ អាន[52] ក៏ដោយ តែចៅក្រមអន្តរជាតិ

---

០០៤/២ ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទៅនឹងបណ្តឹងឧទ្ធរណ៍របស់ អោ អាន ប្រឆាំងនឹងដីកាសម្រេចបញ្ជូនរឿងទៅជំនុំជម្រះក្នុងសំណុំរឿង ០០៤/២ ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១៩ ជូនដំណឹងជាភាសាអង់គ្លេសនៅថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០១៩ និងជាភាសាខ្មែរនៅថ្ងៃទី១៥ ខែមីនា ឆ្នាំ២០១៩ ឯកសារ D360/9។ សំណុំរឿង ០០៤/២ ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទៅនឹងបណ្តឹងឧទ្ធរណ៍របស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ប្រឆាំងនឹងដីកាសម្រេចបញ្ជូនរឿងទៅជំនុំជម្រះក្នុងសំណុំរឿង ០០៤/២ ចុះថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០១៩ ជូនដំណឹងជាភាសាអង់គ្លេសនៅថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១៩ និងជាភាសាខ្មែរនៅថ្ងៃទី១៥ ខែមីនា ឆ្នាំ២០១៩ ឯកសារ D360/10។ សំណុំរឿង ០០៤/២ ការឆ្លើយតបទៅនឹង២ ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទៅនឹងបណ្តឹងឧទ្ធរណ៍របស់ អោ អាន ប្រឆាំងនឹងដីកាសម្រេចបញ្ជូនរឿងទៅជំនុំជម្រះក្នុងសំណុំរឿង ០០៤/២ ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៩ ជូនដំណឹងជាភាសាអង់គ្លេសនៅថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៩ និងជាភាសាខ្មែរនៅថ្ងៃទី២៣ ខែមេសា ឆ្នាំ២០១៩ ឯកសារ D360/11។ សំណុំរឿង ០០៤/២ ការឆ្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិចម្លើយតបរបស់ អោ អាន ទៅនឹងបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចលើកលែងចោទប្រកាន់ អោ អាន (D359) ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៩ ជូនដំណឹងជាភាសាខ្មែរនៅថ្ងៃទី២២ ខែមេសា ឆ្នាំ២០១៩ ឯកសារ D359/3/5។

[50] សំណុំរឿង ០០៤/២ ប្រតិចារឹកសវនាការថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១៩ (CS) ឯកសារ D359/8.1 & D360/17.1, ERN 01626002-01626051 ទំព័រ ១៣-៦២។ សំណុំរឿង ០០៤/២ ប្រតិចារឹកសវនាការថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៩ (CS) ឯកសារ D359/9.1 & D360/18.1, ERN 01626055-01626124 ទំព័រ ១-៧០។ សំណុំរឿង ០០៤/២ ប្រតិចារឹកសវនាការថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៩ (CS) ឯកសារ D359/10.1 & D360/19.1, ERN 01626128-01626148 ទំព័រ ១-២១។

[51] សំណុំរឿង ០០៤/២ (អបជ ៦០) សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៩ ឯកសារ D359/24 & D360/33 ("សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (D359/24 & D360/33)")។

[52] សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (D359/24 & D360/33) កថាខណ្ឌ ៣០២។

ពិចារណាឃើញថា បទល្មើស ១ នៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ ត្រូវកែសម្រួល ដើម្បីកំហិតបទចោទពីអំពើប្រល័យពូជសាសន៍នៅភូមិភាគកណ្ដាល ហើយបានយល់ព្រមបញ្ជូន អោ អាន ទៅជំនុំជម្រះ ដោយផ្អែកលើដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលបានកែសម្រួល និងយល់ឃើញថា អង្គជំនុំជម្រះសាលាដំបូង ត្រូវទទួលវិនិច្ឆ័យ អនុលោមតាមវិធាន ៧៧(១៣)(ខ) នៃវិធានផ្ទៃក្នុង[53]។

## II. បទដ្ឋាននៃការត្រួតពិនិត្យឡើងវិញ

28. វិធាន ៧៧ស្ទួន នៃវិធានផ្ទៃក្នុង តម្រូវឱ្យម្ចាស់បណ្ដឹងឧទ្ធរណ៍ស្នើសុំឱ្យបដិសេធដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត ស្ដីពីភាពអាចទទួលយកបាននៃអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ដោយបង្ហាញឱ្យឃើញថា សេចក្ដីសម្រេចរងការជំទាស់នេះ បានសំអាងលើកំហុសអង្គច្បាប់ និង/ឬ អង្គហេតុ[54]។ អង្គបុរេជំនុំជម្រះសូមរំឭកឡើងវិញថា ចំពោះបណ្ដឹងឧទ្ធរណ៍កំហុសអង្គច្បាប់ដែលរងការចោទប្រកាន់ ត្រូវបានពិនិត្យជាថ្មីឡើងវិញ ដើម្បីវាយតម្លៃថាតើ ការសម្រេចផ្នែកអង្គច្បាប់មានលក្ខណៈត្រឹមត្រូវដែរឬយ៉ាងណា ហើយកំហុសអង្គហេតុដែលរងការចោទប្រកាន់ ត្រូវបានពិនិត្យឡើងវិញ ផ្អែកតាមបទដ្ឋាននៃភាពសមហេតុសមផល ដើម្បីសម្រេចថា តើមានអ្នកវិនិច្ឆ័យលើអង្គហេតុដែលមានហេតុផលណាម្នាក់ អាចឈានដល់ការសម្រេចលើអង្គហេតុ ដែលចោទជាបញ្ហានេះដែរ ឬយ៉ាងណា[55]។

---

[53] សេចក្ដីពិចារណាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (D359/24 & D360/33) កថាខណ្ឌ ៦៨៤, ៦៩៤។

[54] វិធាន ៧៧ស្ទួន នៃវិធានផ្ទៃក្នុង។ សូមមើល ផងដែរ សំណុំរឿង ០០២ សាលដីកាលើគ្រប់បណ្ដឹងឧទ្ធរណ៍របស់ដើមបណ្ដឹងរដ្ឋប្បវេណី (D404/2/4) កថាខណ្ឌ ៣៤។ សំណុំរឿង ០០២ សាលដីកាលើគ្រប់បណ្ដឹងឧទ្ធរណ៍របស់ដើមបណ្ដឹងរដ្ឋប្បវេណី (D411/3/6) កថាខណ្ឌ ៣៤។

[55] សេចក្ដីពិចារណាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (D359/24 & D360/33) កថាខណ្ឌ ៣៨១ សំអាងលើសំណុំរឿង ០០២ (អ.ប.ជ៧៥) សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០១១ ឯកសារ D427/1/30 កថាខណ្ឌ ១១៣។ សំណុំរឿង ០០២ សាលដីកា ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ ឯកសារ កថាខណ្ឌ ៨៩-៩០។ សំណុំរឿង ០០២ សាលដីកាលើគ្រប់បណ្ដឹងឧទ្ធរណ៍របស់ដើមបណ្ដឹងរដ្ឋប្បវេណី (D404/2/4) កថាខណ្ឌ ៣៤។ សំណុំរឿង ០០២ សាលដីកាលើគ្រប់បណ្ដឹងឧទ្ធរណ៍របស់ដើមបណ្ដឹងរដ្ឋប្បវេណី (D411/3/6) កថាខណ្ឌ ៣៤។

## III. ភាពអាចទទួលយកបាន

29. សហមេធាវីប្ដឹងឧទ្ធរណ៍ជំទាស់ នឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិដោយអនុលោមតាមវិធាន ៧៧ស្ទួន នៃវិធានផ្ទៃក្នុង និងអះអាងថា បណ្ដឹងឧទ្ធរណ៍បានដាក់ទាន់ពេលវេលា និងស្របតាមការកម្រិតចំនួនទំព័រ[56]។

30. អង្គបុរេជំនុំជម្រះសូមរំឭកឡើងវិញថា អនុលោមតាមវិធាន ៧៤(៤)(ខ) នៃវិធានផ្ទៃក្នុង "ដើមបណ្ដឹងរដ្ឋប្បវេណី អាចធ្វើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីការបស់សហចៅក្រមស៊ើបអង្កេត[...] ដោយការប្រកាសមិនទទួលពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី"[57]។ វិធាន ៧៧ស្ទួន នៃវិធានផ្ទៃក្នុងចែងថា បណ្ដឹងឧទ្ធរណ៍ត្រូវដាក់ "ក្នុងរយៈពេល១០ថ្ងៃ ចាប់ពីថ្ងៃជូនដំណឹងនៃសេចក្ដីសម្រេចអំពីភាពអាចទទួលយកបាន នូវពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី")[58]។ អង្គបុរេជំនុំជម្រះ យល់ឃើញថា បណ្ដឹងឧទ្ធរណ៍ត្រូវបានដាក់ជូនស្របតាមសេចក្ដីណែនាំរបស់ខ្លួន ដោយរំឭកឡើងវិញអំពីសាលដីការបស់ខ្លួន ដែលអនុញ្ញាតិជាពិសេសឲ្យសហមេធាវីទទួលបានការ

[56] បណ្ដឹងឧទ្ធរណ៍របស់ដើមបណ្ដឹងរដ្ឋប្បវេណី (D362/5) កថាខណ្ឌ ៦-៧។

[57] វិធាន ៧៤(៤)(ខ) នៃវិធានផ្ទៃក្នុង។ សូមមើល ផងដែរ
សាលដីកាលើគ្រប់បណ្ដឹងឧទ្ធរណ៍ទាំងអស់ប្រឆាំងនឹងដីកាសម្រេចនានារបស់សហចៅក្រមស៊ើបអង្កេត
លើភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១១ ឯកសារ D404/2/4 ("សំណុំរឿង ០០២ សាលដីកាលើគ្រប់បណ្ដឹងឧទ្ធរណ៍របស់ដើមបណ្ដឹងរដ្ឋប្បវេណី (D404/2/4)") កថាខណ្ឌ ៣៣។
សំណុំរឿង ០០២ សាលដីកាលើគ្រប់បណ្ដឹងឧទ្ធរណ៍ទាំងអស់ប្រឆាំងនឹងដីកាសម្រេចនានារបស់សហចៅក្រមស៊ើបអង្កេត
លើភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើម
បណ្ដឹងរដ្ឋប្បវេណី ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១១ ឯកសារ D411/3/6 ("សំណុំរឿង ០០២ សាលដីកាលើ
គ្រប់បណ្ដឹងឧទ្ធរណ៍របស់ដើមបណ្ដឹងរដ្ឋប្បវេណី (D411/3/6)") កថាខណ្ឌ ៣៣។

[58] វិធាន ៧៧ស្ទួន នៃវិធានផ្ទៃក្នុង។ សូមមើល ផងដែរ សំណុំរឿង ០០២ សាលដីកាលើគ្រប់បណ្ដឹងឧទ្ធរណ៍របស់ដើមបណ្ដឹងរដ្ឋប្បវេណី (D404/2/4) កថាខណ្ឌ ៣៣។ សំណុំរឿង ០០២ សាលដីកាលើគ្រប់បណ្ដឹងឧទ្ធរណ៍របស់ដើមបណ្ដឹងរដ្ឋប្បវេណី (D411/3/6) កថាខណ្ឌ ៣៣។

ពន្យារ ពេលរហូតដល់ ៣០ ថ្ងៃ ដើម្បីដាក់បណ្តឹងឧទ្ធរណ៍របស់ខ្លួន[59]។ អាស្រ័យហេតុនេះ អង្គបុរេ ជំនុំជម្រះយល់ឃើញថា បណ្តឹងឧទ្ធរណ៍នេះអាចទទួលយកបាន។

## IV. គោលការណ៍គតិយុត្តិនៃភាពអាចទទួលយកបានជាដើមបណ្តឹងរដ្ឋប្បវេណី

31. នៅក្នុងការវាយតម្លៃលើបណ្តឹងឧទ្ធរណ៍របស់សហមេធាវី អង្គបុរេជំនុំជម្រះយល់ឃើញថា ជាការសមស្របក្នុងការរម្លឹកឡើងវិញអំពីគោលការណ៍គតិយុត្តិនានា ដែលបញ្ញត្តិអំពីភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅចំពោះមុខ អ.វ.ត.ក។

32. វិធាន ២៣ស្ទួន(១) កំណត់អំពីលក្ខណៈវិនិច្ឆ័យសម្រាប់ទទួលយកអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី៖

ដើម្បីពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីអាចទទួលយកបាន អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីត្រូវ៖

ក) បង្ហាញអត្តសញ្ញាណឲ្យបានច្បាស់ និង

ខ) បង្ហាញជាលទ្ធផលផ្ទាល់ពីបទឧក្រិដ្ឋ យ៉ាងហោចណាស់មួយនៃបទឧក្រិដ្ឋជាច្រើនដែលត្រូវបានចោទប្រកាន់លើជនត្រូវចោទ ថាខ្លួនពិតជាបានទទួលរងនូវព្យសនកម្មខាងរូបរាងកាយ ខាងសម្ភារៈ ឬផ្លូវចិត្ត ដែលអាចជាមូលដ្ឋានសម្រាប់ការទាមទារសំណងផ្លូវចិត្ត និងសមូហភាព។

> នៅពេលពិចារណាអំពីភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីសហចៅក្រមស៊ើបអង្កេតត្រូវតែមានជំនឿថា អង្គហេតុដែលគាំទ្រដល់ការដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនោះមានភាពពិតប្រាកដ។

---

[59] សំណុំរឿង ០០២ សេចក្តីសម្រេចលើសំណើរបស់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី សុំពន្យាររយៈពេលកំណត់ និងចំនួនទំព័រ (អង្គបុរេជំនុំជម្រះបានពន្យាររយៈពេលកំណត់សម្រាប់ការបណ្តឹងឧទ្ធរណ៍រហូតដល់ ៣០ គិតចាប់ពីថ្ងៃជូនដំណឹងអំពីដីកាដំណោះស្រាយ (ដីកាសម្រេចបញ្ជូនរឿងទៅជំនុំជម្រះ) ជាភាសាខ្មែរ និងបានបង្កើនចំនួនទំព័រកំណត់សម្រាប់សេចក្តីសន្និដ្ឋានរហូតដល់ ៤៥ ទំព័រ ជាភាសាអង់គ្លេស និងបារាំង និង ៩០ ទំព័រ ជាភាសាខ្មែរ។ ការបកប្រែជាភាសាខ្មែរនៃដីកាដំណោះស្រាយ (ដីកាសម្រេចបញ្ជូនរឿងទៅជំនុំជម្រះ) ត្រូវបានជូនដំណឹងនៅថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៨។ ដើមបណ្តឹងរដ្ឋប្បវេណីបានដាក់បណ្តឹងឧទ្ធរណ៍របស់ខ្លួននៅថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១៨)។

33. ដូចអង្គបុរេជំនុំជម្រះបានកត់សម្គាល់ពីមុនរួចហើយ[60] ធាតុផ្សំគតិយុត្តិដែលមានចែងនៅក្នុងវិធាន ២៣ស្ទួន(១)នៃវិធានផ្ទៃក្នុង រួមមាន៖ (ក) អត្ថិភាពនៃទំនាក់ទំនងរវាងឧក្រិដ្ឋកម្ម និងព្យសនកម្ម (ខ) ការខូចខាត និង (គ) ភ័ស្តុតាងនៃអត្តសញ្ញាណ។ វិធាន២៣ស្ទួន(១)នៃវិធានផ្ទៃក្នុង ក៏ចែងផងដែរអំពីកម្រិតនៃភ័ស្តុតាងពាក់ព័ន្ធ ដែលត្រូវតែមានការបង្ហាញអំពីធាតុផ្សំទាំងនេះ។ នៅក្នុងដំណើរការពិនិត្យមើលទៅលើបណ្តឹងឧទ្ធរណ៍ អង្គជំនុំជម្រះនឹងពិភាក្សាអំពីទិដ្ឋភាពឲ្យផ្លូវច្បាប់ជាក់លាក់នៃធាតុផ្សំទាំងនេះ និងកម្រិតនៃភ័ស្តុតាងពាក់ព័ន្ធនិងការវាយតម្លៃសារណាបណ្តឹងឧទ្ធរណ៍របស់សហមេធាវី។ នៅក្នុងផ្នែកនេះអង្គបុរេជំនុំជម្រះផ្តល់ជូននូវសេចក្តីសង្កេតទូទៅដូចខាងក្រោមនេះ។

34. ជាបញ្ហាបឋម អង្គបុរេជំនុំជម្រះយល់ឃើញថា (i) កិច្ចព្រមព្រៀង អ.វ.ត.ក (ii) ច្បាប់ អ.វ.ត.ក (iii) វិធាន ២១, ២៣, ២៣ស្ទួន, ២៣ស្ទួនពីរ, ២៣ស្ទួនបី,២៣ស្ទួនប្រាំ និង ១១៤ នៃវិធានផ្ទៃក្នុង និង (iv) សេចក្តីណែនាំអនុវត្តស្តីពីការចូលរួមរបស់ជនរងគ្រោះ បង្កើតបានជាផ្នែកនៃបរិបទជាធរមាននៅក្នុងការបកស្រាយអំពីលក្ខណៈវិនិច្ឆ័យសម្រាប់ការទទួលយកដើមបណ្តឹងរដ្ឋប្បវេណី[61]។ ការណែនាំក៏អាចស្វែងរកឃើញផងដែរនៅក្នុងគោលការណ៍ទូទៅស្តីពីជនរងគ្រោះ ដែលមានចែងនៅក្នុងច្បាប់អន្តរជាតិ[62]។

---

[60] សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (ឯកសារ D404/2/4) កថាខណ្ឌ ៥៧។ សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (ឯកសារ D411/3/6) កថាខណ្ឌ ៥៧។

[61] សេចក្តីណែនាំអនុវត្តស្តីពីការចូលរួមរបស់ជនរងគ្រោះ អវតក/០២/២០០៧/វិ.១។ សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (ឯកសារ D404/2/4) កថាខណ្ឌ ៣១។ សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (ឯកសារ D411/3/6) កថាខណ្ឌ ៣១។

[62] សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (D404/2/4) កថាខណ្ឌ ៣២។ សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (ឯកសារ D411/3/6) កថាខណ្ឌ ៣២ (ដែលយោងទៅសេចក្តីប្រកាសពីគោលការណ៍ជាមូលដ្ឋាននៃយុត្តិធម៌សម្រាប់ជនរងគ្រោះដោយឧក្រិដ្ឋកម្ម និងការរំលោភអំណាចដែលបានអនុម័តដោយមហាសន្និបាតអង្គការសហប្រជាជាតិ តាមសេចក្តីសម្រេចលេខ 40/34 ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ១៩៨៥ ("គោលការណ៍ស្តីពីជនរងគ្រោះឆ្នាំ១៩៨៥") និងគោលការណ៍ជាមូលដ្ឋាន និងការណែនាំស្តីពីសិទ្ធិទទួលបានដំណោះស្រាយ និងការជួសជុលសំណងព្យសនកម្មដល់ជនរងគ្រោះដោយសារការរំលោភបំពានក៏កំរោលលើច្បាប់សិទ្ធិមនុស្សអន្តរជាតិ និងការរំលោភបំពានយ៉ាងធ្ងន់ធ្ងរលើច្បាប់មនុស្សធម៌អន្តរជាតិ ដែលត្រូវបានអនុម័តដោយមហាសន្និបាតអង្គការសហប្រជាជាតិ តាមសេចក្តីសម្រេចលេខ 60/147 ចុះថ្ងៃទី២១ ខែមីនា ឆ្នាំ២០០៦ ("គោលការណ៍ស្តីពីជនរងគ្រោះឆ្នាំ២០០៥"))។

35. ទាក់ទិននឹងអត្ថិភាពនៃទំនាក់ទំនងហេតុ និងផល អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ត្រូវតែបង្ហាញថាព្យសនកម្មត្រូវតែជាផលវិបាកដោយផ្ទាល់ពីបទឧក្រិដ្ឋដែលត្រូវបានចោទប្រកាន់លើជនត្រូវចោទ[63]។ ទោះបីជាព្យសនកម្មត្រូវតែមានលក្ខណៈជារូបវន្តក៏ដោយ ក៏លក្ខខណ្ឌតម្រូវនៃព្យសនកម្មជាផលវិបាកដោយផ្ទាល់នៃបទល្មើស មិនកម្រិតការទទួលយកដើមបណ្តឹងរដ្ឋប្បវេណីត្រឹមជនរងគ្រោះផ្ទាល់នោះទេ ប៉ុន្តែអាចរួមបញ្ចូលនូវជនរងគ្រោះមិនផ្ទាល់ផងដែរ ដែលបានទទួលរងព្យសនកម្មផ្ទាល់ខ្លួន ជាផលវិបាកផ្ទាល់នៃឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តទៅលើជនរងគ្រោះផ្ទាល់[64]។ ហេតុនេះ យុត្តិសាស្ត្រ អ.វ.ត.ក ទទួលស្គាល់ទាំងជនរងគ្រោះផ្ទាល់ និងទាំងជនរងគ្រោះមិនផ្ទាល់។ ជនរងគ្រោះផ្ទាល់សំដៅទៅលើ "ក្រុមបុគ្គលណាដែលសិទ្ធិរបស់ខ្លួនត្រូវបានរំលោភបំពាន ឬទទួលរងការប៉ះពាល់ដែលបណ្តាលមកពីឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់"[65]។ ជនរងគ្រោះមិនផ្ទាល់ គឺជាបុគ្គលទាំងឡាយណាដែល "ទទួលរងដោយផ្ទាល់នូវព្យសនកម្មដែលជាផលវិបាកផ្ទាល់នៃឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តលើជនរងគ្រោះផ្ទាល់"[66]។

36. ទាក់ទិននឹងព្យសនកម្មវិញ វិធាន ២៣ស្ទួន(១)(ខ) នៃវិធានផ្ទៃក្នុងចែងថា ព្យសនកម្មត្រូវតែជាការខូចខាតខាងរាងកាយ សម្ភារៈ ឬផ្លូវចិត្ត[67]។ ការខូចខាតខាងរាងកាយ "មានន័យថាជាការខូចខាតខាងជីវសាស្ត្រ ខាងសរីរាង្គ ឬខាងប្រព័ន្ធដំណើរការនៃសរីរាង្គ" និង "អាចជារបួសស្នាម កាយវិកលកម្ម ការខូចទ្រង់ទ្រាយ មានជំងឺ ការបាត់បង់ ឬការមិនដំណើរ

[63] សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (ឯកសារ D404/2/4) កថាខណ្ឌ ៧១។ សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (ឯកសារ D411/3/6) កថាខណ្ឌ ៧១។ សូមមើលបន្ថែមទៀត មូលដ្ឋានទី១ ខាងក្រោម។

[64] សំណុំរឿង ០០១/១៨-០៧-២០០៧-អវតក/អជតក ("សំណុំរឿង ០០១") សាលដីកា ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១២ ឯកសារ F28 ("សាលដីកា សំណុំរឿង ០០១ (ឯកសារ F28)") កថាខណ្ឌ ៤១៨។ សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (ឯកសារ D404/2/4) កថាខណ្ឌ ៨៣។ សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (ឯកសារ D411/3/6) កថាខណ្ឌ ៨៣។

[65] សាលដីកា សំណុំរឿង ០០១ (ឯកសារ F28) កថាខណ្ឌ ៤១៦។

[66] សាលដីកា សំណុំរឿង ០០១ (ឯកសារ F28) កថាខណ្ឌ ៤១៨។

[67] សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (ឯកសារ D404/2/4) កថាខណ្ឌ ៨៣។ សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (ឯកសារ D411/3/6) កថាខណ្ឌ ៨៣។

01647475



ការនៃសរីរាង្គណាមួយ ឬមរណភាព"[68]។ ព្យសនកម្មខាង សម្ភារៈ "សំដៅដល់ការបាត់បង់តម្លៃជារត្នរូបិយ ដូចជាការខូចខាតទ្រព្យសម្បត្តិផ្ទាល់ខ្លួនទាំងស្រុង ឬមួយផ្នែក ឬការបាត់បង់ប្រាក់ចំណូលជាដើម"[69]។ ចុងក្រោយ ព្យសនកម្មខាងផ្លូវចិត្តអាច "រួមបញ្ចូលទាំងជំងឺផ្លូវចិត្ត ឬវិកលចរិត ដូចជាជំងឺបាក់ស្បាត"[70]។

37. ទាក់ទិននឹងលក្ខខណ្ឌតម្រូវសម្រាប់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីទាំងអស់ក្នុងការបង្ហាញអត្តសញ្ញាណឲ្យបានច្បាស់នោះ អង្គបុរេជំនុំជម្រះធ្លាប់បានអនុម័តវិធីសាស្ត្រមួយដែលមានលក្ខណៈបត់បែន ដែលរួមមាន ឧទាហរណ៍ ទទួលយកជាភ័ស្តុតាងនៃអត្តសញ្ញាណនូវសេចក្ដីបញ្ជាក់នានាដែលចេញដោយអ្នកភូមិចាស់ទុំ ឬមេភូមិជាដើម[71]។

38. ទាក់ទិននឹងកម្រិតនៃភ័ស្តុតាងដែលត្រូវតែមានការបង្ហាញអំពីធាតុផ្សំខាងលើនេះ អនុលោមតាមវិធាន២៣ស្ទួន(១)នៃវិធានផ្ទៃក្នុង នៅក្នុងការវាយតម្លៃលើសម្ភារៈដែលបានដាក់ជាផ្នែកនៃពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីនោះ អង្គបុរេជំនុំជម្រះត្រូវតែ "ជឿជាក់ថា អង្គហេតុដែលបានអះអាងដើម្បីគាំទ្រដល់ពាក្យសុំនោះ មានភាពពិតប្រាកដ"[72]។

## V. អង្គសេចក្ដី

39. ទោះបីជាសេចក្ដីសម្រេចរបស់អង្គបុរេជំនុំជម្រះស្ដីពីភាពអាចទទួលយកបាននៃបណ្ដឹងឧទ្ធរណ៍ត្រូវបានលើកឡើងនៅក្នុងកថាខណ្ឌខាងលើក្ដី បន្ទាប់ពីប្រជុំពិភាក្សារួចហើយ អង្គជំនុំជម្រះមិន

---

[68] សាលដីកា សំណុំរឿង ០០១ (ឯកសារ F28) កថាខណ្ឌ ៤១៥។

[69] សាលដីកា សំណុំរឿង ០០១ (ឯកសារ F28) កថាខណ្ឌ ៤១៥។

[70] សំណុំរឿង ០០២ សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់ដើមបណ្ដឹងរដ្ឋប្បវេណី (ឯកសារ D404/2/4) កថាខណ្ឌ៨៣។ សំណុំរឿង ០០២ សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់ដើមបណ្ដឹងរដ្ឋប្បវេណី (ឯកសារ D411/3/6) កថាខណ្ឌ ៨៣។ សាលដីកា សំណុំរឿង ០០១ (ឯកសារ F28) កថាខណ្ឌ ៤១៥។

[71] សំណុំរឿង ០០២ សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់ដើមបណ្ដឹងរដ្ឋប្បវេណី (ឯកសារ D404/2/4) កថាខណ្ឌ ៨៥។ សំណុំរឿង ០០២ សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់ដើមបណ្ដឹងរដ្ឋប្បវេណី (ឯកសារ D411/3/6) កថាខណ្ឌ ៨៥។ សូមមើលបន្ថែមទៀត មូលដ្ឋានទី៤ ខាងក្រោម។

[72] សំណុំរឿង ០០២ សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់ដើមបណ្ដឹងរដ្ឋប្បវេណី (D404/2/4) កថាខណ្ឌ ៨៤។ សំណុំរឿង ០០២ សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់ដើមបណ្ដឹងរដ្ឋប្បវេណី (ឯកសារ D411/3/6) កថាខណ្ឌ ៨៤។ សូមមើលបន្ថែមទៀត មូលដ្ឋានទី ៤ ខាងក្រោម។

អាចទទួលបានសម្លេងភាគច្រើនលើសលប់នៃសម្លេងគាំទ្រចំនួនបួនតាមការកំណត់ ដើម្បីឈានទៅសេចក្តីសម្រេច ផ្អែកលើសំអាងហេតុរួមលើអង្គសេចក្តីឡើយ។ អនុលោមតាមវិធាន ៧៧(៤) នៃវិធានផ្ទៃក្នុង មតិរបស់សមាជិកផ្សេងៗគ្នានៃអង្គបុរេជំនុំជម្រះត្រូវបានភ្ជាប់មកជាមួយសាលដីកានេះ។

## VI. សេចក្តីសម្រេច

**អាស្រ័យហេតុនេះ អង្គបុរេជំនុំជម្រះសម្រេចជាឯកច្ឆន្ទ៖**

- **ប្រកាសជាឯកច្ឆន្ទ** ថា ពុំអាចរកសម្លេងគាំទ្រពីចៅក្រមចំនួនបួន ក្នុងការសម្រេចសេចក្តីលើបណ្តឹងឧទ្ធរណ៍នេះ។

តាមវិធាន៧៧ (១៣) នៃវិធានផ្ទៃក្នុង សាលដីកានេះបិតផ្លូវតវ៉ា។

**រាជធានីភ្នំពេញ ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ ២០២០**

**ប្រធាន** **អង្គបុរេជំនុំជម្រះ**

**ប្រាក់ គឹមសាន** **Olivier BEAUVALLET** **ន័យ ថុល** **Kang Jin BAIK** **ហួត វុទ្ធី**

ចៅក្រមប្រាក់ គឹមសាន ចៅក្រមន័យ ថុល និងចៅក្រមហួត វុទ្ធី សូមលើកឡើងនូវមតិយោបល់របស់ខ្លួន ទាក់ទិននឹងអង្គសេចក្តីនៃបណ្តឹងឧទ្ធរណ៍។ ចៅក្រម Olivier BEAUVALLET និងចៅក្រម Kang Jin BAIK សូមលើកឡើងនូវមតិយោបល់របស់ខ្លួន ទាក់ទិននឹងអង្គសេចក្តីនៃបណ្តឹងឧទ្ធរណ៍។

## VII. យោបល់របស់ចៅក្រមប្រាក់ គឹមសាន ចៅក្រមន័យ ថុល និងចៅក្រម ហួត វុទ្ធី

40. តាមវិធាន២៣ស្ទួន នៃវិធានផ្ទៃក្នុង៖

១.ដើម្បីឲ្យពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីអាចទទួលយកបាន អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីត្រូវ៖

ក. បង្ហាញពីអត្តសញ្ញាណឲ្យបានច្បាស់លាស់

ខ. បង្ហាញជាលទ្ធផលដោយផ្ទាល់ពីបទឧក្រិដ្ឋ យ៉ាងហោចណាស់មួយនៃបទឧក្រិដ្ឋជាច្រើន ដែលត្រូវបានចោទប្រកាន់លើជនត្រូវចោទថាខ្លួនពិតជាបានទទួលរងនូវព្យសនកម្មខាងរូបរាងកាយ ខាងសម្ភារៈ ឬផ្លូវចិត្ត ដែលអាចជាមូលដ្ឋានសម្រាប់ការទាមទារសំណងផ្លូវចិត្ត និងសមូហភាព។

41. នៅក្នុងសាលដីការបស់អបជ លេខD359/24 និង D360/33 អបជ បានសម្រេចជាឯកច្ឆន្ទ័ និងប្រកាសថាការចេញដីកាដំណោះស្រាយពីរដែលផ្ទុយគ្នា គឺខុសច្បាប់ ហើយរំលោភបំពានលើក្របខណ្ឌគតិយុត្តិរបស់អ.វ.ត.ក[73]។ ហើយចៅក្រមជាតិបានពិចារណាឃើញថាដីកាដំណោះស្រាយលើកលែងចោទប្រកាន់អោ អាន ដែលសម្រេចសេចក្តីមកនេះ ធ្វើឡើងតាមកិច្ចព្រមព្រៀង និងច្បាប់អ.វ.ត.ក ត្រូវតម្កល់ទុកជាបានការ និងដីកាដំណោះស្រាយចោទប្រកាន់អោ អាន បញ្ជូនទៅជំនុំជម្រះ ដែលសម្រេចសេចក្តីមកនេះ ធ្វើឡើងពុំត្រឹមត្រូវតាមកិច្ចព្រមព្រៀង និងច្បាប់ អ.វ.ត.កឡើយ ត្រូវទុកជាមោឃៈ និងចុងក្រោយចៅក្រមជាតិបានសម្រេចតម្កល់ ដីកាដំណោះស្រាយលើកលែងចោទប្រកាន់ អោ អាន ទុកជាបានការ និងទុកជាមោឃៈ នូវដីកាដំណោះស្រាយចោទប្រកាន់ អោ អាន បញ្ជូនទៅជំនុំជម្រះ[74]។

42. តាមវិធាន២៣ស្ទួន និងសេចក្តីសម្រេចក្នុងឯកសារលេខD359/24 និង D360/33 ខាងលើ ចៅក្រមជាតិនៃអបជ យល់ឃើញថា ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់គប្បីបដិសេធ មិនមែនបដិសេធតែមួយចំនួន ដូចដែលសហចៅក្រមស៊ើបអង្កេតអន្តរជាតិ

---

[73] សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ឯកសារលេខ D359/24 និង D360/33 ទំព័រ៨៩

[74] ដូចខាងលើ ទំព័រ១៣៣

បានធ្វើនោះឡើយ។

43. ហេតុដូច្នេះចៅក្រមជាតិនៃអបជ សម្រេចបដិសេធពាក្យសុំតាំងខ្លួនជាដើម បណ្ដឹងរដ្ឋប្បវេណីទាំងអស់នៅក្នុងសំណុំរឿង០០៤/២។

**រាជធានីភ្នំពេញ ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២០**

**ប្រធាន** **អង្គបុរេជំនុំជម្រះ**

**ប្រាក់ គឹមសាន** **ន័យ ថុល** **ហួត វុទ្ធី**

## VIII. យោបល់របស់ចៅក្រមBAIK និងចៅក្រម BEAUVALLET

44. ចៅក្រមអន្តរជាតិនឹងបង្ហាញអំពីការពិចារណារបស់ខ្លួនទៅលើបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណីដូចតទៅ។

### ក. មូលដ្ឋានទី ១៖ សហចៅក្រមស៊ើបអង្កេតអន្តរជាតិមានកំហុសលើអង្គច្បាប់ និងអង្គហេតុ ដោយគ្រាន់តែកំណត់អត្តសញ្ញាណឧក្រិដ្ឋកម្មទាំងឡាយដែលត្រូវបានប្រព្រឹត្តនៅក្នុងភូមិភាគកណ្តាលថាជាប់ពាក់ព័ន្ធទៅនឹងលក្ខខណ្ឌតម្រូវពីទំនាក់ទំនង អនុលោមតាមវិធាន ២៣ស្ទួន(១)(ខ) នៃវិធានផ្ទៃក្នុង

#### *១. សារណា*

45. សហមេធាវីអះអាងថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិមានកំហុសលើអង្គច្បាប់ និងអង្គហេតុ ដោយពិនិត្យតែទៅលើបទឧក្រិដ្ឋដែលត្រូវបានចោទប្រកាន់ថាបានប្រព្រឹត្តនៅក្នុងភូមិភាគកណ្តាលថាជាប់ពាក់ព័ន្ធទៅនឹងភាពអាចទទួលស្គាល់ជាដើមបណ្តឹងរដ្ឋប្បវេណី[75]។ ក្នុងការធ្វើបែបនេះ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ៖ (ក) បានច្រានចោលការចោទប្រកាន់ អោ អាន ថាបានចូលរួមក្នុង "សហឧក្រិដ្ឋកម្មរួមថ្នាក់ជាតិ ដែលមានគោលបំណងអនុវត្តគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជាទូទាំងប្រទេស រាប់បញ្ចូលទាំងការអនុវត្តគោលនយោបាយទាំងនេះ តាមរយៈឧក្រិដ្ឋកម្មនានានៅក្រៅភូមិភាគកណ្តាល [...]"[76] និង (ខ) មិនបានពិចារណាទៅលើ "ការសន្មតជាមុនពីព្យសនកម្មសមូហភាព ដែលមានវិសាលភាពគ្របដណ្តប់លើក្រុម ឬសហគមន៍ដែលត្រូវបានចាត់ទុកជាគោលដៅតែមួយ ដោយមិនគិតពីទីកន្លែងរបស់ពួកគេ"[77]។

46. នៅក្រោមមូលដ្ឋានទី ១(ក) សហមេធាវីលើកឡើងថា ដីកាដែលរងការជំទាស់មានកំហុស ដោយផ្តោតតែទៅលើឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តនៅក្នុងភូមិភាគកណ្តាល[78] ទោះបីមានការចោទប្រកាន់

---

[75] បណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (D362/5) កថាខណ្ឌ ១៧។

[76] បណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (D362/5) មានចំណងជើងថា ផ្នែក ៥ (ក)(ក)។

[77] បណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (D362/5) កថាខណ្ឌ ១៧។

[78] បណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (D362/5) កថាខណ្ឌ ១៨។

នានាថា អោ អាន បានចូលរួមនៅក្នុងសហឧក្រិដ្ឋកម្មរួមថ្នាក់ជាតិក៏ដោយ[79]។ សហមេធាវីអះអាងថា អង្គបុរេជំនុំជម្រះបានបញ្ជាក់ច្បាស់នៅក្នុងសំណុំរឿង ០០២ ថា វិធាន ២៣ស្ទួន(១)(ខ) នៃវិធានផ្ទៃក្នុង តម្រូវឱ្យអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីបង្ហាញទំនាក់ទំនងរវាង "ព្យសនកម្មរូបរាងកាយ សម្ភារៈ ឬផ្លូវចិត្ត" និង "ឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់" ដែលជា "ការកំណត់ប្រភេទបទល្មើសដែលត្រូវបានស៊ើបអង្កេត" ជាជាងអង្គហេតុដែលត្រូវបានស៊ើបអង្កេតផ្ទាល់[80]។ ហេតុនេះ ក្នុងករណីនៃអំពើឃោរឃៅជាទ្រង់ទ្រាយធំបានប្រព្រឹត្តតាមរយៈសហឧក្រិដ្ឋកម្មរួម ជាគោលនយោបាយទូទាំងប្រទេស អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីពុំចាំបាច់ត្រូវបានតម្រូវឱ្យភ្ជាប់ទំនាក់ទំនងរវាងព្យសនកម្មរបស់ខ្លួន ទៅនឹងទីតាំងឧក្រិដ្ឋកម្ម ឬអង្គហេតុនានាដែលបានរៀបរាប់នៅក្នុងដីកាដំណោះស្រាយទេ[81]។

47. សហមេធាវីអះអាងថា ការសម្រេចរបស់អង្គបុរេជំនុំជម្រះនៅក្នុងសំណុំរឿង ០០២ អនុវត្តស្មើគ្នានៅក្នុងករណីនេះដែរ ដោយសារ អោ អាន បានចូលរួមក្នុងសហឧក្រិដ្ឋកម្មរួមថ្នាក់ជាតិ ដែលមានគោលបំណងអនុវត្តគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជានៅទូទាំងប្រទេសកម្ពុជា[82]។ ពួកគេចោទប្រកាន់ថា ដីកាដំណោះស្រាយ (ដីកាបញ្ជូនទៅជំនុំជម្រះ) ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទី៣ និង ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម "ពោរពេញដោយការចោទប្រកាន់ពីការចូលរួមរបស់ អោ អាន ក្នុងសហឧក្រិដ្ឋកម្មរួមថ្នាក់ជាតិ ដែលគ្របដណ្តប់លើឧក្រិដ្ឋកម្មដែលបានចោទប្រកាន់លើសពីឧក្រិដ្ឋកម្មដែលត្រូវបានប្រព្រឹត្ត"នៅភូមិភាគកណ្តាល[83] ហើយអះអាងថាសហឧក្រិដ្ឋកម្មរួមថ្នាក់ជាតិ ត្រូវបានអនុវត្តតាមរយៈបណ្តាញអង្គការចាត់តាំង

---

[79] បណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (D362/5) កថាខណ្ឌ ១៨, ២៦។

[80] បណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (D362/5) កថាខណ្ឌ ១៨ *យោងទៅ* សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (D404/2/4) កថាខណ្ឌ ៤២។

[81] បណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (D362/5) កថាខណ្ឌ ២០ *យោងទៅ* សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (D404/2/4) កថាខណ្ឌ ៧២។

[82] បណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (D362/5) កថាខណ្ឌ ២១។

[83] បណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (D362/5) កថាខណ្ឌ ២៣ *យោងទៅ* ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (D360) កថាខណ្ឌ ៣០៧។ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមលើកទី ១ (D65) កថាខណ្ឌ ២៣។

ថ្នាក់ភូមិភាគ ដែលរួមមានអង្គការចាត់តាំងរបស់ អោ អាន នៅភូមិភាគកណ្ដាល[84]។ ដើម្បីគាំទ្រដល់ការអះអាងទាំងនេះ សហមេធាវីបានយោងទៅការចោទប្រកាន់នានាដែលថា ការចាប់ខ្លួន និងការបាត់ខ្លួននៅក្នុងភូមិភាគកណ្ដាលគឺជា "ការខិតខំប្រឹងប្រែងមានអង្គការចាត់តាំងដែលរៀបចំដោយ [អោ អាន] និងអ្នកដឹកនាំដទៃទៀតរបស់បក្សកុម្មុយនីស្តកម្ពុជា" ក៏ប៉ុន្តែ ត្រូវបានអនុវត្តដោយ អោ អាន និងកម្មាភិបាលរបស់គាត់មកពីភូមិភាគនិរតី[85] ហើយថា ការចូលរួមរបស់ អោ អាន ក្នុងសហឧក្រិដ្ឋកម្មរួមថ្នាក់ជាតិ ត្រូវបានសម្របសម្រួលដោយថ្នាក់ដឹកនាំកម្រិតខ្ពស់បំផុតរបស់បក្សកុម្មុយនីស្តកម្ពុជា[86] ដោយសារ អោ អាន បានទទួលការណែនាំពី ប៉ុល ពត[87]។ សហមេធាវីអះអាងថា ដីកាដំណោះស្រាយ (ដីកាបញ្ជូនទៅជំនុំជម្រះ) លើកឡើងពីការចូលរួមរបស់ អោ អាន ទៅក្នុងការប្រព្រឹត្តិឧក្រិដ្ឋកម្មនៅភូមិភាគកណ្ដាល ក្នុងការពន្លឿនការសម្រេចផែនការឧក្រិដ្ឋកម្មនៅទូទាំងប្រទេសរបស់បក្សកុម្មុយនីស្តកម្ពុជា ដូចដែលដីកាដំណោះស្រាយ (ដីកាបញ្ជូនទៅជំនុំជម្រះ) បានសន្និដ្ឋានថា អោ អាន បានធ្វើការ "ចូលរួមចំណែកជាដុំកំភួន" ចំពោះគោលនយោបាយជាតិទាំងបួន[88] រួមទាំងការកំណត់គោលដៅលើក្រុមមនុស្សជាក់លាក់ជាច្រើន[89]។

48. ហេតុនេះ សហមេធាវីអះអាងថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិមានកំហុស ដោយផ្ដោតតែទៅលើឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តនៅក្នុងភូមិភាគកណ្ដាល ដើម្បីកំណត់អំពីភាពអាចទទួលស្គាល់ជាដើមបណ្ដឹងរដ្ឋប្បវេណី "ទោះបីមានការបង្ហាញយ៉ាងច្បាស់ប្រចក្សអំពី "លក្ខណៈរួម" នៃការទទួលខុសត្រូវរបស់ អោ អាន ក៏ដោយ"[90]។ ផ្ទុយទៅវិញ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ

[84] បណ្ដឹងឧទ្ធរណ៍របស់ដើមបណ្ដឹងរដ្ឋប្បវេណី (D362/5) កថាខណ្ឌ ២១។

[85] បណ្ដឹងឧទ្ធរណ៍របស់ដើមបណ្ដឹងរដ្ឋប្បវេណី (D362/5) កថាខណ្ឌ ២១ *យោងទៅ* ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទី ៣ (D1) កថាខណ្ឌ ៩០(ខ)។

[86] បណ្ដឹងឧទ្ធរណ៍របស់ដើមបណ្ដឹងរដ្ឋប្បវេណី (D362/5) កថាខណ្ឌ ២១។

[87] បណ្ដឹងឧទ្ធរណ៍របស់ដើមបណ្ដឹងរដ្ឋប្បវេណី (D362/5) កថាខណ្ឌ ២១ *យោងទៅ* ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (D360) កថាខណ្ឌ ៨២៥។

[88] បណ្ដឹងឧទ្ធរណ៍របស់ដើមបណ្ដឹងរដ្ឋប្បវេណី (D362/5) កថាខណ្ឌ ២២ *យោងទៅ* ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (D360) កថាខណ្ឌ ៨២៧-៨២៩, ៨៣១។

[89] បណ្ដឹងឧទ្ធរណ៍របស់ដើមបណ្ដឹងរដ្ឋប្បវេណី (D362/5) កថាខណ្ឌ ២៥ *យោងទៅ* ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (D360) កថាខណ្ឌ ២១៨។

[90] បណ្ដឹងឧទ្ធរណ៍របស់ដើមបណ្ដឹងរដ្ឋប្បវេណី (D362/5) កថាខណ្ឌ ២៦។

គួរតែបានពិចារណាទៅលើឧក្រិដ្ឋកម្មនានាដែលបានប្រព្រឹត្តនៅខាងក្រៅភូមិភាគកណ្ដាល នៅពេលដែលឧក្រិដ្ឋកម្មទាំងនោះបង្កើតជាផ្នែកនៃសហឧក្រិដ្ឋកម្មរួមថ្នាក់ជាតិ ដែល អោ អាន ត្រូវបានចោទប្រកាន់ថាបានចូលរួមនោះ[91]។ សហមេធាវីស្នើឲ្យអង្គបុរេជំនុំជម្រះទទួលយកម្ចាស់បណ្ដឹងឧទ្ធរណ៍ដែលបានទទួលរងព្យសនកម្ម ដែលជាផលវិបាកដោយផ្ទាល់ពីការអនុវត្តសហឧក្រិដ្ឋកម្មរួមថ្នាក់ជាតិនេះ[92]។

49. នៅក្រោមមូលដ្ឋានទី ១(ខ) សហមេធាវីជំទាស់ថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិមានកំហុសដោយដាក់កម្រិត លើការវិភាគអំពីភាពអាចទទួលយកបានរបស់គាត់ត្រឹមតែឧក្រិដ្ឋកម្មនៅក្នុងភូមិភាគកណ្ដាល ដោយយល់ឃើញថា ជនរងគ្រោះនៅខាងក្រៅភូមិភាគនេះគឺជាសមាជិកនៃក្រុម និងសហគមន៍ដែលត្រូវបានគេចាត់ទុកជាគោលដៅតែមួយ[93]។ សហមេធាវីអះអាងថា អង្គបុរេជំនុំជម្រះបានទទួលស្គាល់នូវ "ការសន្មតទុកជាមុនពីការខូចខាតជាសម្ងហភាព" នៅពេលឧក្រិដ្ឋកម្មឃោរឃៅទ្រង់ទ្រាយធំត្រូវបានចោទប្រកាន់ ហើយថា ការសន្មតទុកជាមុននេះលាតសន្ធឹងដល់សមាជិកនៃក្រុម និងសហគមន៍ដែលត្រូវបានគេចាត់ទុកជាគោលដៅតែមួយ ដោយបដិសេធនូវលក្ខខណ្ឌតម្រូវនៃភាពជិតគ្នាផ្នែករូបរាងកាយ[94]។ សហមេធាវីចោទប្រកាន់បន្ថែមថា ការគាំទ្រដល់ "ការខូតខាតជាសម្ងហភាព" របស់ អ.វ.ត.ក មានលក្ខណៈស្រដៀងគ្នាជាមួយការអនុវត្តជាអន្តរជាតិ[95] ដោយសារសញ្ញាណនេះត្រូវបានទទួលស្គាល់ដោយតុលាការព្រហ្មទណ្ឌអន្តរជាតិ

---

[91] បណ្ដឹងឧទ្ធរណ៍របស់ដើមបណ្ដឹងរដ្ឋប្បវេណី (D362/5) កថាខណ្ឌ ២៦។

[92] បណ្ដឹងឧទ្ធរណ៍របស់ដើមបណ្ដឹងរដ្ឋប្បវេណី (D362/5) កថាខណ្ឌ ២៧-២៨ (សហមេធាវីយោងទៅអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីដែលត្រូវបានបដិសេធ ដែលបានទទួលរងព្យសនកម្មជាផលវិបាកនៃគោលនយោបាយទាំងបួន ដែលត្រូវបានអនុវត្តដើម្បីពន្លឿនការអនុវត្តសហឧក្រិដ្ឋកម្មរួមថ្នាក់ជាតិ រួមមាន ឈុំ ហុន (13-VSS-00633) ជន ណាត (13-VSS-00316) កប ញ៉ែន (13-VSS-00477) អ៊ិន សុភាព (13-VSS-00193) និងម្ចាស់បណ្ដឹងឧទ្ធរណ៍ដែលត្រូវបានកំណត់អត្តសញ្ញានៅក្នុងឧបសម្ព័ន្ធ ង៖ ដើមបណ្ដឹងរដ្ឋប្បវេណីដែលបានទទួលរងព្យសនកម្មជាលទ្ធផលនៃការធ្វើទុក្ខបុកម្នេញចំពោះក្រុមដែលត្រូវបានចាត់ទុកជាគោលដៅ ឯកសារ D362/5.7 និង ឧបសម្ព័ន្ធ ច៖ អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីដែលបានទទួលរងព្យសនកម្មដោយសារគោលនយោបាយនៃសហឧក្រិដ្ឋកម្មរួម ឯកសារ D362/5.8។

[93] បណ្ដឹងឧទ្ធរណ៍របស់ដើមបណ្ដឹងរដ្ឋប្បវេណី (D362/5) កថាខណ្ឌ ២៩។

[94] បណ្ដឹងឧទ្ធរណ៍របស់ដើមបណ្ដឹងរដ្ឋប្បវេណី (D362/5) កថាខណ្ឌ ៣០ *យោងទៅ* សំណុំរឿង ០០២ សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់ដើមបណ្ដឹងរដ្ឋប្បវេណី (D404/2/4) កថាខណ្ឌ ៨៣-៩៣។

[95] បណ្ដឹងឧទ្ធរណ៍របស់ដើមបណ្ដឹងរដ្ឋប្បវេណី (D362/5) កថាខណ្ឌ ៣១។

("ICC")[96] គោលការណ៍ជាមូលដ្ឋានរបស់អង្គការសហប្រជាជាតិឆ្នាំ១៩៨៥ និងឆ្នាំ២០០៥[97] និងស្ថាប័នសិទ្ធិមនុស្សជាច្រើនទៀត ដូចជាគណៈកម្មការសិទ្ធិមនុស្ស និងសិទ្ធិប្រជាជនអាហ្វ្រិក និងតុលាការសិទ្ធិមនុស្សអន្តរទ្វីបអាមេរិក[98]។

50. សហមេធាវីចោទប្រកាន់ថា អោ អាន ទទួលខុសត្រូវក្នុងការកំណត់គោលដៅលើក្រុមជាក់លាក់នៅក្នុងភូមិភាគកណ្តាល[99] និងសូមរម្លឹកនូវការផ្តល់សំអាងហេតុរបស់អង្គបុរេជំនុំជម្រះថា "ការសន្មតជាមុនពីការខូចខាតជាសមូហភាព ដែលកើតចេញពីព្យសនកម្មដែលទទួលរងគ្រោះផ្ទាល់នៅក្នុងភូមិភាគកណ្តាល [...] លាតសន្ធឹងដល់សមាជិក*គ្រប់រូប*នៃក្រុមមនុស្ស ឬសហគមន៍គោលដៅជាក់លាក់ទាំងនេះ ដោយមិនគិតដល់ទីកន្លែងរបស់ពួកគេ"[100]។ ទោះបីសហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានទទួលស្គាល់ដោយចេតនានូវគោលការណ៍នៃព្យសនកម្មជាសមូហភាព

[96] បណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (D362/5) កថាខណ្ឌ ៣១ *យោងទៅ* តុលាការព្រហ្មទណ្ឌអន្តរជាតិ ("ICC") *រឿងក្តី រដ្ឋអាជ្ញា ទល់នឹង Thomas Lubanga Dyilo* អង្គជំនុំជម្រះសាលាឧទ្ធរណ៍ សំណុំរឿងលេខ ICC-01/04-01/06-1432 សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់រដ្ឋអាជ្ញា និងមេធាវីការពារក្តីប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង I លើការចូលរួមរបស់ជនរងគ្រោះថ្ងៃទី១៨ ខែមករា ឆ្នាំ២០០៨ ចុះថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០០៨ កថាខណ្ឌ ៣៥។

[97] បណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (D362/5) កថាខណ្ឌ ៣១ *ដកស្រង់ពី* គោលការណ៍ស្តីពីជនរងគ្រោះឆ្នាំ១៩៨៥ ឧបសម្ព័ន្ធ ក.១។ គោលការណ៍ស្តីពីជនរងគ្រោះឆ្នាំ២០០៥ បុព្វកថា។

[98] បណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (D362/5) កថាខណ្ឌ ៣១ *យោងទៅ* គណៈកម្មការសិទ្ធិមនុស្ស និងសិទ្ធិប្រជាជនអាហ្វ្រិក *មជ្ឈមណ្ឌលអភិវឌ្ឍន៍សិទ្ធិជនជាតិភាគតិច (កេនយ៉ា) និង ក្រុមសិទ្ធិជនជាតិភាគតិចអន្តរជាតិ តាងនាមឲ្យក្រុមប្រឹក្សាសុខុមាលភាពអង់ដូវស៉ែ ទល់នឹង ប្រទេសកេនយ៉ា* ឯកសារលេខ No. 276/03 ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០០៩ កថាខណ្ឌ ២៤៨។ គណៈកម្មាធិការសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ *យោបល់ទូទៅលេខ ២១៖ សិទ្ធិរបស់បុគ្គលគ្រប់រូបក្នុងការចូលរួមក្នុងជីវភាពខាងវប្បធម៌* សម័យប្រជុំលើកទី ៤៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០០៩ ឯកសារ អ.ស.ប លេខ E/C. 12/GC/21 កថាខណ្ឌ ៣៧។ តុលាការសិទ្ធិមនុស្សអន្តរទ្វីបអាមេរិក *ករណីជនជាតិភាគតិចគិច្ចវ៉ា (Kichwa) នៃអម្បូរ Sarayaku ទល់នឹងប្រទេសអេក្វាឌ័រ* សាលក្រម (អង្គសេចក្តី និងសំណង) ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១២ ស៊េរី គ លេខ ២៤៥ កថាខណ្ឌ ២៣១-២៣២, ២៨៤។

[99] បណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (D362/5) កថាខណ្ឌ ៣២ *យោងទៅ* ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (D360) កថាខណ្ឌ ២១៨។ ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទី ៣ (D1) កថាខណ្ឌ ៧, ១៦-១៧។ ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមលើកទី ១ (D65) កថាខណ្ឌ ២១។

[100] បណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (D362/5) កថាខណ្ឌ ៣២។

នៅក្នុងដីកាដំណោះស្រាយក្ដី តែគាត់ "ដាក់លក្ខខណ្ឌដែលមានកំហុសថា សមាជិកដែលរស់នៅក្នុងក្រុម ឬសហគមន៍គោលដៅតែមួយ ត្រូវមានទីតាំងស្ថិតនៅក្នុងភូមិភាគកណ្ដាល [...]"[101]។

51. សហមេធាវីស្នើសុំឱ្យអង្គបុរេជំនុំជម្រះធ្វើការបដិសេធដីកាដែលរងការជំទាស់ និងទទួលយកម្ចាស់បណ្ដឹងឧទ្ធរណ៍ដែលបានផ្ដល់ព័ត៌មានគ្រប់គ្រាន់ដើម្បីបង្ហាញថា ពួកគាត់ជាសមាជិកនៅក្នុងក្រុមដែលត្រូវបានចាត់ទុកជាគោលដៅជាក់លាក់មួយឬច្រើន ឬសហគមន៍ដែលត្រូវបានកំណត់អត្តសញ្ញាណ នៅក្នុងដីកាដំណោះស្រាយ (ដីកាបញ្ជូនទៅជំនុំជម្រះ) ជាដើមបណ្ដឹងរដ្ឋប្បវេណី[102]។

## ២. *ការពិភាក្សា*

52. អង្គបុរេជំនុំជម្រះយល់ឃើញថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិមិនមានកំហុស ដោយកំណត់អត្តសញ្ញាណត្រឹមតែឧក្រិដ្ឋកម្មនានាដែលបានចោទប្រកាន់ថាបានប្រព្រឹត្តនៅក្នុងភូមិភាគកណ្ដាល ថាជាប់ពាក់ព័ន្ធនឹងលក្ខខណ្ឌចាំបាច់នៃទំនាក់ទំនងហេតុនិងផល អនុលោមតាមវិធាន ២៣*ស្ទួន* (១)(ខ) នៃវិធានផ្ទៃក្នុងនោះទេ។ ទីមួយ អង្គបុរេជំនុំជម្រះសង្កេតឃើញថា ដីកាដែលរងការជំទាស់កម្រិតយ៉ាងត្រឹមត្រូវនូវការពិនិត្យ ទៅលើអ្នកដាក់ពាក្យសុំដែលអាចទទួលស្គាល់ជាដើមបណ្ដឹងរដ្ឋប្បវេណីពាក់ព័ន្ធនឹងភូមិភាគកណ្ដាល[103]។ ទីពីរ ដីកាដែលរងការជំទាស់បកស្រាយ និងអនុវត្ត

---

[101] បណ្ដឹងឧទ្ធរណ៍របស់ដើមបណ្ដឹងរដ្ឋប្បវេណី (D362/5) កថាខណ្ឌ ៣៣។

[102] បណ្ដឹងឧទ្ធរណ៍របស់ដើមបណ្ដឹងរដ្ឋប្បវេណី (D362/5) កថាខណ្ឌ ៣៤-៣៥ (សហមេធាវីយោងទៅអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីដែលត្រូវបានបដិសេធ ដែលបានទទួលរងព្យសនកម្មជាផលវិបាកដោយសារជាសមាជិកនៃក្រុម ឬសហគមន៍ដែលត្រូវបានចាត់ទុកជាគោលដៅ រួមមាន វ៉ែន វ៉ន (11-VSS-00276) ជិន សុខុម (13-VSS-00647) អែល ម៉ើ (13-VSS-00403) ម៉ាន ស្លេះ (16-VSS-00015) ខៀវ នី (13-VSS-00610) សុន ឯម (14-VSS-00170) តន់ សុខ (11-VSS-00120) ហាស់ ដា (11-VSS-00224) ប៊ុន សារិន (15-VSS-00063) ស្វាយ ណេត (14-VSS-00196) សៅ គិមសៀង (16-VSS-00077) ខេនវន ឡេងស្វូ (11-VSS-00319) ឡុង ផាង (11-VSS-00182) ហឿង សុវណ្ណា (13-VSS-00389) ឆាយ យ៉ាន (15-VSS-00022) និងម្ចាស់បណ្ដឹងឧទ្ធរណ៍ដែលត្រូវបានកំណត់អត្តសញ្ញាណនៅក្នុង ឧបសម្ព័ន្ធ ង៖ ដើមបណ្ដឹងរដ្ឋប្បវេណីដែលបានទទួលរងព្យសនកម្មជាលទ្ធផលនៃការធ្វើទុក្ខបុកម្នេញចំពោះក្រុមដែលត្រូវបានចាត់ទុកជាគោលដៅ ឯកសារ D362/5.7)។

[103] ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) កថាខណ្ឌ ៨២៤។ ដីកាសម្រេចលើដើមបណ្ដឹងរដ្ឋប្បវេណី (អន្តរជាតិ) (D362) កថាខណ្ឌ ៣៧។

01647485



យ៉ាងត្រឹមត្រូវនូវសញ្ញាណនៃការខូចខាតសម្ភារភាព ទាក់ទិននឹងជនរងគ្រោះដោយប្រយោលដែលបានទទួលរងការខូចខាត ជាលទ្ធផលនៃឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់ថាបានប្រព្រឹត្តប្រឆាំងនឹងជនរងគ្រោះផ្ទាល់នៅក្នុងភូមិភាគកណ្តាល[104]។

## *ក. ច្បាប់ជាធរមាន*

53. ស្តីអំពីគោលបំណងនៃបណ្តឹងសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី វិធាន ២៣(១) នៃវិធានផ្ទៃក្នុងចែងថា៖

> គោលបំណងនៃបណ្តឹងសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅចំពោះមុខ អ.វ.ត.ក គឺដើម្បី៖
>
> ក-ចូលរួមក្នុងដំណើរការនីតិវិធីព្រហ្មទណ្ឌ ប្រឆាំងនឹងអ្នកដែលទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មនៅក្នុងយុត្តាធិការរបស់ អ.វ.ត.ក ដោយគាំទ្រដល់ការចោទប្រកាន់ ។ និង
> ខ-ទាមទារសំណងផ្លូវចិត្ត និងសម្ភារភាព ដូចមានចែងក្នុងវិធាន ២៣ *ស្ទួនបួន* ។

54. ឆ្លើយតបទៅនឹងពាក្យសុំ និងការទទួលស្គាល់ជាដើមបណ្តឹងរដ្ឋប្បវេណី វិធាន ២៣*ស្ទួន*(១) នៃវិធានផ្ទៃក្នុងចែងថា៖

> ដើម្បីឱ្យពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីអាចទទួលយកបាន អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីត្រូវ៖
>
> ក - បង្ហាញពីអត្តសញ្ញាណអោយបានច្បាស់លាស់ និង
>
> ខ - បង្ហាញជាលទ្ធផលដោយផ្ទាល់ពីបទឧក្រិដ្ឋ យ៉ាងហោចណាស់មួយនៃបទឧក្រិដ្ឋជាច្រើន ដែលត្រូវបានចោទប្រកាន់លើជនត្រូវចោទ ថាខ្លួនពិតជាបានទទួលរងនូវព្យសនកម្មខាងរូបរាងកាយ ខាងសម្ភារៈ ឬ ផ្លូវចិត្ត ដែលអាចជាមូលដ្ឋានសម្រាប់ការទាមទារសំណងផ្លូវចិត្ត និងសម្ភារភាព។ នៅពេលពិចារណាអំពីភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី សហចៅក្រមស៊ើបអង្កេតត្រូវតែមានជំនឿថា អង្គហេតុដែលគាំទ្រដល់ការដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនោះមានភាពពិតប្រាកដ។

[104] ដីកាសម្រេចលើដើមបណ្តឹងរដ្ឋប្បវេណី (អន្តរជាតិ) (D362) កថាខណ្ឌ ៣២-៣៥។

## ខ. មូលដ្ឋានទី ១(ក)

55. ដីកាដែលរងការជំទាស់មិនមានកំហុសក្នុងការកម្រិតនូវវិសាលភាពភូមិសាស្ត្រ ត្រឹមតែភូមិភាគកណ្តាលនោះទេ ហើយអង្គជំនុំជម្រះពិចារណាឃើញថា ការពង្រីកបណ្តឹងសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ប្រឆាំងនឹងជនជាប់ចោទហួសពីឧក្រិដ្ឋកម្មដែលបានចោទប្រកាន់នៅក្នុងភូមិភាគកណ្តាល គឺជារឿងមិនត្រឹមត្រូវ និងមិនយុត្តិធម៌ទេ ដែលបង្វែរចេញពីលក្ខខណ្ឌតម្រូវពីទំនាក់ទំនងអនុលោមតាមវិធាន ២៣*ស្ទួន* នៃវិធានផ្ទៃក្នុង ដែលមានសារសំខាន់ក្នុងការទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី។

56. វិធាន ២៣*ស្ទួន*(១)(ខ) នៃវិធានផ្ទៃក្នុងពាក់ព័ន្ធនឹងការទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី និងចែងថា អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីត្រូវ "បង្ហាញជាលទ្ធផលដោយផ្ទាល់ពីបទឧក្រិដ្ឋ យ៉ាងហោចណាស់មួយនៃបទឧក្រិដ្ឋជាច្រើន ដែលត្រូវបានចោទប្រកាន់លើជនត្រូវចោទ ថាខ្លួនពិតជាបានទទួលរងនូវព្យសនកម្មខាងរូបរាងកាយ ខាងសម្ភារៈ ឬ ផ្លូវចិត្ត"[105]។ អង្គជំនុំជម្រះសង្កេតឃើញថា វិធានផ្ទៃក្នុងនេះតម្រូវឱ្យទំនាក់ទំនងរវាង "បទឧក្រិដ្ឋដែលត្រូវបានចោទប្រកាន់" និង "ព្យសនកម្ម" ដែលអ្នកដាក់ពាក្យសុំបានទទួលរង[106]។ អង្គបុរេជំនុំជម្រះធ្លាប់បានសន្និដ្ឋានថា ទោះបី "វិធាន ២៣*ស្ទួន*(១)(ខ) នៃវិធានផ្ទៃក្នុងមិនបានទាមទារឱ្យមានទំនាក់ទំនងហេតុផលរវាងព្យសនកម្ម និងឧក្រិដ្ឋកម្មណាមួយដែលបានស៊ើបអង្កេតនោះឡើយ គឺវាតម្រូវឱ្យមានទំនាក់ទំនងហេតុនិងផល រវាងព្យសនកម្មនិង*ឧក្រិដ្ឋកម្មណាមួយដែលបានចោទប្រកាន់ប៉ុណ្ណោះ*"[107]។ ហេតុនេះព្យសនកម្មដែលអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីបានទទួលរង ត្រូវតែមានទំនាក់ទំនងទៅនឹងឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់នៅក្នុងដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ដើម្បីអាចយកមកពិចារណាពីភាពអាចទទួលយកបាននៅដំណាក់កាលនៃកិច្ចដំណើរការនីតិវិធី។

---

[105] វិធាន ២៣*ស្ទួន*(១)(ខ) នៃវិធានផ្ទៃក្នុង។

[106] វិធាន ២៣*ស្ទួន*(១)(ខ) នៃវិធានផ្ទៃក្នុង។ *សូមមើលផងដែរ* សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (D404/2/4) កថាខណ្ឌ ៤២។ សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (D411/3/6) កថាខណ្ឌ ៤២។

[107] សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (D404/2/4) កថាខណ្ឌ ៤២, ៧១។ សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (D411/3/6) កថាខណ្ឌ ៤២, ៧១។

57. អត្ថន័យនៃវិធាន ២៣*ស្ទួន*(១)(ខ) នៃវិធានផ្ទៃក្នុង ត្រូវបានយកមកបញ្ជាក់បន្ថែមទៀតដោយអង្គបុរេជំនុំជម្រះ។ ទោះបីអង្គបុរេជំនុំជម្រះកត់សម្គាល់ពីយោបល់ជំទាស់ជាក់ស្តែងមួយផ្នែកនៅក្នុងសំណុំរឿង ០០២ ក្តី[108] តែអង្គជំនុំជម្រះសង្កេតឃើញថា៖ "អង្គបុរេជំនុំជម្រះពិចារណាថា វត្ថុបំណង និងគោលបំណងនៃវិធាន ២៣*ស្ទួន*(១) នៃវិធានផ្ទៃក្នុង មិនមែនបង្កើតឡើងសម្រាប់រឹតបន្តឹង ឬកំណត់ទៅលើសកម្មភាពរបស់ជនរងគ្រោះ ឬសកម្មភាពរបស់ដើមបណ្តឹងរដ្ឋប្បវេណីនៅ អ.វ.ត.ក នោះទេ។ ប៉ុន្តែវិធាននេះ បង្កើតឡើងសម្រាប់កំណត់លក្ខណៈវិនិច្ឆ័យក្នុងការទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី"[109]។ នៅក្នុងបរិបទនៃសំណុំរឿង ០០២ ដែលមានជនជាប់ចោទច្រើននាក់ត្រូវបានឆ្លើយដាក់នោះ អង្គជំនុំជម្រះបានសង្កេតឃើញថា ទោះបី "អង្គហេតុដែលត្រូវស៊ើបអង្កេតកំណត់ត្រឹមតែទៅលើតំបន់ ឬទីតាំងឧក្រិដ្ឋកម្មមួយចំនួនក៏ដោយ ក៏ការកំណត់បទចោទនៃអង្គហេតុទាំងនេះ [...] រួមបញ្ចូលនូវឧក្រិដ្ឋកម្ម [...] ជនត្រូវចោទបានធ្វើឡើងរួមគ្នា ក្នុងពេលអនុវត្តសហឧក្រិដ្ឋកម្ម ព្រមទាំងរួមបញ្ចូលឧក្រិដ្ឋកម្មដទៃទៀតដែលបានធ្វើឡើងប្រឆាំងប្រជាជន និង *"នៅទូទាំងប្រទេស"*"[110]។ ដូចបានកត់សម្គាល់គឺថា "ជនរងគ្រោះនៅចំពោះមុខ អ.វ.ត.ក ជាពិសេសក្នុងសំណុំរឿង ០០២ គឺស្ថិតក្នុងស្ថានភាពខុសគ្នា ពីជនរងគ្រោះនៅចំពោះមុខតុលាការក្នុងស្រុក និងសូម្បីតែជនរងគ្រោះនៅ អ.វ.ត.ក ក្នុងសំណុំរឿង ០០១ ក៏មានស្ថានភាពខុសគ្នាដែរ"[111]។ ហេតុនេះ នៅក្នុងសំណុំរឿង ០០២ អង្គជំនុំជម្រះបានសម្រេចថា អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីមិនចាំបាច់ត្រូវតែភ្ជាប់ទំនាក់ទំនងរវាងព្យសនកម្មរបស់ខ្លួន ទៅនឹងទីតាំងឧក្រិដ្ឋកម្មនានាដែលបានកំណត់អត្តសញ្ញាណនៅក្នុងដីកាដំណោះស្រាយទេ "ដោយសារឧក្រិដ្ឋកម្ម និងគោលនយោបាយបក្សកុម្មុយនីស្តជាមូលដ្ឋានបង្កើតជាមូលដ្ឋាននៃការ

---

[108] សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (D404/2/4) មតិយោបល់ [ជំទាស់] របស់ចៅក្រម Catherine MARCHI-UHEL កថាខណ្ឌ ៣-៥។

[109] សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (D404/2/4) កថាខណ្ឌ ៦២។ សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (D411/3/6) កថាខណ្ឌ ៦២។

[110] សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (D404/2/4) កថាខណ្ឌ ៤២។ សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (D411/3/6) កថាខណ្ឌ ៤២។

[111] សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (D404/2/4) កថាខណ្ឌ ៦៩។ សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (D411/3/6) កថាខណ្ឌ ៦៩។

01647488



ចោទប្រកាន់ដែលត្រូវបានប្រព្រឹត្តនៅទូទាំងប្រទេសកម្ពុជាទាំងមូល"[112] ដោយមានបទល្មើសនានា "រួមមាន ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ការបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវថ្ងៃទី១២ ខែសីហា ឆ្នាំ១៩៤៩ និងការរំលោភបំពានដល់ក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦"[113]។

58. នៅក្នុងករណីនេះ ទោះបីសហមេធាវីលើកយោងយ៉ាងទូលំទូលាយទៅសេចក្តីសម្រេចពីមុនៗរបស់អង្គជំនុំជម្រះក្នុងសំណុំរឿង ០០២ ក្តី[114] តែអង្គបុរេជំនុំជម្រះយល់ឃើញថា ទឡ្ហីករណ៍ទាំងនោះមិនទទួលជោគជ័យទេ។ អង្គបុរេជំនុំជម្រះមិនជឿថា កាលៈទេសៈនានាដែលអង្គបុរេជំនុំជម្រះបានបង្ហាញនៅក្នុងសំណុំរឿង ០០២ មានអានុភាពអនុវត្តនៅក្នុងករណីនេះទេ។ អង្គជំនុំជម្រះសង្កេតឃើញថា ជនជាប់ចោទជាច្រើននាក់នៅក្នុងសំណុំរឿង ០០២ ត្រូវបានចោទប្រកាន់បញ្ជូនទៅជំនុំជម្រះពីឧក្រិដ្ឋកម្មនានាដែលបានប្រព្រឹត្ត*ទូទាំង*ប្រទេសកម្ពុជា[115]។ ផ្ទុយពីសំណុំរឿង ០០២ អោ អាន ត្រូវបានចោទប្រកាន់បញ្ជូនទៅជំនុំជម្រះចំពោះឧក្រិដ្ឋកម្មដែលត្រូវបានប្រព្រឹត្តនៅក្នុង*ភូមិភាគកណ្តាល*តែមួយគត់[116] ដោយដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) បានកំណត់និយមន័យ និងកម្រិតច្បាស់លាស់អំពីវិសាលភាពភូមិសាស្ត្រដូចតទៅ៖ "ចាប់តាំងពីចុងឆ្នាំ១៩៧៦ ឬដើមឆ្នាំ១៩៧៧ និងរហូតដល់យ៉ាងហោចណាស់ថ្ងៃ ៦ មករា ឆ្នាំ១៩៧៩ កែ ពក, អោ អាន និងកម្មាភិបាលផ្សេងៗទៀតនៃបក្សកុម្មុយនីស្តកម្ពុជា មានគោលបំណងរួមក្នុងការអនុវត្តគោលនយោបាយទាំងបួនរបស់បក្សកុម្មុយនីស្តកម្ពុជា *នៅក្នុងភូមិភាគកណ្តាលនៃកម្ពុជាប្រជាធិបតេយ្យ*"[117]។

---

[112] សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (D404/2/4) កថាខណ្ឌ ៧២។ សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (D411/3/6) កថាខណ្ឌ ៧២។

[113] សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (D404/2/4) កថាខណ្ឌ ៧១។ សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (D411/3/6) កថាខណ្ឌ ៧១។

[114] បណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (D362/5) កថាខណ្ឌ ១៩-២០។

[115] *សូមមើលឧទាហរណ៍* សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (D404/2/4) កថាខណ្ឌ ៧៤-៧៥។ សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (D411/3/6) កថាខណ្ឌ ៧៤-៧៥។

[116] ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (D360) កថាខណ្ឌ ៧២០-៨៥១។

[117] ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (D360) កថាខណ្ឌ ៨២៤ (គូសបញ្ជាក់បន្ថែម)។

59. ជាងនេះទៀត សហមេធាវីជំទាស់ថា ដើមបណ្ដឹងរដ្ឋប្បវេណីនៅទូទាំងប្រទេសកម្ពុជាគួរត្រូវបានទទួលស្គាល់ និងបានលើកយោងម្ដងហើយម្ដងទៀតទៅដល់ការចោទប្រកាន់ដែលបានធ្វើឡើងនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទី ៣ និង ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម ដើម្បីគាំទ្រដល់ការអះអាងនេះ[118]។ អង្គជំនុំជម្រះពិចារណាឃើញថា នៅដំណាក់កាលនេះនៃកិច្ចដំណើរការនីតិវិធី ដែលដីកាដំណោះស្រាយបានចេញរួចទៅហើយនោះ ឯកសារដែលមានអំណាចអាជ្ញាបញ្ញាគឺដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) មិនមែនដីកាពីមុនៗដែលចេញដោយការិយាល័យសហព្រះរាជអាជ្ញានោះឡើយ[119]។ នៅក្នុងន័យនេះ អង្គបុរេជំនុំជម្រះពិចារណាឃើញថា អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីត្រូវបង្ហាញចំណងទាក់ទងហេតុនិងផល ទៅនឹងឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់ ហើយមិនមែនចំពោះ "(១) វិសាលភាពទូលំទូលាយនៃកិច្ចស៊ើបសួរ (២) អង្គហេតុដែលត្រូវបានបើកការស៊ើបអង្កេតរួចហើយ ឬ (៣) អង្គហេតុដែលស្ថិតនៅក្រោមកិច្ចស៊ើបសួរនោះទេ"[120]។ អង្គជំនុំជម្រះសង្កេតឃើញថា ការពិត ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទី ៣ ចោទប្រកាន់អំពីបទឧក្រិដ្ឋដែលត្រូវបានកម្រិតនៅក្នុងវិសាលភាពភូមិសាស្ត្រត្រឹមតែភូមិភាគកណ្ដាលប៉ុណ្ណោះ[121]។ ជាងនេះទៀត សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានពន្យល់ថា គាត់មិនចាត់ទុកខ្លួនឯងថាបានទទួលពិចារណាដោយ

---

[118] បណ្ដឹងឧទ្ធរណ៍របស់ដើមបណ្ដឹងរដ្ឋប្បវេណី (D362/5) កថាខណ្ឌ ២១-២៥។

[119] *សូមមើលឧទាហរណ៍* វិធាន ៦៧(១) នៃវិធានផ្ទៃក្នុង ("សហចៅក្រមស៊ើបអង្កេតត្រូវបញ្ចប់កិច្ចស៊ើបសួរ ដោយចេញដីកាដំណោះស្រាយថាត្រូវចោទប្រកាន់ និងបញ្ជូនជនត្រូវចោទទៅជំនុំជម្រះ ឬលើកលែងការចោទប្រកាន់។ ដីកាសន្និដ្ឋានរបស់សហព្រះរាជអាជ្ញាមិនចងសហចៅក្រមស៊ើបអង្កេតឡើយ")។

[120] *ប្រៀបធៀប* សំណុំរឿង ០០២ សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់ដើមបណ្ដឹងរដ្ឋប្បវេណី (D404/2/4) មតិយោបល់ [ជំទាស់] របស់ចៅក្រម Catherine MARCHI-UHEL កថាខណ្ឌ ៣៥។

[121] ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទី ៣ (D1) កថាខណ្ឌ ១៦ ("[សហឧក្រិដ្ឋកម្មរួម] ចាប់ផ្ដើមកើតមានយ៉ាងហោចណាស់ចាប់តាំងពីខែកុម្ភៈ ឆ្នាំ១៩៧៧ រហូតដល់ចុងបញ្ចប់នៃរបបកម្ពុជាប្រជាធិបតេយ្យ ដែលរួមមាន តាអាន សមាជិកគណៈភូមិភាគ និងតំបន់របស់គាត់ ព្រមទាំងអ្នកក្រោមបង្គាប់ដែលមកពីភូមិភាគនិរតី។ កម្មវត្ថុរបស់សហឧក្រិដ្ឋកម្មរួមគឺត្រូវបោសសម្អាតនៅភូមិភាគកណ្ដាល [...] និងសម្លាប់រាល់ខ្មាំងរបស់របបកម្ពុជាប្រជាធិបតេយ្យនៅក្នុងភូមិភាគនោះ")។ *សូមមើលផងដែរ* សំណុំរឿង ០០៤ សំណើសុំសេចក្ដីអធិប្បាយ (D307) កថាខណ្ឌ ៣ អង្គហេតុ ៨ (សហចៅក្រមស៊ើបអង្កេតអន្តរជាតិសង្កេតឃើញថា៖ "[ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទី ៣] ចោទប្រកាន់ពីសហឧក្រិដ្ឋកម្មរួមដែលត្រូវបានកំហិតផ្នែកទីតាំងភូមិសាស្ត្រត្រឹមភូមិភាគកណ្ដាល៖ ហេតុនេះ ឧក្រិដ្ឋកម្មដែលត្រូវបានប្រព្រឹត្តនៅភូមិភាគពាយ័ព្យ និងភូមិភាគនិរតី ពុំស្ថិតក្នុងវិសាលភាពរបស់វាឡើយ")។

ផ្ទាល់នូវសេណារីយ៉ូឧក្រិដ្ឋកម្មនានា ដែលត្រូវបានចោទប្រកាន់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមលើកទី ១ ទាក់ទិននឹង អោ អាន ឡើយ[122] ដែលសហព្រះរាជអាជ្ញាអន្តរជាតិបានយល់ស្រប[123]។

60. យោងតាមវិធាន ២៣(១) អង្គបុរេជំនុំជម្រះសូមរម្លឹកថា "គោលបំណងនៃបណ្តឹងតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញគឺដើម្បី៖ ក- ចូលរួមក្នុងដំណើរការនីតិវិធីព្រហ្មទណ្ឌ ប្រឆាំងនឹងអ្នកដែលទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មនៅក្នុងយុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញ ដោយគាំទ្រដល់ការចោទប្រកាន់"។ តាមការសន្និដ្ឋានដ៏សមហេតុសមផលនៅក្នុងកិច្ចដំណើរការនីតិវិធីដំណាក់កាលនេះ ដើម្បីអាចទទួលយកជាដើមបណ្តឹងរដ្ឋប្បវេណី អ្នក

[122] សំណុំរឿង ០០៤ សំណើសុំសេចក្តីអធិប្បាយ (D307) កថាខណ្ឌ ៣ អង្គហេតុ ៨ ("ការទទួលខុសត្រូវរបស់ អោ អាន ចំពោះសេណារីយ៉ូឧក្រិដ្ឋកម្មទាំងអស់ដែលត្រូវបានចោទក្នុង [ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមលើកទី ១] – យើងពុំចាត់ទុកខ្លួនឯងថា បានទទួលពិចារណាដោយផ្ទាល់អំពីអង្គហេតុ ៨ [...] ដោយហេតុផលមួយចំនួន៖ ការចោទប្រកាន់នៅក្នុង [ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមលើកទី ១] គឺកំហិតផ្នែកភូមិសាស្ត្រត្រឹមភូមិភាគពាយ័ព្យ និងនិរតី។ ឧក្រិដ្ឋកម្មទាំងប៉ុន្មានដែលត្រូវបានចោទប្រកាន់ដោយ [ការិយាល័យសហព្រះរាជអាជ្ញា] ត្រូវបានរៀបរាប់នៅក្នុងកថាខណ្ឌ ៥ ដល់ ២០ នៃ [ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមលើកទី ១]។ ក្នុងការរៀបរាប់នេះ ពុំមានការលើកឡើងអំពីតួនាទីណាមួយដែលអាចជារបស់ អោ អាន ក្នុងការប្រព្រឹត្តិឧក្រិដ្ឋកម្ម ដែលត្រូវបានចោទប្រកាន់។ អោ អាន ត្រូវបានលើកឡើងក្នុងកថាខណ្ឌ ២៣ តែមួយប៉ុណ្ណោះ ដែលគាត់ត្រូវបានចោទប្រកាន់ថាបានប្រព្រឹត្ត *ក្នុងចំណោមប្រការផ្សេងៗ* នូវឧក្រិដ្ឋកម្មដែលត្រូវបានរៀបរាប់ក្នុង [ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមលើកទី ១] តាមរយៈការចូលរួមរបស់គាត់ក្នុងសហឧក្រិដ្ឋកម្មរួម ដូចដែលបានរៀបរាប់ក្នុងកថាខណ្ឌ ២១ នៃ [ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមលើកទី ១] និងកថាខណ្ឌ ១៦ នៃ [ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទី ៣]។ [...] ពាក់ព័ន្ធនឹងកថាខណ្ឌ ២១ នៃ [ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមលើកទី ១] វាពិពណ៌នាអំពីសហឧក្រិដ្ឋកម្មរួមនៅទូទាំងប្រទេស។ ប៉ុន្តែការចោទប្រកាន់អំពីសមាជិកភាពរបស់ អោ អាន នៃសហឧក្រិដ្ឋកម្មរួម មានលក្ខណៈទូទៅណាស់ ហើយការចោទប្រកាន់ផ្សេងទៀតដោយ [ការិយាល័យសហព្រះរាជអាជ្ញា] នៅក្នុងដីកាសន្និដ្ឋានទាំងនេះ ពុំផ្តល់ពន្លឺបន្ថែមស្តីពី សមាជិកភាពដែលត្រូវបានចោទប្រកាន់របស់ អោ អាន ក្នុងសហឧក្រិដ្ឋកម្មរួមនៅទូទាំងប្រទេសនេះឡើយ។ គ្មានការចោទប្រកាន់អំពីបទល្មើសជាក់លាក់នូវអង្គហេតុទាក់ទង អោ អាន ឡើយ")។

[123] សំណុំរឿង ០០៤ ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងសំណើរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិសុំឱ្យផ្តល់យោបល់ទាក់ទងនឹងអង្គហេតុនានាដែលបានចោទប្រកាន់មិនចាំបាច់ស៊ើបសួរបន្ថែម ចុះថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០១៦ ឯកសារ D307/2 កថាខណ្ឌ ៣(៤), ២៤ ("[សហព្រះរាជអាជ្ញាអន្តរជាតិ] យល់ស្របថា [សហចៅក្រមស៊ើបអង្កេតអន្តរជាតិ] មិនត្រូវបានប្តឹងដោយផ្ទាល់ចំពោះអង្គហេតុទី ៨ ទាក់ទងនឹង អោ អាន ទេ")។

ដាក់ពាក្យសុំត្រូវបង្ហាញថា ខ្លួនបានទទួលផលវិបាកដោយផ្ទាល់ពីបទល្មើសយ៉ាងហោចណាស់មួយ ដែល បានចោទប្រកាន់ថា ខ្លួនពិតជាបានទទួលរងព្យសនកម្មផ្លូវកាយ សម្ភារៈ ឬ ផ្លូវចិត្ត ជាមូលដ្ឋាននៃការទាមទារសំណងផ្លូវចិត្ត និងសំណងជាសមូហភាព[124]។

61. អង្គបុរេជំនុំជម្រះសង្កេតឃើញថា ដីកាដែលត្រូវបានជំទាស់កម្រិតយ៉ាងសមស្របនូវវិសាលភាព នៃអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដែលអាចទទួលយកបានត្រឹមអ្នក "ទទួលរងព្យសនកម្មនៅក្នុងភូមិភាគកណ្តាល ចាប់តាំងពេលប្រហែលជានៅចុងឆ្នាំ១៩៧៦ ដល់ ថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៩" ស្របតាមដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) [125]។ ផ្ទុយពីការចោទប្រកាន់របស់សហមេធាវី[126] អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីបានទទួលរងព្យសនកម្ម ដែលពុំកើតចេញពីឧក្រិដ្ឋកម្មដូចបានចោទប្រកាន់នៅក្នុងភូមិភាគកណ្តាល ពុំបំពេញលក្ខខណ្ឌទំនាក់ទំនងហេតុ និងផល អនុលោមតាមវិធាន ២៣*ស្ទួន*(១)(ខ) នោះទេ។

62. ចំណុចចុងក្រោយ អង្គបុរេជំនុំជម្រះពិចារណាឃើញថា អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីដែលមិនអាចទទួលយកបានភាគច្រើន បង្ហាញនៅក្នុងសេចក្តីសន្និដ្ឋានរបស់សហមេធាវី និងអ្នកមានឈ្មោះនៅក្នុងឧបសម្ព័ន្ធ ង (ក្រុមគោលដៅ)[127] និងឧបសម្ព័ន្ធ ច (ជនរងគ្រោះនៅទូទាំងប្រទេសកម្ពុជា)[128] អាចទទួលរងពីអំពើសាហាវឃោរឃៅទ្រង់ទ្រាយធំ កើតឡើងនៅក្នុងអំឡុងពេលនៃរបបខ្មែរក្រហម។ ទោះបីជាយ៉ាងនេះក្តី អង្គបុរេជំនុំជម្រះយល់ឃើញថា ព្រឹត្តិការណ៍ដែលបានពិពណ៌នាពុំមែនជាឧក្រិដ្ឋកម្មដូចបានចោទប្រកាន់នៅក្នុងសំណុំរឿង ០០៤/២ ដូចបានកំណត់នៅក្នុងដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) នោះទេ។ ហេតុនេះ សហចៅក្រមស៊ើបអង្កេតអន្តរជាតិពុំមានកំហុសអង្គច្បាប់ឡើយ នៅពេលពិចារណាតែទៅលើជនរងគ្រោះនៃឧក្រិដ្ឋកម្មនៅភូមិភាគកណ្តាល ឬ នៅពេលច្រានចោលអ្នកដាក់ពាក្យសុំដែលមាន

---

[124] វិធាន ២៣*ស្ទួន*(១)(ខ)។

[125] ដីកាសម្រេចស្តីពីដើមបណ្តឹងរដ្ឋប្បវេណី (អន្តរជាតិ) (ឯកសារ D362) កថាខណ្ឌ ៣៧ (ការគូសបញ្ជាក់បន្ថែម)។

[126] បណ្តឹងឧទ្ធរណ៍ពាក់ព័ន្ធករណីដើមបណ្តឹងរដ្ឋប្បវេណី (អន្តរជាតិ) (ឯកសារ D362) កថាខណ្ឌ ១៧-២១ កថាខណ្ឌ ២៦។

[127] ឧបសម្ព័ន្ធ ង៖ ដើមបណ្តឹងរដ្ឋប្បវេណីដែលរងព្យសនកម្មដោយសារលទ្ធផលនៃការធ្វើទុក្ខបុកម្នេញលើក្រុមគោលដៅ ឯកសារ D362/5.7។

[128] ឧបសម្ព័ន្ធ ច៖ ដើមបណ្តឹងរដ្ឋប្បវេណីដែលរងព្យសនកម្មដោយសារគោលនយោបាយនៃសហឧក្រិដ្ឋកម្មរួម ឯកសារ D362/5.8។

ឈ្មោះនៅក្នុងឧបសម្ព័ន្ធ ង និង ច ដែលពុំជាប់ទាក់ទងនឹងឧក្រិដ្ឋកម្មដូចបានចោទប្រកាន់នៅក្នុងភូមិភាគនេះ[129]។ អាស្រ័យហេតុនេះ មូលដ្ឋានទី១(ក) ត្រូវបានច្រានចោល។

### *គ. មូលដ្ឋានទី១(ខ)*

63. អនុលោមតាមវិធាន ២៣*ស្ទួន*(១)(ខ) អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីត្រូវ "បង្ហាញ [...] ថា ខ្លួនពិតជាបានទទួលរងនូវព្យសនកម្មខាងរូបកាយ ខាងសម្ភារៈ ឬ ផ្លូវចិត្ត"[130]។ នៅក្នុងសំណុំរឿង ០០២ អង្គបុរេជំនុំជម្រះបានពិចារណាលើលក្ខណៈ និងវិសាលភាពនៃព្យសនកម្មផ្លូវចិត្ត ដែលបានទទួលរងនៅក្នុងបរិបទនៃអំពើសាហាវឃោរឃៅទ្រង់ទ្រាយធំ ប្រព្រឹត្តឡើងនៅទូទាំងប្រទេសកម្ពុជា[131] ហើយបានពង្រីកសច្ចធារណ៍នៃព្យសនកម្មផ្លូវចិត្តរហូតដល់ជនរងគ្រោះប្រយោល ដែលពុំមានទំនាក់ទំនងគ្រួសារជាមួយនឹងជនរងគ្រោះផ្ទាល់ ប៉ុន្តែ ដែលជាផ្នែកមួយនៃក្រុមគោលដៅតែមួយ[132]។ អង្គបុរេជំនុំជម្រះបានសង្កេតឃើញថា៖

> ការត្រឹមតែដឹងពីជោគវាសនារបស់មនុស្សណាម្នាក់ ដែលជាជនរងគ្រោះផ្ទាល់ពីបទឧក្រិដ្ឋ ដែលបានប្រព្រឹត្តឡើង ដោយសារការអនុវត្តគោលនយោបាយរហូតមានការប៉ះពាល់យ៉ាងដូច្នេះ វាលើសពីការរំខានផ្លូវចិត្តទៅទៀតចំពោះមនុស្ស ដែលមានសភាពផ្លូវចិត្តធម្មតា។ ការរំខានបែបនេះ មិនត្រឹមតែកើតចេញពីការបានឃើញផ្ទាល់ភ្នែកនូវការប្រព្រឹត្តបទឧក្រិដ្ឋទាំងនោះប៉ុណ្ណោះទេតែក៏កើតចេញពីការគម្រាមកំហែងដែលកើតមានជាបន្តបន្ទាប់ ដោយសារព្រឹត្តិការណ៍ទាំងនេះអាចនឹងបង្កជាការភ័យដល់អ្នកដទៃទៀតដែលថា ពួកគេនឹងជួបនូវជោគវាសនាបែបនេះដែរ ដោយសារពួកគេស្ថិតនៅក្នុងក្រុម ឬ សហគមន៍តែមួយ ជាមួយជនរងគ្រោះផ្ទាល់នៃបទឧក្រិដ្ឋណាមួយ ដែលបានប្រព្រឹត្តឡើងជាផ្នែកមួយនៃការអនុវត្តនូវគោល នយោ

---

[129] អង្គបុរេជំនុំជម្រះកត់សម្គាល់ថា អង្គជំនុំជម្រះនឹងវាយតម្លៃលើកំហុសអង្គហេតុដែលបានចោទប្រកាន់ពាក់ព័ន្ធនឹងអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី *ក្នុងនោះរួមមាន* ជន ណាត (13-VSS-00316) នៅក្នុងមូលដ្ឋានទី២ និង/ឬមូលដ្ឋានទី៤ *ខាងក្រោម*។

[130] វិធាន ២៣*ស្ទួន*(១)(ខ)។

[131] សំណុំរឿង ០០២ សាលដីកាបណ្តឹងឧទ្ធរណ៍ពាក់ព័ន្ធដើមបណ្តឹងរដ្ឋប្បវេណី (ឯកសារ D404/2/4) កថាខណ្ឌ ៨៦។ សំណុំរឿង ០០២ សាលដីកាបណ្តឹងឧទ្ធរណ៍ពាក់ព័ន្ធដើមបណ្តឹងរដ្ឋប្បវេណី (ឯកសារ D411/3/6) កថាខណ្ឌ ៨៦។

[132] សំណុំរឿង ០០២ សាលដីកាបណ្តឹងឧទ្ធរណ៍ពាក់ព័ន្ធដើមបណ្តឹងរដ្ឋប្បវេណី (ឯកសារ D404/2/4) កថាខណ្ឌ ៨៣-៩៣។ សំណុំរឿង ០០២ សាលដីកាបណ្តឹងឧទ្ធរណ៍ពាក់ព័ន្ធដើមបណ្តឹងរដ្ឋប្បវេណី (ឯកសារ D411/3/6) កថាខណ្ឌ ៨៣-៩៣។

បាយទាំងនោះ[133]។

ក្រោយពីធ្វើការសង្កេតបែបនេះរួចមកអង្គបុរេជំនុំជម្រះបានសម្រេចថា "ចំពោះអ្នកដាក់ពាក្យសុំទាំងឡាយណាដែលអះអាងថា បានទទួលរងព្យសនកម្មផ្លូវចិត្ត ដែលមិនមានភាពជិតស្និទ្ធជាមួយជនរងគ្រោះផ្ទាល់នោះ អង្គបុរេជំនុំជម្រះត្រូវអនុវត្តតាមការសន្មតថាជាព្យសនកម្មរួម" នៅក្នុងការវាយតម្លៃចំពោះពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី[134]។

64. នៅក្នុងរឿងក្ដីនេះ អង្គបុរេជំនុំជម្រះបញ្ជាក់ថា ជនរងគ្រោះដោយប្រយោល អាចបង្ហាញព្យសនកម្មផ្លូវចិត្ត ទោះបីជាពុំមានទំនាក់ទំនងគ្រួសារជាមួយជនរងគ្រោះផ្ទាល់ តាមរយៈសមាជិកភាពរបស់ខ្លួននៅក្នុងក្រុមគោលដៅតែមួយ ឬ សហគមន៍ក៏ដោយ។ អង្គបុរេជំនុំជម្រះសង្កេតឃើញថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិ តាមពិត បានអនុវត្តតាមវិធីសាស្ត្រនេះ ដូចបានសន្និដ្ឋាននៅក្នុងផ្នែកពាក់ព័ន្ធនៃដីកាដែលរងការជំទាស់៖

> ព្យសនកម្មខាងផ្លូវចិត្ត គឺរួមបញ្ចូលទាំងព្យសនកម្ម ដែលជនរងគ្រោះផ្ទាល់ទទួលរងដោយផ្ទាល់ពីឧក្រិដ្ឋ ឬ ជាព្យសនកម្ម ដែលជនរងគ្រោះមិនផ្ទាល់ បានទទួលរងដោយសារឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តមកលើជនរងគ្រោះផ្ទាល់ ឬ ដោយសារព្យសនកម្ម ដែលជនរងគ្រោះផ្ទាល់បានទទួលរង។ *ជនរងគ្រោះមិនផ្ទាល់អាចរងព្យសនកម្មបែបនេះ ទោះបីជាគាត់គ្មានទំនាក់ទំនងជាគ្រួសារជាមួយនឹងជនរងគ្រោះផ្ទាល់ក៏ដោយ ពោលគឺឱ្យតែពួកគាត់ជាសមាជិកនៅក្រុមគោលដៅតែមួយ ឬ ក្នុងសហគមន៍តែមួយ ឬ ប្រសិនបើជនរងគ្រោះមិនផ្ទាល់បានទទួលរងព្យសនកម្មដោយសារតែជនរងគ្រោះផ្ទាល់បានទទួលរង*[135]។

65. ផ្អែកលើមូលដ្ឋាននេះ សហមេធាវីចោទប្រកាន់ថា "ការសន្មតទុកជាមុនពីការខូចខាតជាសមូហភាព ដែលកើតចេញពីព្យសនកម្មដែលទទួលរងដោយជនរងគ្រោះផ្ទាល់នៅក្នុងភូមិភាគកណ្ដាល [...] លាតសន្ធឹងដល់សមាជិក*គ្រប់រូប* នៃក្រុមមនុស្ស ឬសហគមន៍គោលដៅ

---

[133] សំណុំរឿង ០០២ សាលដីកាបណ្ដឹងឧទ្ធរណ៍ពាក់ព័ន្ធដើមបណ្ដឹងរដ្ឋប្បវេណី (ឯកសារ D404/2/4) កថាខណ្ឌ ៨៦។ សំណុំរឿង ០០២ សាលដីកាបណ្ដឹងឧទ្ធរណ៍ពាក់ព័ន្ធដើមបណ្ដឹងរដ្ឋប្បវេណី (ឯកសារ D411/3/6) កថាខណ្ឌ ៨៦។

[134] សំណុំរឿង ០០២ សាលដីកាបណ្ដឹងឧទ្ធរណ៍ពាក់ព័ន្ធដើមបណ្ដឹងរដ្ឋប្បវេណី (ឯកសារ D404/2/4) កថាខណ្ឌ ៩៣។ សំណុំរឿង ០០២ សាលដីកាបណ្ដឹងឧទ្ធរណ៍ពាក់ព័ន្ធដើមបណ្ដឹងរដ្ឋប្បវេណី (ឯកសារ D411/3/6) កថាខណ្ឌ ៩៣។

[135] ដីកាសម្រេចស្ដីពីដើមបណ្ដឹងរដ្ឋប្បវេណី (អន្តរជាតិ) (ឯកសារ D362) កថាខណ្ឌ ៣៤ (ការគូសបញ្ជាក់បន្ថែម)។

ជាក់លាក់ទាំងនេះ ដោយមិនគិតដល់ទីកន្លែងរបស់ពួកគេ"[136]។ ទោះបីជាយ៉ាងនេះក្តី អង្គជំនុំជម្រះសូមរម្លឹកថា វិធាន ២៣*ស្ទួន*(១)(ខ) ទាមទារលក្ខខណ្ឌចំណងទាក់ទងរវាង*ព្យសនកម្ម* និង*ឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់*[137]រួមទាំងទំនាក់ទំនងជាមួយជនរងគ្រោះដោយប្រយោល។

66. ផ្ទុយពីសំណុំរឿង ០០២ ឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់ប្រឆាំងនឹង អោ អាន បានកម្រិតត្រឹមវិសាលភាពភូមិសាស្ត្រនៃភូមិភាគកណ្តាល[138]។ ដូចបានកត់សម្គាល់ រឿងក្តីនេះបង្ហាញទៀតថា ព្យសនកម្ម ដែលអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីបានពិពណ៌នា ត្រូវជាប់ទាក់ទងនឹងភូមិភាគកណ្តាល។ ជាពិសេស ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ពិពណ៌នាអំពីការកំណត់គោលដៅនៃក្រុមជាក់លាក់ ដូចខាងក្រោម៖

> ចាប់តាំងពីចុងឆ្នាំ១៩៧៦ ឬ ដើមឆ្នាំ១៩៧៧ និងរហូតដល់ហោចណាស់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩ កែ ពក **អោ អាន** និងកម្មាភិបាលផ្សេងៗទៀតនៃបក្សកុម្មុយនីស្តកម្ពុជា មានគោលបំណងរួមក្នុងការអនុវត្តគោលនយោបាយទាំងបួនរបស់បក្សកុម្មុយនីស្តកម្ពុជា នៅក្នុងភូមិភាគកណ្តាលនៃកម្ពុជាប្រជាធិបតេយ្យ។
>
> [...]
>
> iii. ការកំណត់គោលដៅលើក្រុមពិសេស ដូចជា កម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជានៃភូមិភាគកណ្តាល អតីតមន្ត្រីនៃរបបសាធារណរដ្ឋខ្មែរ "*ប្រជាជន ១៧មេសា*" ប្រជាជនមកពីភូមិភាគបូព៌ា ប្រជាជនចាម និងក្រុមគ្រួសាររបស់ពួកគេ ត្រូវបានអនុវត្តតាមរយៈការប្រព្រឹត្តឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ទៅលើប្រជាជនចាមនៅខេត្តកំពង់ចាម តាមរយៈការសម្លាប់ ការបង្កឱ្យព្យសកម្មផ្លូវកាយ ឬ ផ្លូវចិត្តធ្ងន់ធ្ងរ និងតាមរយៈឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដោយការដាក់ពន្ធនាគារ ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើទារុណកម្ម និងអំពើអមនុស្សធម៌ផ្សេងៗទៀត (ការបាត់ខ្លួនដោយបង្ខំ ពលកម្មដោយបង្ខំ ការធ្វើទារុណកម្មលើ

---

[136] បណ្តឹងឧទ្ធរណ៍ពាក់ព័ន្ធនឹងដើមបណ្តឹងរដ្ឋប្បវេណី (D362/5) កថាខណ្ឌ ៣២។

[137] វិធាន ២៣*ស្ទួន*(១)(ខ)។

[138] ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D360) កថាខណ្ឌ ៨២៥។

រូបកាយនៃអ្នកទោស លក្ខខណ្ឌនៃការឃុំឃាំងដ៏អមនុស្សធម៌) ការធ្វើទុក្ខបុកម្នេញដោយសារហេតុផលនយោបាយព្រមទាំងការធ្វើទុក្ខបុកម្នេញដោយសារហេតុផល សាសនា[139]។

67. ផ្ទុយមកវិញ សហមេធាវីផ្តល់ទឡ្ហីករណ៍ថា អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី *ទាំងអស់* ដែលចោទប្រកាន់ថា ខ្លួនមានព្យសនកម្មដោយសារជាសមាជិកនៃក្រុមគោលដៅជាក់លាក់ អាចទទួលយកបាន សូម្បីនៅពេលព្យសនកម្មពុំមែនកើតចេញពីការកំណត់គោលដៅសមាជិកនៃក្រុមជាក់លាក់នៅក្នុងភូមិភាគកណ្តាលក៏ដោយ[140]។ ឧទាហរណ៍ សហមេធាវីពិពណ៌នាអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី អែល ម៉ើ ជាជនជាតិ ចាម ដែលត្រូវបានផ្លាស់ទីលំនៅ ដោយបង្ខំជាមួយគ្រួសាររបស់គាត់ពីផ្ទះរបស់ពួកគេនៅក្នុងខេត្តកំពតទៅកាន់ទីតាំងនានានៅសម័យកម្ពុជាប្រជាធិបតេយ្យ នៅក្រៅភូមិភាគកណ្តាល ហើយត្រូវបានបង្ខំឱ្យហូបសាច់ជ្រូកផ្ទុយនឹងជំនឿសាសន៍របស់គាត់[141]។ ទោះបីជាអង្គជំនុំជម្រះយល់ស្របថាករណីនេះអាចបង្កឱ្យមានការឈឺចាប់ និងអាចជាប់ពាក់ព័ន្ធនឹងគោលនយោបាយ ដែលត្រូវបានអនុវត្តនៅទូទាំងប្រទេសកម្ពុជា នៅក្នុងអំឡុងពេលនៃរបបខ្មែរក្រហមក៏ដោយ ក៏ព្យសនកម្មដែលត្រូវបានចោទប្រកាន់នេះ ពុំបានបណ្តាលមកពីការកំណត់គោលដៅជនជាតិចាមនៅក្នុងភូមិភាគកណ្តាលនោះទេ ហើយក៏ពុំមែនជាការទទួលខុសត្រូវរបស់ អោ អាន នោះដែរ។

68. ហេតុដូច្នេះ អង្គបុរេជំនុំជម្រះសន្និដ្ឋានថា លក្ខខណ្ឌតម្រូវពីទំនាក់ទំនង នៅក្នុងវិធាន ២៣*ស្ទួន*(១)(ខ) កំណត់ថា សច្ចធារណ៍នៃព្យសនកម្មជាសមូហភាព នៅក្នុងរឿងក្តីបច្ចុប្បន្ន ពង្រីករហូតដល់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដែលអាចភ្ជាប់ព្យសនកម្មរបស់ពួកគេ ជាមួយនឹងឧក្រិដ្ឋកម្ម ដែលត្រូវបានចោទប្រកាន់ថាបានប្រព្រឹត្តឡើងប្រឆាំងនឹងជនរងគ្រោះផ្ទាល់នៅក្នុងភូមិភាគកណ្តាល។ ត្រឹមជាសមាជិកនៃក្រុមគោលដៅជាក់លាក់នៅកន្លែងផ្សេង ដោយពុំមាន

---

[139] ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D360) កថាខណ្ឌ ៨២៥។

[140] បណ្តឹងឧទ្ធរណ៍ពាក់ព័ន្ធនឹងដើមបណ្តឹងរដ្ឋប្បវេណី (D362/5) កថាខណ្ឌ ៣៣-៣៥ (ដែលលើកឡើងថា "ម្ចាស់បណ្តឹងឧទ្ធរណ៍ដែលមានឈ្មោះនៅក្នុងឧបសម្ព័ន្ធ "ង" បានផ្តល់ព័ត៌មានគ្រប់គ្រាន់ទាំងអស់ ដើម្បីបង្ហាញថាពួកគេជាសមាជិកនៅក្នុងក្រុម ឬ សហគមន៍គោលដៅជាក់លាក់មួយ ឬ ច្រើនដែលត្រូវបានកំណត់អត្តសញ្ញាណនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរនោះ" និង "*ផ្អែកលើមូលដ្ឋាននេះ* [អង្គបុរេជំនុំជម្រះ] គួរបដិសេធដីកាដែលរងការជំទាស់ ហើយទទួលយកម្ចាស់បណ្តឹងឧទ្ធរណ៍ទាំងនេះជាដើមបណ្តឹងរដ្ឋប្បវេណី" ) (ការគូសបញ្ជាក់បន្ថែម)។

[141] បណ្តឹងឧទ្ធរណ៍ពាក់ព័ន្ធនឹងដើមបណ្តឹងរដ្ឋប្បវេណី (D362/5) កថាខណ្ឌ ៣៤(៣)។

ទំនាក់ទំនងជាមួយនឹងភូមិភាគកណ្ដាលពុំគ្រប់គ្រាន់នោះទេ។ ទោះបីជាអង្គជំនុំជម្រះសង្កេតឃើញថា អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីភាគច្រើនមិនអាចទទួលយកបាន បានបង្ហាញនៅក្នុងសេចក្ដីសន្និដ្ឋានរបស់សហមេធាវី និងអ្នកដែលមានឈ្មោះនៅក្នុងឧបសម្ព័ន្ធ ង[142] អាចទទួលរងព្យសនកម្មផ្លូវចិត្តដោយសារលទ្ធផលដែលខ្លួន (គេយល់ឃើញថាខ្លួនជា) សមាជិកនៃក្រុមគោលដៅជាក់លាក់ក៏ដោយ ក៏ព្យសនកម្មរបស់ពួកគេពុំជាប់ទាក់ទងនឹង "ឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់" នៅក្នុងរឿងក្ដីនេះទេ ដូច្នេះហើយ សហចៅក្រមស៊ើបអង្កេតអន្តរជាតិពុំមានកំហុសអង្គច្បាប់នៅពេលច្រានចោលអ្នកដាក់ពាក្យសុំទាំងនេះឡើយ[143]។ អាស្រ័យហេតុនេះ មូលដ្ឋានទី១(ខ) ត្រូវបានច្រានចោល។

## ខ. មូលដ្ឋានទី ២÷ ការបំបែកសំណុំរឿង ០០៤/២ ចេញពីសំណុំរឿង ០០៤ មិនគួរជាកត្តាកំណត់លើភាពអាចទទួលបាននៃដើមបណ្ដឹងរដ្ឋប្បវេណីនោះទេ

### *១. សារណា*

69. សហមេធាវីលើកឡើងថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានបកស្រាយខុសចំពោះដីកាសម្រេចបំបែកសំណុំរឿង ០០៤/២[144] ថាជាការកម្រិតសមត្ថភាពរបស់ខ្លួនក្នុងការពិចារណាលើឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់នៅក្នុងសំណុំរឿង ០០៤ មុនការបំបែកដែលមានភាពទូលំទូលាយ ហើយការណ៍នេះបានធ្វើឱ្យប៉ះពាល់ធ្ងន់ធ្ងរដល់ម្ចាស់បណ្ដឹងឧទ្ធរណ៍[145]។ សហ

---

[142] ឧបសម្ព័ន្ធ ង៖ ដើមបណ្ដឹងរដ្ឋប្បវេណីដែលរងព្យសនកម្មដោយសារលទ្ធផលនៃការធ្វើទុក្ខបុកម្នេញលើក្រុមគោលដៅ ឯកសារ D362/5.7។

[143] អង្គបុរេជំនុំជម្រះកត់សម្គាល់ថា អង្គជំនុំជម្រះនឹងវាយតម្លៃលើកំហុសអង្គហេតុដែលបានចោទប្រកាន់ពាក់ព័ន្ធនឹងអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី *ក្នុងនោះរួមមាន* សូ ខេវន ឡេង (11-VSS-00319) និង ម៉ាន ស្មេះ (16-VSS-00015) នៅក្នុងមូលដ្ឋានទី២ និង មូលដ្ឋានទី៤ *ខាងក្រោម*។

[144] បណ្ដឹងឧទ្ធរណ៍របស់ដើមបណ្ដឹងរដ្ឋប្បវេណី (D362/5) កថាខណ្ឌ ៣៦-៣៨ *យោងទៅ* សំណុំរឿង ០០៤ ដីកាសម្រេចបំបែកសំណុំរឿង អោ អាន (D334/1)។

[145] បណ្ដឹងឧទ្ធរណ៍របស់ដើមបណ្ដឹងរដ្ឋប្បវេណី (D362/5) កថាខណ្ឌ ៣៦ *យោងទៅ* ដីកាសម្រេចលើដើមបណ្ដឹងរដ្ឋប្បវេណី (អន្តរជាតិ) (D362) កថាខណ្ឌ ៣៧។

ចៅក្រមស៊ើបអង្កេតអន្តរជាតិបានកាត់បន្ថយវិសាលភាពពេលវេលា និងភូមិសាស្ត្រត្រឹមតែអ្នកដាក់ពាក្យសុំដែលបានទទួលរងព្យសនកម្ម "នៅក្នុងភូមិភាគកណ្ដាល ចាប់តាំងពីពេលប្រហែលជានៅចុងឆ្នាំ១៩៧៦ ដល់ថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៩ ប៉ុណ្ណោះ"[146] ដោយរារាំងប្រកបដោយប្រសិទ្ធិភាពដល់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់នៅក្នុងសំណុំរឿងមុន មិនឱ្យពួកគេបន្តចូលរួមនៅក្នុងដំណើរការនីតិវិធី[147]។ សហមេធាវីលើកឡើងថា ការបកស្រាយរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិចំពោះដីកាសម្រេចបំបែកសំណុំរឿង "ផ្ទុយពីសិទ្ធិរបស់ជនរងគ្រោះ" ដែលត្រូវបានធានាដោយគោលការណ៍ជាសារវ័ន្តរបស់ អ.វ.ត.ក ជាពិសេស ទាក់ទិននឹងគោលដៅនៃការបង្រួបបង្រួមជាតិរបស់សាលាក្ដីនេះ និងភាពចាំបាច់នូវការធានាឱ្យមានការចូលរួមប្រកបដោយអត្ថន័យរបស់ជនរងគ្រោះ[148]។

70. សហមេធាវីចោទប្រកាន់ថា សហចៅក្រមស៊ើបអង្កេតមិនបានធ្វើការចង្អុលបង្ហាញជាមុនថា ដីកាសម្រេចបំបែកសំណុំរឿងនឹងមានផលប៉ះពាល់ជាអវិជ្ជមានទៅលើសិទ្ធិរបស់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីនោះឡើយ[149]។ សហចៅក្រមស៊ើបអង្កេត "បានខកខានក្នុងការពិគ្រោះយោបល់ជាមួយដើមបណ្ដឹងរដ្ឋប្បវេណី ឬមេធាវីតំណាងពួកគេជាមុន អំពីដីកាសម្រេចបំបែកសំណុំរឿងនោះទេ ទោះបីជាវិធាន ៦៦*ស្ទួន* នៃវិធានផ្ទៃក្នុង ដែលតម្រូវឱ្យផ្ដល់ឱកាសដល់ភាគីនានាក្នុងការធ្វើសំណើលើបញ្ហានេះក៏ដោយ"[150]។ ជាងនេះទៀត សហចៅក្រមស៊ើបអង្កេតមិនបានផ្ដល់សេចក្ដីសម្រេចដែលមានសំអាងហេតុ ទៅលើផលប៉ះពាល់របស់ដីកា

---

[146] បណ្ដឹងឧទ្ធរណ៍របស់ដើមបណ្ដឹងរដ្ឋប្បវេណី (D362/5) កថាខណ្ឌ ៣៧។

[147] បណ្ដឹងឧទ្ធរណ៍របស់ដើមបណ្ដឹងរដ្ឋប្បវេណី (D362/5) កថាខណ្ឌ ៣៧។

[148] បណ្ដឹងឧទ្ធរណ៍របស់ដើមបណ្ដឹងរដ្ឋប្បវេណី (D362/5) កថាខណ្ឌ ៣៨ *យោងទៅ* សំណុំរឿង ០០២ សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់ដើមបណ្ដឹងរដ្ឋប្បវេណី (D404/2/4) កថាខណ្ឌ ៦១។

[149] បណ្ដឹងឧទ្ធរណ៍របស់ដើមបណ្ដឹងរដ្ឋប្បវេណី (D362/5) កថាខណ្ឌ ៣៩។

[150] បណ្ដឹងឧទ្ធរណ៍របស់ដើមបណ្ដឹងរដ្ឋប្បវេណី (D362/5) កថាខណ្ឌ ៣៩ *យោងទៅ* វិធាន ៦៦*ស្ទួន*(២) នៃវិធានផ្ទៃក្នុង ("មុនពេលកាត់បន្ថយវិសាលភាពនៃកិច្ចស៊ើបសួរ សហចៅក្រមស៊ើបអង្កេត ត្រូវជូនដំណឹងអំពីព័ត៌មានលម្អិតស្ដីពីគោលបំណងនៃការកាត់បន្ថយ ទៅសហព្រះរាជអាជ្ញា និងមេធាវីរបស់ភាគីដទៃទៀត។ ភាគីទាំងអស់ ត្រូវដាក់សារណាក្នុងរយៈពេល ១៥ថ្ងៃ យ៉ាងយូរ")។

សម្រេចបំបែកសំណុំរឿងដែលមានទៅលើដើមបណ្តឹងរដ្ឋប្បវេណី និងវិសាលភាពនៃសំណុំរឿង ០០៤ សំណុំរឿង ០០៤/១ និង សំណុំរឿង ០០៤/២ នោះឡើយ[151]។

71. ដោយយោងទៅដីកាសម្រេចបំបែកសំណុំរឿង សហមេធាវីលើកឡើងថា ការអនុវត្តនីតិវិធីជាធម្មតា ក្នុងគោលបំណងពន្លឿនកិច្ចដំណើរការនីតិវិធី មិនគួរដកហូតសិទ្ធិរបស់ជនរងគ្រោះក្នុងការចូលរួមប្រកបដោយអត្ថន័យនោះឡើយ[152]។ ទោះបីដីកាសម្រេចបំបែកសំណុំរឿងបានប្រកាសថា ការចេញដីកានេះនឹងមិនបង្កឱ្យមានព្យសនកម្មដល់ភាគីក៏ដោយ តែដីកាសម្រេចនេះក្លាយជាកត្តាកំណត់ពីភាពអាចទទួលយកបាន នៃអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី "យ៉ាងច្រើន" ដោយសារសហចៅក្រមស៊ើបអង្កេតអន្តរជាតិមិនយកចិត្តទុកដាក់ចំពោះវិសាលភាពយ៉ាងទូលំទូលាយនៃសំណុំរឿង ០០៤ ដែលបញ្ចូលឧក្រិដ្ឋកម្មនានានៅភូមិភាគពាយ័ព្យ និងភូមិភាគនិរតី[153]។

72. ហេតុនេះ សហមេធាវីស្នើសុំឱ្យអង្គបុរេជំនុំជម្រះ "សម្រេចថា ដីកាសម្រេចបំបែកសំណុំរឿងបានបង្កការប៉ះពាល់ដល់សិទ្ធិរបស់ម្ចាស់បណ្តឹងឧទ្ធរណ៍" និងច្រានចោលដីកាសម្រេចដែលរងការជំទាស់របស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ[154] ចំពោះម្ចាស់បណ្តឹងឧទ្ធរណ៍ម្នាក់ៗដែល "បានទទួលរងព្យសនកម្ម ដែលជាផលវិបាកដោយផ្ទាល់នៃឧក្រិដ្ឋកម្មដែលបានចោទប្រកាន់នៅក្នុងវិសាលភាពនៃសំណុំរឿង ០០៤ មុនពេលបំបែក"[155]។ ក្នុងការគាំទ្រដល់ការអះអាងរបស់ខ្លួន

---

[151] បណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (D362/5) កថាខណ្ឌ ៣៩ *យោងទៅ* វិធាន ៦៦*ស្ទួន*(៣) នៃវិធានផ្ទៃក្នុង ("សហចៅក្រមស៊ើបអង្កេត ត្រូវកំណត់អំពីអានុភាពនៃសេចក្តីសម្រេចដែលបានធ្វើឡើង អនុលោមតាមអនុវិធាន (១) ខាងលើទៅលើឋានៈរបស់ដើមបណ្តឹងរដ្ឋប្បវេណី ក្នុងការចូលរួមក្នុងកិច្ចស៊ើបសួរ")។

[152] បណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (D362/5) កថាខណ្ឌ ៤០ *យោងទៅ* សំណុំរឿង ០០៤ ដីកាសម្រេចបំបែកសំណុំរឿង អោ អាន (D334/1)។

[153] បណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (D362/5) កថាខណ្ឌ ៤០។

[154] បណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (D362/5) កថាខណ្ឌ ៤១។

[155] បណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (D362/5) កថាខណ្ឌ ៤១ *យោងទៅ* ឧបសម្ព័ន្ធ ខ៖ អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីដែលទទួលរងព្យសនកម្មក្នុងភូមិភាគនិរតីពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ (ខេត្តកំពត ខេត្តកណ្តាល និងខេត្តតាកែវ) ឯកសារ D362/5.4 ("ឧបសម្ព័ន្ធ ខ (D362/5.4)")។ ឧបសម្ព័ន្ធ គ៖ អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីដែលទទួលរងព្យសនកម្មក្នុងភូមិភាគពាយ័ព្យពីឆ្នាំ១៩៧៦ ដល់ឆ្នាំ១៩៧៩ (ខេត្តបន្ទាយមានជ័យ ខេត្តបាត់ដំបង និងខេត្តពោធិ៍សាត់) ឯកសារ D362/5.5 ("ឧបសម្ព័ន្ធ គ (D362/5.5)")។ ឧបសម្ព័ន្ធ ឃ៖ អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹង

សហមេធាវីបានដាក់បញ្ជីឈ្មោះអ្នកដាក់ពាក្យសុំនៅក្នុងឧបសម្ព័ន្ធ ខ (ភូមិភាគនិរតី) ឧបសម្ព័ន្ធ គ (ភូមិភាគពាយ័ព្យ) និង ឧបសម្ព័ន្ធ ឃ (ភូមិភាគកណ្ដាល) ដោយចោទប្រកាន់ថា ពួកគេត្រូវបានបដិសេធដោយមិនត្រឹមត្រូវ[156]។

## ២. ការពិភាក្សា

73. ការបកស្រាយ ដីកាសម្រេចបំបែកសំណុំរឿងរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិមិនបានកម្រិតដោយមិនត្រឹមត្រូវទៅលើការពិនិត្យរបស់ខ្លួន ឬមិនយកចិត្តទុកដាក់ដោយមិនសមរម្យចំពោះការចោទប្រកាន់យ៉ាងទូលំទូលាយនៅក្នុងសំណុំរឿង ០០៤ ដើមនោះឡើយ។

74. ទីមួយ អង្គបុរេជំនុំជម្រះយល់ឃើញថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិមិនបានកាត់បន្ថយវិសាលភាពនៃការស៊ើបអង្កេត ឬដកហូតនូវសិទ្ធិរបស់ជនរងគ្រោះក្នុងការចូលរួមប្រកបដោយអត្ថន័យ ដោយសារដីកាសម្រេចបំបែកសំណុំរឿងនោះទេ។ ដីកាសម្រេចបំបែកសំណុំរឿងគ្រាន់តែ "មានភាពត្រួតគ្នា និងប្រមូលផ្តុំ" អង្គហេតុចោទប្រកាន់ដូចគ្នាពីសំណុំរឿង ០០៤ ដើម្បីបង្កើតជាសំណុំរឿង ០០៤/២ ថ្មីប៉ុណ្ណោះ រួមទាំងឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់ប្រឆាំងនឹង អោ អាន ផងដែរ[157]។ អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីដែលបង្ហាញពីទំនាក់ទំនងរវាងហេតុ និងបច្ច័យទៅនឹងឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់ អាចត្រូវបានទទួលស្គាល់នៅក្នុង

---

រដ្ឋប្បវេណីដែលទទួលរងព្យសនកម្មក្នុងភូមិភាគកណ្ដាលពីឆ្នាំ១៩៧៦ ដល់ឆ្នាំ១៩៧៩ (ខេត្តកំពង់ចាម ខេត្តកំពង់ធំ និងខេត្តក្រចេះ) ឯកសារ D362/5.6 ("ឧបសម្ព័ន្ធ ឃ (D362/5.6)")។

[156] ឧបសម្ព័ន្ធ ខ (D362/5.4)។ ឧបសម្ព័ន្ធ គ (D362/5.5)។ ឧបសម្ព័ន្ធ ឃ (D362/5.6)។

[157] *សូមមើល* សំណុំរឿង ០០៤/១ សេចក្ដីពិចារណាលើបណ្ដឹងឧទ្ធរណ៍របស់ដើមបណ្ដឹងរដ្ឋប្បវេណី (D308/3/1/20) កថាខណ្ឌ ៣៨-៤០ (ដែលអង្គបុរេជំនុំជម្រះបានសម្រេចពីមុនពាក់ព័ន្ធនឹងការបំបែកសំណុំរឿង ០០៤/១ (អ៊ឹម ចែម) ចេញពីសំណុំរឿង ០០៤ ដែលទូលំទូលាយ ថា "សហចៅក្រមស៊ើបអង្កេតបានបំបែកដោយប្រយោលនូវការចោទប្រកាន់ពីបទព្រហ្មទណ្ឌទាំងអស់ប្រឆាំងនឹង អ៊ឹម ចែម ដើម្បីបង្កើតសំណុំរឿង ០០៤/១ មិនមែនជាការបំបែកបុគ្គលទេ"។ ជាងនេះទៀត អង្គជំនុំជម្រះបានសន្និដ្ឋានដោយផ្ទាល់ថា ការចោទប្រកាន់ព្រហ្មទណ្ឌទាំងអស់ប្រឆាំងនឹង អ៊ឹម ចែម "មានភាពត្រួតគ្នា និងប្រមូលផ្តុំនៅក្នុងសំណុំរឿង ០០៤/១ ដោយពុំមានការចោទប្រកាន់ណាមួយសេសសល់នៅក្នុងសំណុំរឿង ០០៤ ទេ"។ ជាការសំខាន់ *"រាល់ការចោទប្រកាន់ពីព្រហ្មទណ្ឌទាំងអស់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ និងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម រួមទាំងការចោទប្រកាន់នានាដែលត្រួតគ្នានៅក្នុងសំណុំរឿង ០០៤/១ ប្រឆាំងនឹង អ៊ឹម ចែម ក៏នៅសេសសល់ក្នុងសំណុំរឿង ០០៤ ដែរ ប្រឆាំងនឹងបុគ្គលដែលមានឈ្មោះ ឬ អញ្ញាតជនផ្សេងទៀត"* (គូសបញ្ជាក់បន្ថែម))។

សំណុំរឿង អោ អាន អនុលោមតាមវិធាន ២៣*ស្ទួន*(១)(ខ) នៃវិធានផ្ទៃក្នុង[158]។ ដោយសារមានភាពត្រួតគ្នាចំពោះបទចោទទាំងអស់ ហើយដោយសារអង្គហេតុចោទប្រកាន់ដែលដូចគ្នាបេះបិទ "នៅមានសេសសល់ក្នុងសំណុំរឿងដើម"[159] នោះ អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅតែទទួលបានឋានៈរបស់ខ្លួនដដែល ទាក់ទិននឹងឧក្រិដ្ឋកម្មដូចគ្នាប្រឆាំងនឹងជនត្រូវចោទ ឬជនសង្ស័យផ្សេងទៀត នៅក្នុងសំណុំរឿង ០០៤។

75. ចំពោះការអះអាងរបស់សហមេធាវីដែលថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានរំលោភទៅលើវិធាន ៦៦*ស្ទួន* នៃវិធានផ្ទៃក្នុង ដោយមិនបានពិគ្រោះយោបល់ជាមួយដើមបណ្តឹងរដ្ឋប្បវេណី "ជាមុនអំពីដីកាសម្រេចបំបែកសំណុំរឿង" ឬ ដីកាសម្រេចបំបែកសំណុំរឿងមិនបាន "បញ្ចូលទៅក្នុងសេចក្តីសម្រេចដែលមានសំអាងហេតុ" អំពីផលប៉ះពាល់ដែលអាចមានទៅលើដើមបណ្តឹងរដ្ឋប្បវេណី[160] នោះ ទឡ្ហីករណ៍ទាំងនេះមិនត្រឹមត្រូវទេ ដោយសារបញ្ញត្តិនេះមិនពាក់ព័ន្ធឡើយ។ វិធាន ៦៦*ស្ទួន*(១)(២) និង (៣) នៃវិធានផ្ទៃក្នុង[161] ចែងក្នុងផ្នែកដែលពាក់ព័ន្ធ ដូចខាងក្រោម៖

> ១. ដើម្បីធានាបាននូវកិច្ចដំណើរការនីតិវិធីមួយប្រកបដោយយុត្តិធម៌ អត្ថន័យ និងឆាប់រហ័ស ជាពិសេស ដោយពិចារណាលើលក្ខខណ្ឌតម្រូវជាក់លាក់នៃកិច្ចដំណើរការនីតិវិធីនៅចំពោះមុខ អ.វ.ត.ក នៅពេលជូនដំណឹងអំពីការបញ្ចប់កិច្ចស៊ើបសួរ សហចៅក្រមស៊ើបអង្កេត អាចសម្រេចកាត់បន្ថយវិសាលភាពនៃកិច្ចស៊ើបសួរ ដោយដកចេញនូវអង្គហេតុមួយចំនួន ដែលមាននៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ឬនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម។ សហចៅក្រមស៊ើបអង្កេតត្រូវធានាថា អង្គហេតុដែលនៅសេសសល់ អាចយកមកធ្វើជាតំណាងចំពោះវិសាលភាពនៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ និងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម។

---

158 *សូមមើលផងដែរ* មូលដ្ឋានទី ១(ក) (ពិភាក្សាអំពីភាពអាចទទួលយកបាននៃអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីក្នុងចំណោមនោះរួមមាន ចំណងទាក់ទងដែលចាំបាច់រវាងព្យសនកម្មដែលអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីបានទទួលរង និងឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់ អនុលោមតាមវិធាន ២៣*ស្ទួន* នៃវិធានផ្ទៃក្នុង)។

159 សំណុំរឿង ០០៤/១ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (D308/3/1/20) កថាខណ្ឌ ៣៨។

160 បណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (D362/5) កថាខណ្ឌ ៣៩។

161 បណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (D362/5) កថាខណ្ឌ ៣៩ ជើងទំព័រ ៩៣ និង ៩៤។

២. មុនពេលកាត់បន្ថយវិសាលភាពនៃកិច្ចស៊ើបសួរ សហចៅក្រមស៊ើបអង្កេត ត្រូវជូនដំណឹងអំពីព័ត៌មានលម្អិតស្តីពីគោលបំណងនៃការកាត់បន្ថយ ទៅសហព្រះរាជអាជ្ញា និងមេធាវីរបស់ភាគីដទៃទៀត។ ភាគីទាំងអស់ ត្រូវដាក់សារណាក្នុងរយៈពេល ១៥ថ្ងៃ យ៉ាងយូរ។

៣. សហចៅក្រមស៊ើបអង្កេត ត្រូវកំណត់អំពីអានុភាពនៃសេចក្តីសម្រេចដែលបានធ្វើឡើង អនុលោមតាមអនុវិធាន (១) ខាងលើ ទៅលើឋានៈរបស់ដើមបណ្តឹងរដ្ឋប្បវេណី ក្នុងការចូលរួមក្នុងកិច្ចស៊ើបសួរ។

ពាក្យពេចន៍ធម្មតានៃបញ្ញត្តិនេះអនុវត្តចំពោះការកាត់បន្ថយវិសាលភាពនៃកិច្ចស៊ើបសួរ ជាយន្តការគតិយុត្តិដែលខុសគ្នាទាំងស្រុងពីការបំបែកសំណុំរឿង។ ហេតុនេះ អង្គជំនុំជម្រះយល់ឃើញថា វិធាន ៦៦*ស្ទួន*(១)(២) និង (៣) នៃវិធានផ្ទៃក្នុង មិនអាចយកមកអនុវត្តចំពោះដីកាសម្រេចបំបែកសំណុំរឿងទេ។

76. ទីពីរ ចំពោះការអះអាងរបស់សហមេធាវីដែលថា តាមរយៈដីកាសម្រេចបំបែកសំណុំរឿង សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានដកហូតសិទ្ធិរបស់ជនរងគ្រោះក្នុងការចូលរួមប្រកបដោយអត្ថន័យ ហើយថា គាត់គួរតែពិចារណាទៅដល់ភូមិភាគពាយ័ព្យ ឬភូមិភាគនិរតី[162] នោះ អង្គបុរេជំនុំជម្រះយល់ឃើញថា ទឡ្ហីករណ៍នេះមិនត្រឹមត្រូវទាល់តែសោះ។ ដីកាសម្រេចបំបែកសំណុំរឿងបង្កឲ្យមានការកាត់បន្ថយ ឬដកចេញដែលបណ្តាលឲ្យប៉ះពាល់ដល់ភាគីណាឡើយ ហេតុនេះត្រូវបានបដិសេធចោល*ដូចខាងលើដែរ*។ ជាងនេះទៀត ដូចដែលអង្គជំនុំជម្រះបញ្ជាក់នៅក្នុងមូលដ្ឋានទី ១ គឺថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិពុំមានកំហុសក្នុងការកាត់បន្ថយវិសាលភាពនៃភាពអាចទទួលយកបាន ត្រឹមតែព្យសនកម្មដែលជាផលវិបាកដោយផ្ទាល់យ៉ាងហោចណាស់ ពីឧក្រិដ្ឋកម្មមួយក្នុងចំណោមឧក្រិដ្ឋកម្មនានាដែលបានចោទប្រកាន់ប្រឆាំងនឹងអោ អាន ដែលបានកើតឡើងនៅ*ភូមិភាគកណ្តាល* ពីពេលប្រហែលនៅចុងឆ្នាំ១៩៧៦ រហូតដល់

[162] បណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (D362/5) កថាខណ្ឌ ៤០។ *សូមមើលផងដែរ* ឧបសម្ព័ន្ធ ខ (D362/5.4)។ ឧបសម្ព័ន្ធ គ (D362/5.5) (ជាមួយឧបសម្ព័ន្ធ ខ យោងទៅអ្នកដាក់ពាក្យសុំដែលទទួលរងព្យសនកម្មនៅក្នុងភូមិភាគនិរតី និងឧបសម្ព័ន្ធ គ ដែលរៀបរាប់ពីអ្នកដាក់ពាក្យសុំដែលទទួលរងព្យសនកម្មនៅក្នុងភូមិភាគពាយ័ព្យ)។

ថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៩ នោះទេ[163]។ ហេតុនេះ អង្គជំនុំជម្រះយល់ឃើញថា ឧបសម្ព័ន្ធ ខ (ដែលរៀបរាប់អ្នកដាក់ពាក្យសុំដែលទទួលរងព្យសនកម្មនៅភូមិភាគនិរតី) និង ឧបសម្ព័ន្ធ គ (ដែលរៀបរាប់អ្នកដាក់ពាក្យសុំដែលទទួលរងព្យសនកម្មនៅភូមិភាគពាយ័ព្យ) ស្ថិតក្រៅវិសាលភាពដែនដី ហើយត្រូវបានបដិសេធ។

77. ទីបី ពាក់ព័ន្ធនឹងឧបសម្ព័ន្ធ ឃ (ដែលរៀបរាប់អ្នកដាក់ពាក្យសុំដែលទទួលរងព្យសនកម្មនៅភូមិភាគកណ្តាល) ដូចឧបសម្ព័ន្ធ ខ និង គ ដែរ អង្គជំនុំជម្រះសម្រេចបដិសេធទឡ្ហីករណ៍ដែលថា ដីកាសម្រេចបំបែកសំណុំរឿងបានបង្កឱ្យមានការប៉ះពាល់ដល់អ្នកដាក់ពាក្យសុំដែលមិនអាចទទួលយកបាន។ ដោយមិនគិតដល់ការណ៍ដែលសហមេធាវីមិនបានលើកឡើងឱ្យបានត្រឹមត្រូវនូវកំហុសឆ្គងនានានោះ អនុលោមតាមវិធាន ២១ នៃវិធានផ្ទៃក្នុង អង្គជំនុំជម្រះយល់ឃើញថា ជាការការពារដល់ផលប្រយោជន៍របស់ជនរងគ្រោះដែលត្រូវយកឧបសម្ព័ន្ធ ឃ មកពិចារណាជាពិសេស ដោយសារភូមិភាគកណ្តាលស្ថិតក្នុងវិសាលភាពដែនដីនៃសំណុំរឿងនេះ ដែលធ្វើឱ្យវាមានភាពជាប់ពាក់ព័ន្ធ*តាមការវិភាគបឋម* ហើយអាចកើតមានឡើងនូវការដកចេញដោយមិនត្រឹមត្រូវ។

78. នៅត្រង់ចំណុចនេះ មានភ្ជាប់មកជាមួយនូវ ឧបសម្ព័ន្ធ ១៖ សេចក្តីពិចារណាទៅលើឧបសម្ព័ន្ធ ឃ នៃដើមបណ្តឹងរដ្ឋប្បវេណី។ ក្រោយពីបានពិនិត្យឡើងវិញទៅលើឧបសម្ព័ន្ធ ឃ អង្គជំនុំជម្រះយល់ឃើញថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិមានកំហុសនៅក្នុងសេចក្តីសម្រេចរបស់ខ្លួន ទៅលើភាពអាចទទួលយកបានរបស់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីចំនួនប្រាំពីរនាក់ ហើយយល់ឃើញថា ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីចំនួនប្រាំពីរនាក់ ដូចខាងក្រោម គួរត្រូវបានទទួលយក ទៅតាមសំអាងហេតុនៅក្នុងឧបសម្ព័ន្ធ ១ ដែលរួមមាន៖ 13-VSS-00316, 12-

[163] *សូមមើល* សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងដីកាដំណោះស្រាយ (D359/24 & D360/33) កថាខណ្ឌ ៦៣២ (ពាក់ព័ន្ធនឹងការកែប្រែដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ដែលចៅក្រមអន្តរជាតិបានពិចារណាឃើញថា "បទល្មើស ១ នៃដីកាបញ្ជូនរឿងទៅជំនុំជម្រះចោទប្រកាន់ អោ អាន បញ្ជូនទៅជំនុំជម្រះពីបទឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ប្រឆាំងជនជាតិចាមនៅកំពង់ចាម *នៅក្នុងភូមិភាគកណ្តាល*")។

VSS-00518, 11-VSS-00059, 12-VSS-00672, 13-VSS-00697, 16-VSS-00020 និង 11-VSS-00032[164]។

79. សរុបមក ទាក់ទិននឹងបញ្ជីឈ្មោះអ្នកដាក់ពាក្យសុំនៅក្នុងឧបសម្ព័ន្ធ ខ (ភូមិភាគនិរតី) ឧបសម្ព័ន្ធ គ (ភូមិភាគពាយ័ព្យ) និង ឧបសម្ព័ន្ធ ឃ (ភូមិភាគកណ្ដាល) លើកលែងតែពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីចំនួនប្រាំពីរនាក់ខាងលើដែលគួរត្រូវបានទទួលយកនោះ អង្គបុរេជំនុំជម្រះយល់ឃើញថា ពុំមានមូលដ្ឋានគតិយុត្តិដើម្បីសន្និដ្ឋានថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិមានកំហុសក្នុងការពិនិត្យទៅលើភាពអាចទទួលស្គាល់នៅក្នុងសំណុំរឿង ០០៤/២ បន្ទាប់ពីមានការបំបែកសំណុំរឿងនោះទេ ឬថា ប្រការនេះ "បានបង្កឲ្យមានការប៉ះពាល់ដែលមិនអាចទទួលបានយក" ចំពោះអ្នកពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីនោះឡើយ។ មូលដ្ឋានទី ២ ត្រូវបានបដិសេធមួយផ្នែក។

## គ. មូលដ្ឋានទី៣. ការមិនបានចេញសេចក្ដីសម្រេច ដោយមានសំអាងហេតុ សម្រាប់ការច្រានចោល ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី

### *១. សារណា*

80. សហមេធាវីបានចោទប្រកាន់ថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិ មានកំហុសអង្គច្បាប់ ដោយមិនបានផ្ដល់មតិដោយមានសំអាងហេតុ សម្រាប់ការច្រានចោល ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី។ សហមេធាវីបានលើកទឡ្ហីករណ៍ថា ដីកាសម្រេចដែលរងការជំទាស់ មិនបានបំពេញតាមបទដ្ឋានអប្បបរមាដែលបានតម្រូវ ដើម្បីគោរពទៅតាមគោលការណ៍នីត្យានុកូលភាព រួមទាំងតម្លាភាពនិងសច្ចភាពផ្លូវច្បាប់ ដូចដែលអង្គបុរេជំនុំជម្រះបានកំណត់នោះឡើយ[165]។ យ៉ាងហោចណាស់ សហចៅក្រមស៊ើបអង្កេតចាំបាច់ត្រូវ "បង្ហាញទាំងស្រុងនូវឯកសារសម្ភារៈ ដែលចៅក្រម

---

[164] អង្គជំនុំជម្រះកត់សម្គាល់ថា អ្នកដាក់ពាក្យសុំចំនួនបីនាក់ក្នុងចំណោមប្រាំពីរនាក់នេះ (12-VSS-00672, 16-VSS-0020 និង 11-VSS-00032) ក៏ត្រូវដាក់ និងពិចារណាអនុលោមតាមមូលដ្ឋានទី ៤ ដែលអង្គជំនុំជម្រះយល់ឃើញថា ពួកគេគួរត្រូវបានទទួលស្គាល់ស្រដៀងគ្នាដែរ ដូច*ខាងក្រោម*។

[165] បណ្ដឹងឧទ្ធរណ៍របស់ដើមបណ្ដឹងរដ្ឋប្បវេណី (ឯកសារ D362/5) កថាខណ្ឌ ៤២, ៤៤ និងជើងទំព័រ ៩៨ យោងទៅរកផងដែរ សំណុំរឿង ០០២ សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់ដើមបណ្ដឹងរដ្ឋប្បវេណី (ឯកសារ D411/3/6) កថាខណ្ឌ ៣៧-៣៨។

01647504



បានយកមកពិចារណា នៅពេលចេញសេចក្តីសម្រេច"[166]។ ពេលដែលដើមបណ្តឹងរដ្ឋប្បវេណី មិនត្រូវបានជូនដំណឹងអំពីសំអាងហេតុ ពេលនោះសិទ្ធិប្តឹងឧទ្ធរណ៍ ដែលមានចែងក្នុងវិធានផ្ទៃក្នុង នឹងក្លាយជាគ្មានន័យ[167]។

81. សហមេធាវីបានលើកទឡ្ហីករណ៍ថា អង្គបុរេជំនុំជម្រះនាពេលកន្លងមក បានកំណត់ពីបទដ្ឋានអប្បបរមា សម្រាប់សេចក្តីសម្រេចដោយមានសំអាងហេតុ ទាក់ទងពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដែលត្រូវបានបដិសេធនៅក្នុងសំណុំរឿង ០០២ ហើយអះអាងថា ដីកាសម្រេចដែលរងការជំទាស់ "មិនបានបំពេញ" តាមបទដ្ឋានទាំងអស់នោះ[168]។ សហមេធាវីបានលើកឡើងថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានច្រានចោល "យ៉ាងច្រើនលើសលប់" នូវពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី "*ជារួម* ដោយពុំបានធ្វើការពិចារណាត្រឹមត្រូវលើពាក្យសុំនីមួយៗ"[169]។ សហមេធាវីបានចោទប្រកាន់ថា ដីកាសម្រេចដែលរងការជំទាស់ ដូចនៅក្នុងសំណុំរឿង ០០២ ដែរ បានប្រើប្រាស់សំអាងហេតុ ឬការខ្វះសំអាងហេតុ "មានកម្រិតត្រឹមតែពាក្យពេចន៍ពីរបីឃ្លាខ្លីៗ ដែលគេអាចយកមកប្រើប្រាស់ឡើងវិញ បានច្រើនដង"[170]។ ដីកាសម្រេចដែលរងការជំទាស់ បានច្រានចោល "ម្ចាស់បណ្តឹងឧទ្ធរណ៍ជិតបីភាគបួនផ្អែកលើមូលហេតុធម្មតា" ដូចជាស្ថិតក្រៅវិសាលភាព នៃសំណុំរឿង ឬថាប្រហែលជាម្ចាស់បណ្តឹងឧទ្ធរណ៍ មិនបានទទួលរងព្យសនកម្ម ជាលទ្ធផលដោយផ្ទាល់ពីបទឧក្រិដ្ឋ ដែលត្រូវបានចោទប្រកាន់ឡើយ[171]។ ការមិនមានភាពជាក់លាក់នេះ ធ្វើឱ្យអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី មិនអាចប្រើប្រាស់សិទ្ធិប្តឹងឧទ្ធរណ៍

[166] បណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (ឯកសារ D362/5) កថាខណ្ឌ ៤២ ដកស្រង់សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ ដើមបណ្តឹងរដ្ឋប្បវេណី (D411/3/6) កថាខណ្ឌ ៣៩។

[167] បណ្តឹងឧទ្ធរណ៍របស់ ដើមបណ្តឹងរដ្ឋប្បវេណី (ឯកសារ D362/5) កថាខណ្ឌ ៤២។

[168] បណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (ឯកសារ D362/5), កថាខណ្ឌ ៤៣-៤៤ យោងទៅរក សំណុំរឿង ០០២ សាលដីកាលើ បណ្តឹងឧទ្ធរណ៍របស់ ដើមបណ្តឹងរដ្ឋប្បវេណី (ឯកសារ D411/3/6)។ សំណុំរឿង ០០២ សាលដីកាលើ បណ្តឹងឧទ្ធរណ៍របស់ ដើមបណ្តឹងរដ្ឋប្បវេណី (ឯកសារ D404/2/4)។

[169] បណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (ឯកសារ D362/5) កថាខណ្ឌ ៤៤។

[170] បណ្តឹងឧទ្ធរណ៍របស់ ដើមបណ្តឹងរដ្ឋប្បវេណី (ឯកសារ D362/5) កថាខណ្ឌ ៤៤។

[171] បណ្តឹងឧទ្ធរណ៍របស់ ដើមបណ្តឹងរដ្ឋប្បវេណី (ឯកសារ D362/5) កថាខណ្ឌ ៤៤។

របស់ខ្លួន ប្រកបដោយអត្ថន័យឡើយ[172]។

82. សហមេធាវីបានស្នើដល់អង្គបុរេជំនុំជម្រះ ច្រានចោលដីកាសម្រេចដែលរងការជំទាស់ ក្នុងករណីដែលពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី "ស្ថិតក្រៅវិសាលភាពនៃសំណុំរឿង" ឬក្នុងករណីដែល "មិនត្រូវបានបង្ហាញថា ម្ចាស់បណ្តឹងឧទ្ធរណ៍ទទួលរងព្យសនកម្ម ជាលទ្ធផលដោយផ្ទាល់ពីបទឧក្រិដ្ឋដែលត្រូវបានចោទប្រកាន់" ដោយសារតែមូលដ្ឋាននៃការបដិសេធ មិនត្រូវបានធ្វើឡើងដោយដីកាសម្រេចដែលមានសំអាងហេតុ[173]។

## *២. ការពិភាក្សា*

83. អង្គបុរេជំនុំជម្រះបានសម្រេចថា ដីកាសម្រេចដែលរងការជំទាស់ និងឧបសម្ព័ន្ធ ខ ដែលពាក់ព័ន្ធ (បង្ហាញពីការវិភាគចំពោះ ពាក្យសុំតាំងខ្លួនដែលមិនអាចទទួលយកបាន) បានផ្តល់សំអាងហេតុគ្រប់គ្រាន់ ដើម្បីគាំទ្រការសម្រេចលើភាពមិនអាចទទួលយកបាន ដែលដូច្នេះគឺបង្កើតបានជា ដីកាសម្រេចដែលមានសំអាងហេតុ។ ដីកាសម្រេចនិងឧបសម្ព័ន្ធ ខ ដែលពាក់ព័ន្ធ បង្ហាញពីសម្ភារៈដែលត្រូវបានប្រើប្រាស់ សម្រាប់ធ្វើការពិចារណា។ ឯកសារទាំងអស់នេះបង្ហាញថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានពិចារណាជាបុគ្គលទៅលើ អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនីមួយៗ ហើយអនុញ្ញាតឲ្យម្ចាស់បណ្តឹងឧទ្ធរណ៍ ប្រើប្រាស់ដោយប្រសិទ្ធិភាព នូវសិទ្ធិរបស់ពួកគេក្នុងការប្តឹងឧទ្ធរណ៍។

84. អង្គបុរេជំនុំជម្រះសូមរំឭកថា "លក្ខខណ្ឌតម្រូវដែលថា សេចក្តីសម្រេចទាំងអស់របស់តុលាការតម្រូវឲ្យផ្តល់សំអាងហេតុ [...] ជាបទដ្ឋានអន្តរជាតិ"[174]។ ទីមួយ អង្គជំនុំជម្រះពិចារណាថា ការ

[172] បណ្តឹងឧទ្ធរណ៍របស់ ដើមបណ្តឹងរដ្ឋប្បវេណី (ឯកសារ D362/5) កថាខណ្ឌ ៤៤។

[173] បណ្តឹងឧទ្ធរណ៍របស់ ដើមបណ្តឹងរដ្ឋប្បវេណី (ឯកសារ D362/5) កថាខណ្ឌ ៤៥។ *សូមមើលផងដែរ* បណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (ឯកសារ D362/5) ឧបសម្ព័ន្ធ ឆ៖ អ្នកដាក់ពាក្យសុំតាំងខ្លួន ជាដើមបណ្តឹងរដ្ឋប្បវេណី ដែលសម្រេចថាមិនអាចទទួលស្គាល់បាន ដោយផ្អែកលើមូលដ្ឋានមិនគ្រប់គ្រាន់ (ឯកសារ D362/5.9)។

[174] សំណុំរឿង ០០២ សាលដីកាលើ បណ្តឹងឧទ្ធរណ៍របស់ ដើមបណ្តឹងរដ្ឋប្បវេណី (ឯកសារ D404/2/4) កថាខណ្ឌ ៣៨។ សំណុំរឿង ០០២ សាលដីកាលើ បណ្តឹងឧទ្ធរណ៍របស់ ដើមបណ្តឹងរដ្ឋប្បវេណី (ឯកសារ D411/3/6) កថាខណ្ឌ ៣៨ យោងទៅរកសំណុំរឿង ០០២ (អបជ០៦) សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់លោក នួន ជា ប្រឆាំងចំពោះដីកាបដិសេធពាក្យសុំមោឃភាព ថ្ងៃទី២៦ ខែសីហា ឆ្នាំ២០០៨ ឯកសារ D55/I/8 កថាខណ្ឌ ២១។

តម្រូវឲ្យមានសេចក្តីសម្រេច ដោយមានសំអាងហេតុ គឺដើម្បីភាគីអាចប្រើប្រាស់ដោយប្រសិទ្ធិភាព នូវសិទ្ធិរបស់ខ្លួនក្នុងការប្តឹងឧទ្ធរណ៍ តាមវិធាន៧៤ នៃវិធានផ្ទៃក្នុង[175]។ នៅក្នុងសេចក្តីសម្រេចកន្លងមករបស់ខ្លួន អង្គជំនុំជម្រះបានសម្រេចថា ទោះបីជា "សហចៅក្រមស៊ើបអង្កេត មិនមានកាតព្វកិច្ច "ផ្តល់ការយល់ឃើញទៅលើកត្តាទាំងអស់" ដែលបានពិចារណានៅក្នុងដំណើរការធ្វើសេចក្តីសម្រេចរបស់ខ្លួននោះឡើយ" សំខាន់បំផុតគឺភាគីពាក់ព័ន្ធទាំងអស់ ដឹងអំពីមូលហេតុនៃសេចក្តីសម្រេចនីមួយៗ"[176]។ ការនេះធ្វើឲ្យភាគីអាចធ្វើសេចក្តីសម្រេចច្បាស់លាស់ ថាតើប្តឹងឧទ្ធរណ៍ឬអត់ និងប្តឹងទៅលើមូលដ្ឋានអ្វីដែរ[177]។

---

[175] វិធាន ៧៤ នៃវិធានផ្ទៃក្នុង ទាក់ទងមូលដ្ឋានសម្រាប់ បណ្តឹងឧទ្ធរណ៍បុរេជំនុំជម្រះ។ ជាពិសេសពាក់ព័ន្ធជាមួយវិធាន ៧៤ (៤) នៃវិធានផ្ទៃក្នុង ទាក់ទងបណ្តឹងឧទ្ធរណ៍របស់ ដើមបណ្តឹងរដ្ឋប្បវេណី ចែងថា "ដើមបណ្តឹងរដ្ឋប្បវេណីអាចធ្វើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីការបស់សហចៅក្រមស៊ើបអង្កេត ដូចខាងក្រោម ៖" ហើយរៀបរាប់ពីមូលដ្ឋានជាក់លាក់ សម្រាប់បណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី ដូចជាបណ្តឹងឧទ្ធរណ៍ ប្រឆាំងដីកាសម្រេច "មិនទទួលពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី"។

[176] សំណុំរឿង ០០២ សាលដីកាលើ បណ្តឹងឧទ្ធរណ៍របស់ ដើមបណ្តឹងរដ្ឋប្បវេណី (ឯកសារ D404/2/4) កថាខណ្ឌ ៣៨។ សំណុំរឿង ០០២ សាលដីកាលើ បណ្តឹងឧទ្ធរណ៍របស់ ដើមបណ្តឹងរដ្ឋប្បវេណី (ឯកសារ D411/3/6) កថាខណ្ឌ ៣៨ យោងទៅរកសំណុំរឿង ០០២ (អបជ០៣) សាលដីកាលើបណ្តឹងឧទ្ធរណ៍ ប្រឆាំងដីកាសម្រេចឃុំខ្លួន អៀង សារី បណ្តោះអាសន្ន ថ្ងៃទី១៧ ខែតុលា ឆ្នាំ២០០៨ ឯកសារ C22/I/73 កថាខណ្ឌ ៦៦។ សំណុំរឿង ០០២ (អបជ៦៧) សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញា ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត ស្តីពីសំណើសុំដាក់បញ្ចូល ឯកសារភស្តុតាងបន្ថែមទៅក្នុងសំណុំរឿង ដែលនឹងជួយដល់ការបញ្ជាក់អំពីការដឹងឮរបស់ជនត្រូវចោទ ចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើង ថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១០ ឯកសារ D365/2/10 ("សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍ ប្រឆាំងសំណើសុំដាក់សម្ភារៈភស្តុតាង ទៅក្នុងសំណុំរឿង (ឯកសារ D365/2/10)") កថាខណ្ឌ ២៤។ *សូមមើលផងដែរ* សំណុំរឿង ០០២ (អបជ៦២) សាលដីកាលើបណ្តឹងឧទ្ធរណ៍ របស់សហមេធាវីការពារក្តី អៀង ធីរិទ្ធ ប្រឆាំងនឹង "ដីកាសម្រេចលើសំណើសុំបំពេញកិច្ចស៊ើបសួររបស់ សហមេធាវីការពារក្តី អៀង ធីរិទ្ធ" ចុះថ្ងៃ ទី១៥ ខែមិថុនា ឆ្នាំ២០១០ ថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១០ ឯកសារ D353/2/3 ("សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់មេធាវីការពារក្តី ប្រឆាំងសំណើសុំបំពេញកិច្ចស៊ើបសួរ (ឯកសារ D353/2/3)") កថាខណ្ឌ ២៣។

[177] សំណុំរឿង ០០២ សាលដីកាលើ បណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (ឯកសារ D404/2/4) កថាខណ្ឌ ៣៨។ សំណុំរឿង ០០២ សាលដីកាលើ បណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (ឯកសារ D411/3/6) កថាខណ្ឌ ៣៨។ សំណុំរឿង ០០២ (អបជ៤៦) សាលដីកាលើបណ្តឹងឧទ្ធរណ៍ ប្រឆាំងនឹងដីការបស់ ក.ស.ច.ស ចំពោះសំណើសុំ D153, D172, D173, D174, D178 និង D284 (សំណើសុំបំពេញកិច្ចស៊ើបសួរលើកទី១២ របស់ នួន ជា) ថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០១០ ឯកសារ

85. នៅក្នុងសំណុំរឿង ០០២ អង្គបុរេជំនុំជម្រះបានពិចារណាពីកម្រិត នៃភាពលម្អិតដែលបានតម្រូវនៅក្នុងសំអាងហេតុរបស់សហចៅក្រមស៊ើបអង្កេត នៅពេលទទួលយកឬច្រានចោល ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ហើយអង្គបុរេជំនុំជម្រះបានសម្រេចថា៖

> ជាទូទៅសេចក្តីសម្រេចរបស់តុលាការ ត្រូវបង្ហាញទាំងស្រុងនូវឯកសារសម្ភារៈ ដែលចៅក្រមបានយកមកពិចារណា នៅពេលចេញសេចក្តីសម្រេច។ ចំណុចត្រង់នេះនឹងធានាថា ភាគីនានាដែលមិនទទួលបានជោគជ័យ នៅក្នុងពាក្យសុំរបស់ខ្លួន អាចត្រូវបានធានាថា អង្គហេតុដែលបានដាក់ជូន និងការលើកឡើងរបស់ខ្លួនទាក់ទងទៅនឹងអង្គច្បាប់ ត្រូវបានយកមកពិចារណាយ៉ាងត្រឹមត្រូវ និងពេញលេញ។ អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីម្នាក់ៗ មានសិទ្ធិទទួលបានការពិចារណាទៅលើ ពាក្យសុំជាឯកត្តបុគ្គលរបស់ខ្លួន និងទទួលបាននូវការបង្ហាញថា ចំណុចនេះពិតជាកើតឡើងមែន បើទោះបីជាសេចក្តីសម្រេចនោះ ត្រូវបានចេញនៅក្នុងទម្រង់មួយខ្លី ឬជាតារាងក៏ដោយ"[178]

ក្នុងករណីនេះ អង្គជំនុំជម្រះពិចារណាថា ចាំបាច់ត្រូវមានសំអាងហេតុដែលលម្អិតជាងនេះ ចំពោះអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដែលត្រូវបានបដិសេធ ដោយសារតែសំអាងហេតុរបស់សហចៅក្រមស៊ើបអង្កេត គឺមានត្រឹមតែឃ្លាខ្លីៗ (៥ទៅ១៥ពាក្យ) ហើយ "ច្រើនបំផុត" គឺត្រឹមពីរប្រយោគ សម្រាប់ការបដិសេធ ហើយមិនមានភាពជាក់លាក់ ចំពោះពាក្យសុំតាំងខ្លួននីមួយៗផង[179]។ អង្គជំនុំជម្រះសន្និដ្ឋានថា សហចៅក្រមស៊ើបអង្កេត បានប្រព្រឹត្ត "កំហុសអង្គច្បាប់ដែលលេចធ្លោ" ដោយមិនបានផ្តល់ឲ្យបានគ្រប់គ្រាន់នូវមូលដ្ឋាននៃការច្រានចោលអ្នក

---

D300/1/5 ("សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងដីកាសម្រេចរបស់ ក.ស.ច.ស (ឯកសារ D300/1/5)" កថាខណ្ឌ ៩១។

[178] សំណុំរឿង ០០២ សាលដីកាលើ បណ្តឹងឧទ្ធរណ៍របស់ ដើមបណ្តឹងរដ្ឋប្បវេណី (ឯកសារ D404/2/4) កថាខណ្ឌ ៣៩។ សំណុំរឿង ០០២ សាលដីកាលើ បណ្តឹងឧទ្ធរណ៍របស់ ដើមបណ្តឹងរដ្ឋប្បវេណី (ឯកសារ D411/3/6) កថាខណ្ឌ ៣៩។

[179] សំណុំរឿង ០០២ សាលដីកាលើ បណ្តឹងឧទ្ធរណ៍របស់ ដើមបណ្តឹងរដ្ឋប្បវេណី (ឯកសារ D404/2/4) កថាខណ្ឌ ៣៧, ៣៩។ សំណុំរឿង ០០២ សាលដីកាលើ បណ្តឹងឧទ្ធរណ៍របស់ ដើមបណ្តឹងរដ្ឋប្បវេណី (ឯកសារ D411/3/6) កថាខណ្ឌ ៣៧, ៣៩។

ដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី[180]។

86. ក្នុងករណីបច្ចុប្បន្ន អង្គបុរេជំនុំជម្រះកត់សម្គាល់ថា ដីកាសម្រេចដែលរងការជំទាស់ បានលើកឡើងពីគោលការណ៍គតិយុត្តិ និងលក្ខណៈវិនិច្ឆ័យ ដែលសហចៅក្រមស៊ើបអង្កេតអន្តរជាតិបានអនុវត្ត នៅពេលសម្រេចលើភាពអាចទទួលបានបាននៃ ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី[181]។ គោលការណ៍ទាំងអស់នេះ រួមមានប្រភេទនៃជនរងគ្រោះ និងព្យសនកម្មទាក់ទងពាក្យសុំតាំងខ្លួន ជាដើមបណ្ដឹងរដ្ឋប្បវេណី ដែលត្រូវបានទទួលស្គាល់ ទំនាក់ទំនងហេតុផលតាមការតម្រូវ រវាងព្យសនកម្មដែលបានទទួលរង និងឧក្រិដ្ឋកម្មដែលបានចោទប្រកាន់ ប្រឆាំងជនត្រូវចោទ បទដ្ឋាននៃការបង្ហាញភស្តុតាង និងព័ត៌មានគ្រប់គ្រាន់[182]។ បន្ថែមលើនេះ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានកំណត់អំពីវិសាលភាពនៃ ពាក្យសុំតាំងខ្លួនដែលបានទទួលយក ផ្អែកលើដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ប្រឆាំង អោ អាន ដែលពន្យល់ថា "អ្នកដាក់ពាក្យសុំ ដែលទទួលរងព្យសនកម្មនៅក្នុងភូមិភាគកណ្ដាល ចាប់តាំងពីពេលប្រហែលជានៅចុងឆ្នាំ ១៩៧៦ ដល់ថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៩ បំពេញតាមលក្ខខណ្ឌតម្រូវនៃទំនាក់ទំនងហេតុផល ប្រសិនបើមានលក្ខខណ្ឌចំនួនពីរ"[183]។ ឧបសម្ព័ន្ធដែលពាក់ព័ន្ធ បានផ្ដល់នូវព័ត៌មានបន្ថែម ទាក់ទង

---

[180] សំណុំរឿង ០០២ សាលដីកាលើ បណ្ដឹងឧទ្ធរណ៍របស់ ដើមបណ្ដឹងរដ្ឋប្បវេណី (ឯកសារ D404/2/4) កថាខណ្ឌ ៣៩ -៤០។ សំណុំរឿង ០០២ សាលដីកាលើ បណ្ដឹងឧទ្ធរណ៍របស់ ដើមបណ្ដឹងរដ្ឋប្បវេណី (ឯកសារ D411/3/6) កថាខណ្ឌ ៣៩ -៤០។

[181] ដីកាសម្រេចលើភាពអាចទទួលស្គាល់ អ្នកដាក់ពាក្យសុំតាំងខ្លួន ជាដើមបណ្ដឹងរដ្ឋប្បវេណី របស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ (ឯកសារ D362)។

[182] ដីកាសម្រេចលើភាពអាចទទួលស្គាល់ អ្នកដាក់ពាក្យសុំតាំងខ្លួន ជាដើមបណ្ដឹងរដ្ឋប្បវេណី របស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ (ឯកសារ D362)។

[183] ដីកាសម្រេចលើភាពអាចទទួលស្គាល់ អ្នកដាក់ពាក្យសុំតាំងខ្លួន ជាដើមបណ្ដឹងរដ្ឋប្បវេណី របស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ (ឯកសារ D362) កថាខណ្ឌ ៣៧ -៣៨ (សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានពន្យល់បន្ថែមថា លក្ខខណ្ឌពីរបន្ថែមទៀត ដែលអ្នកដាក់ពាក្យសុំត្រូវបំពេញគឺ៖ (១) ព្យសនកម្មដែលអ្នកដាក់ពាក្យសុំ បានទទួលរង បណ្ដាលមកពីការអនុវត្ត គោលនយោបាយដែលត្រូវបាន ចោទប្រកាន់" របស់បក្សកុម្មុយនីស្តកម្ពុជា ដែលបានរៀបរាប់នៅក្នុងដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ នៅទីតាំងណាមួយនៅភូមិភាគកណ្ដាល (២) "មានភស្តុតាងបង្ហាញថា ការអនុវត្តគោលនយោបាយទាំងនេះ អាចជាអំពើប្រល័យពូជសាសន៍ ឬជាឧក្រិដ្ឋកម្មមួយ ឬលើសពីមួយ ក្នុងចំណោមឧក្រិដ្ឋកម្ម ប្រឆាំងមនុស្សជាតិដែលមានចែងក្នុងមាត្រា ៥ នៃច្បាប់ អ.វ.ត.ក"។

ភាពអាចទទួលយកបាន នៃអ្នកដាក់ពាក្យសុំតាំងខ្លួន ជាដើមបណ្តឹងរដ្ឋប្បវេណីនីមួយៗ[184]។ អង្គបុរេជំនុំជម្រះពិចារណាថា ដីកាសម្រេចដែលរងការជំទាស់ និងឧបសម្ព័ន្ធ ត្រូវបកស្រាយរួមគ្នា។

87. ទោះបីជាសហមេធាវីចោទប្រកាន់ថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិ "ច្រានចោលពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី យ៉ាងច្រើនលើសលប់*ជារួម* ដោយពុំបានធ្វើការពិចារណាត្រឹមត្រូវ លើពាក្យសុំនីមួយៗ"[185] តែអង្គជំនុំជម្រះសម្រេចថា ឧបសម្ព័ន្ធ ខ[186] តាមពិតទៅបានបង្ហាញថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានពិចារណាជាបុគ្គល ទៅលើពាក្យសុំតាំងខ្លួននីមួយៗ។ អង្គជំនុំជម្រះកត់សម្គាល់ថា តារាងមានបញ្ចូលផងដែរនូវលេខឯកសារពាក់ព័ន្ធ និងសំអាងហេតុគ្រប់គ្រាន់ សម្រាប់ការសម្រេច លើភាពមិនអាចទទួលយកបាន។

88. ផ្ទុយពីការគ្រាន់តែបញ្ជាក់ថា "ទំនាក់ទំនងហេតុនិងផលចាំបាច់ រវាងព្យសនកម្មដែលបានលើកឡើង និងអង្គហេតុទាំងឡាយដែលស្ថិតនៅក្រោមការស៊ើបអង្កេត មិនត្រូវបានបង្ហាញ" ឬ "អ្នកដាក់ពាក្យសុំតាំងខ្លួន ជាដើមបណ្តឹងរដ្ឋប្បវេណី មិនបានផ្តល់ព័ត៌មានឲ្យបានគ្រប់គ្រាន់ នៅក្នុងពាក្យសុំរបស់ខ្លួន ដើម្បីបញ្ជាក់អំពីភាពស្របគ្នា ទៅនឹងវិធាន ២៣ស្ទួន(១) និង(៤) នោះទេ" ដូចដែលបានធ្វើនៅក្នុងសំណុំរឿង ០០២[187] នៅក្នុងឧបសម្ព័ន្ធ ខ នៅត្រង់ជួរ "សំអាងហេតុមិនទទួលយកពាក្យសុំ"[188] សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានបង្ហាញពីមូលដ្ឋាននៃការសន្និដ្ឋានរបស់គាត់។ ជាឧទាហរណ៍ បន្ទាប់ពីថ្លែងបញ្ជាក់ពីព័ត៌មានជាក់លាក់ ដែលបានពិចារណាជាដំបូងរួចហើយ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានសន្និដ្ឋានថា "អង្គហេតុដែលបានរៀបរាប់ ស្ថិតនៅក្រៅវិសាលភាពសំណុំរឿង" ឬថា "ទំនងជាការពិតជាជាងការមិនពិតដែលថា គាត់បានទទួលរងការឈឺចាប់ ដោយសារតែឧក្រិដ្ឋកម្មមួយ ក្នុងចំណោមឧក្រិដ្ឋកម្មដែលបានដាក់ជាបទចោទ" ចំពោះអង្គហេតុដែលបានរៀបរាប់ ពាក់ព័ន្ធអ្នកដាក់ពាក្យសុំតាំងខ្លួនម្នាក់ៗ ដែលនេះរួមបញ្ចូលទាំង

---

[184] ឧបសម្ព័ន្ធ ក៖ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដែលត្រូវបានទទួលស្គាល់ ឯកសារ D362.1។ ឧបសម្ព័ន្ធ ខ៖ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដែលមិនត្រូវបានទទួលស្គាល់ ឯកសារ D362.2។

[185] បណ្តឹងឧទ្ធរណ៍របស់ ដើមបណ្តឹងរដ្ឋប្បវេណី (ឯកសារ D362/5) កថាខណ្ឌ ៤៤។

[186] ឧបសម្ព័ន្ធ ខ៖ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដែលមិនត្រូវបានទទួលស្គាល់ ឯកសារ D362.2។

[187] សំណុំរឿង ០០២ សាលដីកាលើ បណ្តឹងឧទ្ធរណ៍របស់ ដើមបណ្តឹងរដ្ឋប្បវេណីs (D404/2/4) កថាខណ្ឌ ៣៧។ សំណុំរឿង ០០២ សាលដីកាលើ បណ្តឹងឧទ្ធរណ៍របស់ ដើមបណ្តឹងរដ្ឋប្បវេណីs (D411/3/6) កថាខណ្ឌ ៣៧។

[188] ឧបសម្ព័ន្ធ ខ៖ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដែលមិនត្រូវបានទទួលស្គាល់ ឯកសារ D362.2។

ឧក្រិដ្ឋកម្ម ដែលត្រូវបានចោទប្រកាន់នៅក្នុងពាក្យសុំតាំងខ្លួន ទីតាំង និងពេលវេលា[189]។

89. ចំពោះ ខៀវ ហ៊ីម[190] បណ្ដឹងតវ៉ាជាក់លាក់មួយ ដែលសហមេធាវីបានធ្វើឡើង ពីការមិនបានផ្ដល់

[189] ឧបសម្ព័ន្ធ ខ៖ ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីដែលមិនត្រូវបានទទួលស្គាល់ ឯកសារ D362.2។ *សូមមើល* ឧទាហរណ៍ ក្នុងចំណោមផ្សេងទៀត ការបដិសេធរបស់សហចៅក្រមស៊ើបអង្កេតអន្តជាតិដែលបញ្ជាក់ថា៖ ម៉ៃ វណ្ណៈ រៀបរាប់អំពី "ការធ្វើឲ្យទៅជាទាសករ និងអំពើអមនុស្សធម៌ផ្សេងទៀតនៅឃុំមានជ័យ ស្រុកឈ្ងូក ខេត្តកំពត នៅសម័យកម្ពុជាប្រជាធិបតេយ្យ, ការសម្លាប់សាច់ញាតិរបស់អ្នកដាក់ពាក្យសុំនៅព្រៃក្តួច ស្រុកត្រាំកក់ ខេត្តតាកែវ នៅពេលវេលាច្បាស់លាស់ នៅសម័យកម្ពុជាប្រជាធិបតេយ្យ" និងមានការ "ទទួលស្គាល់ថា ហេតុការណ៍ទាំងនេះមានការប៉ះទង្គិចផ្លូវចិត្ត តែហេតុការណ៍ទាំងនេះមិនពាក់ព័ន្ធនឹងបញ្ហា ដែលអាចទទួលស្គាល់អ្នកដាក់ពាក្យសុំចូលរួមជាដើមបណ្ដឹងរដ្ឋប្បវេណីបានទេ ដោយសារអង្គហេតុទាំងនោះស្ថិតនៅក្រៅវិសាលភាពសំណុំរឿង" (ឧបសម្ព័ន្ធ ខ៖ ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីដែលមិនត្រូវបានទទួលស្គាល់ ឯកសារ D362.2 ឯកសារ ១៥០)។ *សូមមើលផងដែរ* ឧទាហរណ៍ ការពិនិត្យរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិលើពាក្យសុំរបស់ ទេស បុប្ផា ដែលរៀបរាប់អំពី "អំពើអមនុស្សធម៌ផ្សេងទៀត៖ ការស្លាប់កូន [...] នៅឆ្នាំ១៩៧៥, អំពើអមនុស្សធម៌ផ្សេងទៀត៖ ការបាត់ខ្លួនបងប្អូនប្រុស បងប្អូនប្រុសថ្លៃ កូន និងប្ដី និងអំពើអមនុស្សធម៌ផ្សេងទៀត (រួមមាន ការធ្វើបាប) ការធ្វើឲ្យទៅជាទាសករ និង អំពើអមនុស្សធម៌ផ្សេងទៀត (រួមមាន ស្ថានភាពរស់នៅអមនុស្សធម៌) មកលើអ្នកដាក់ពាក្យសុំនៅស្រុកបាណន់ នៅសម័យកម្ពុជាប្រជាធិបតេយ្យ, អំពើអមនុស្សធម៌ផ្សេងទៀត៖ ការស្លាប់ម្ដាយគាត់ និងបងប្អូន" និងការសន្និដ្ឋានរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិថា "អង្គហេតុដែលបានរៀបរាប់ទាំងនេះស្ថិតនៅក្រៅវិសាលភាពសំណុំរឿង" (ឧបសម្ព័ន្ធ ខ៖ ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីដែលមិនត្រូវបានទទួលស្គាល់ ឯកសារ D362.2 ឯកសារ ៥៩)។ *សូមមើលផងដែរ* ឧទាហរណ៍ ការពិនិត្យរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិលើពាក្យសុំរបស់ ភ្លី លី ដែលបានរៀបរាប់ក្នុងចំណោមផ្សេងទៀតអំពី "ការបាត់ខ្លួនឪពុកម្ដាយរបស់អ្នកដាក់ពាក្យសុំ ប្ដី និងបងប្អូនប្រុស ជាអតីតទាហាន លន់ នល់ នៅតំបន់ ១៣ នៅឆ្នាំ១៩៧៦" និងពាក្យសុំរបស់ ឆាយ សុខ ដែលរៀបរាប់ក្នុងចំណោមផ្សេងទៀតអំពី "ការផ្លាស់ទីលំនៅដោយបង្ខំ [...] ទៅខេត្តកំពង់ស្ពឺ ខេត្តបាត់ដំបង (ឆ្នាំ១៩៧៥) និងខេត្តកណ្ដាល"។ យោងតាមអ្នកដាក់ពាក្យសុំទាំងពីរ សហចៅក្រមស៊ើបអង្កេតអន្តរជាតិសន្និដ្ឋានថា ពួកគេមិនបាន "បញ្ជាក់ថា ទំនងជាការពិតជាជាងមិនពិតដែលថា [ពួកគាត់] បានទទួលរងការឈឺចាប់ ដោយសារឧក្រិដ្ឋកម្មមួយក្នុងចំណោមឧក្រិដ្ឋកម្មដែលបានដាក់ជាបទចោទ" (ឧបសម្ព័ន្ធ ខ៖ ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីដែលមិនត្រូវបានទទួលស្គាល់ ឯកសារ D362.2 ទំព័រ ១១៧, ១២២)។ ការរៀបរាប់របស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិអំពីអង្គហេតុពាក់ព័ន្ធ និងសំអាងហេតុពាក់ព័ន្ធសម្រាប់ការបដិសេធ ដែលថាអង្គហេតុទាំងនេះស្ថិតនៅក្រៅវិសាលភាពសំណុំរឿង ឬអ្នកដាក់ពាក្យសុំមិនបានបង្ហាញឲ្យឃើញថា ខ្លួនទទួលរងការឈឺចាប់ដោយសារឧក្រិដ្ឋកម្មមួយក្នុងចំណោមឧក្រិដ្ឋកម្មដែលបានចោទប្រកាន់ ត្រូវបានធ្វើឡើងជាទូទៅ ដូចករណី ម៉ៃ វណ្ណៈ, ទេស បុប្ផា, ភ្លី លី និង ឆាយ សុខ ហើយដូច្នេះ គ្រប់គ្រាន់ដើម្បីធ្វើការបដិសេធ នៅក្នុងឧបសម្ព័ន្ធ ខ។

សំអាងហេតុនោះ អង្គបុរេជំនុំជម្រះពិចារណាថា សំអាងហេតុរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ គឺគ្រប់គ្រាន់ដោយគាត់បានរៀបរាប់ អំពីអង្គហេតុពាក់ព័ន្ធ ទាក់ទងឧក្រិដ្ឋកម្មដែលបានចោទប្រកាន់ នៅក្នុងឆ្នាំ១៩៧៥ នៅក្នុងខេត្តកំពង់ស្ពឺ ដែលដូច្នេះហើយ "មិនពាក់ព័ន្ធបញ្ហាណាមួយដែលអាចឲ្យគាត់អាចទទួលឋានៈជាដើមបណ្តឹងរដ្ឋប្បវេណីឡើយ"[191]។

90. ជាសន្និដ្ឋាន ការពន្យល់បកស្រាយរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ មានភាពជាក់លាក់ ហើយសំខាន់បំផុត មានការយោងទៅរកព័ត៌មានលម្អិតនៃពាក្យសុំ ដែលត្រូវបានច្រានចោល។ ហេតុដូច្នេះអង្គជំនុំជម្រះពិចារណាថា ឧបសម្ព័ន្ធ ខ នៅពេលអានរួមគ្នាជាមួយ ដីកាសម្រេចដែលរងការជំទាស់ បានបង្ហាញពីសម្ភារៈដែលត្រូវបានយកមកធ្វើការពិចារណា ដោយសហចៅក្រមស៊ើបអង្កេតអន្តរជាតិ នៅពេលធ្វើការសម្រេច ហើយការនេះបង្ហាញថា ពាក្យសុំតាំងខ្លួននីមួយ "ត្រូវបានយកមកពិចារណាយ៉ាងត្រឹមត្រូវ និងពេញលេញ"[192]។ អង្គជំនុំជម្រះសម្រេចថា ដីកាសម្រេចដែលរងការជំទាស់ និងឧបសម្ព័ន្ធ ខ ដែលពាក់ព័ន្ធ គឺមានសំអាងហេតុគ្រប់គ្រាន់ ដែលអនុញ្ញាតឲ្យអ្នកដាក់ពាក្យសុំតាំងខ្លួននីមួយៗ អាចដាក់បណ្តឹងឧទ្ធរណ៍ ប្រឆាំងការបដិសេធពាក្យសុំតាំងខ្លួនរបស់គាត់បាន។ ហេតុដូច្នេះ មូលដ្ឋានទីបីត្រូវបានបដិសេធចោល។

## ឃ. មូលដ្ឋានទី៤÷ ការចោទប្រកាន់ពីការមិនបានផ្តល់ព័ត៌មានគ្រប់គ្រាន់

### *១. សារណា*

91. សហមេធាវីបានលើកឡើងថា សហចៅក្រមស៊ើបអង្កេត មានកំហុសឆ្គងលើអង្គហេតុ ដោយបដិសេធអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដោយសារតែមិន "មានព័ត៌មានគ្រប់គ្រាន់ ស្របតាមវិធាន២៣ ស្ទួន (១) និង(៤) នៃវិធានផ្ទៃក្នុង"[193]។ សហមេធាវីបានអះអាងថា

[190] បណ្តឹងឧទ្ធរណ៍របស់ ដើមបណ្តឹងរដ្ឋប្បវេណី (ឯកសារ D362/5), កថាខណ្ឌ ៤៤ (សហមេធាវីបានចោទប្រកាន់ថា "ដីកាសម្រេចដែលរងការជំទាស់ បានសង្ខេបនូវអង្គហេតុ ប៉ុន្តែមិនបានបញ្ជាក់អំពីសំអាងហេតុ ដែលសហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានបដិសេធពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីឡើយ")។

[191] ឧបសម្ព័ន្ធ ខ៖ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដែលមិនត្រូវបានទទួលស្គាល់ ឯកសារ D362.2 ទំព័រ ២០៨។

[192] សំណុំរឿង ០០២ សាលដីកាលើ បណ្តឹងឧទ្ធរណ៍របស់ ដើមបណ្តឹងរដ្ឋប្បវេណី (ឯកសារ D404/2/4) កថាខណ្ឌ ៣៩។ សំណុំរឿង ០០២ សាលដីកាលើ បណ្តឹងឧទ្ធរណ៍របស់ ដើមបណ្តឹងរដ្ឋប្បវេណី (ឯកសារ D411/3/6) កថាខណ្ឌ ៣៩។

[193] បណ្តឹងឧទ្ធរណ៍របស់ ដើមបណ្តឹងរដ្ឋប្បវេណី (ឯកសារ D362/5) កថាខណ្ឌ ៤៦។

"ព័ត៌មានត្រូវបានចាត់ទុកថាគ្រប់គ្រាន់ នៅពេលដែលព័ត៌មាននោះ អនុញ្ញាតឱ្យសហចៅក្រមស៊ើបអង្កេតជឿជាក់ថា អង្គហេតុដែលបានអះអាង អាចជាការពិត"[194]។

92. តាមទស្សនៈរបស់សហមេធាវី គោលដៅ និងគោលបំណងនៃវិធាន ២៣ ស្ទួន នៃវិធានផ្ទៃក្នុង គឺមិនរឹតបណ្តឹងឬកម្រិតទស្សនៈនៃបណ្តឹងរដ្ឋប្បវេណី នៅ អ.វ.ត.ក ឡើយ[195] ហើយវិធាននេះចាំបាច់ត្រូវបកស្រាយ រួមជាមួយវិធាន ២១ នៃវិធានផ្ទៃក្នុង ដែលចែងអំពីភារកិច្ចជាសារវន្ត ក្នុងការការពារផលប្រយោជន៍របស់ជនរងគ្រោះ[196]។ សហចៅក្រមស៊ើបអង្កេត "ត្រូវតែសម្រេចថាតើមានមូលដ្ឋានដែលគួរឱ្យជឿជាក់បាន *ជាបឋម* ដែលចង្អុលបង្ហាញថា អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ពិតជាបានទទួលរងព្យសនកម្ម ដែលជាប់ទាក់ទងដោយផ្ទាល់ ទៅនឹងអង្គហេតុដែលស្ថិតនៅក្រោមកិច្ចស៊ើបសួរផ្អែកលើមូលដ្ឋាននៃធាតុផ្សំ នៅក្នុងសំណុំរឿងនោះដែរឬអត់"[197] ហើយក្នុងការសម្រេចនោះ សហចៅក្រមស៊ើបអង្កេត ត្រូវធ្វើការពិចារណាលើកម្រិតធ្ងន់ធ្ងរ នៃឧក្រិដ្ឋកម្មដែលត្រូវដោះស្រាយនៅ អ.វ.ត.ក ដោយផ្អែកលើ "ស្ថានភាពពិសេសនៃជម្លោះ"[198]។ សហមេធាវីយោងទៅរកការទទួលស្គាល់របស់សហចៅក្រមស៊ើបអង្កេត ដែលថាកត្តាជាក់លាក់ខ្លះ បានសម្រាលដល់បន្ទុកបង្ហាញភស្តុតាង នៃព្យសនកម្មដែលបានតម្រូវ សម្រាប់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី (ដូចជាពេលវេលាកន្លងផុត) និងវិធីសាស្ត្របែបបត់បែនរបស់សហចៅក្រមស៊ើបអង្កេត សម្រាប់ការបញ្ជាក់ភស្តុតាងពីអត្តសញ្ញាណ[199]។

---

[194] បណ្តឹងឧទ្ធរណ៍របស់ ដើមបណ្តឹងរដ្ឋប្បវេណី (ឯកសារ D362/5) កថាខណ្ឌ ៤៦។ យោងទៅសំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍ របស់ដើមបណ្តឹងរដ្ឋប្បវេណី (ឯកសារ D404/2/4) កថាខណ្ឌ ៩៤។

[195] បណ្តឹងឧទ្ធរណ៍របស់ ដើមបណ្តឹងរដ្ឋប្បវេណី (ឯកសារ D362/5) កថាខណ្ឌ ៤៧ យោងទៅសំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍ របស់ដើមបណ្តឹងរដ្ឋប្បវេណី (ឯកសារ D404/2/4) កថាខណ្ឌ ៦២។

[196] បណ្តឹងឧទ្ធរណ៍របស់ ដើមបណ្តឹងរដ្ឋប្បវេណី (ឯកសារ D362/5) កថាខណ្ឌ ៤៧ យោងទៅសំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍ របស់ដើមបណ្តឹងរដ្ឋប្បវេណី (ឯកសារ D404/2/4) កថាខណ្ឌ៦១។

[197] បណ្តឹងឧទ្ធរណ៍របស់ ដើមបណ្តឹងរដ្ឋប្បវេណី (ឯកសារ D362/5) កថាខណ្ឌ ៤៨។

[198] បណ្តឹងឧទ្ធរណ៍របស់ ដើមបណ្តឹងរដ្ឋប្បវេណី (ឯកសារ D362/5) កថាខណ្ឌ ៤៨ ដកស្រង់ សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍ របស់ដើមបណ្តឹងរដ្ឋប្បវេណី (ឯកសារ D404/2/4) កថាខណ្ឌ ៧០។

[199] បណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (ឯកសារ D362/5) កថាខណ្ឌ ៤៩-៥០ យោងទៅ ដីកាសម្រេចលើដើមបណ្តឹងរដ្ឋប្បវេណី (សហចៅក្រមស៊ើបអង្កេតអន្តរជាតិ) (ឯកសារ D362) កថាខណ្ឌ ៤០, ៤៨។

93. ដោយផ្អែកលើការលើកឡើងខាងលើ សហមេធាវីបានស្នើដល់អង្គបុរេជំនុំជម្រះ ឲ្យច្រានចោលការសម្រេចមិនទទួលស្គាល់របស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ចំពោះជនរងគ្រោះ ដែលត្រូវបានបដិសេធដោយផ្អែកលើមូលដ្ឋាន ទាក់ទងភាពមិនគ្រប់គ្រាន់ និងគុណភាពនៃព័ត៌មាន ហើយស្នើអង្គបុរេជំនុំជម្រះសម្រេចផ្តល់ឋានៈជាដើមបណ្តឹងរដ្ឋប្បវេណី ដល់ជនរងគ្រោះទាំងអស់នោះ[200]។

## ២. *ការពិភាក្សា*

94. អនុលោមតាមវិធាន ២៣ ស្ទួន (៤) នៃវិធានផ្ទៃក្នុង ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់ ចាំបាច់ត្រូវមានព័ត៌មានគ្រប់គ្រាន់ ដើម្បីអនុញ្ញាតឲ្យមានការផ្ទៀងផ្ទាត់ ពីការគោរពទៅតាមវិធានផ្ទៃក្នុង[201]។ ជាពិសេស "ពាក្យបណ្តឹងត្រូវផ្តល់ព័ត៌មានលម្អិត អំពីឋានៈជាជនរងគ្រោះ បញ្ជាក់អំពីប្រភេទឧក្រិដ្ឋកម្មដែលត្រូវចោទប្រកាន់ និងភ្ជាប់មកជាមួយនូវភស្តុតាង បញ្ជាក់អំពីព្យសនកម្មដែលទទួលរង ឬ ការបង្ហាញអំពីពិរុទ្ធភាពរបស់ឧក្រិដ្ឋជន ដែលត្រូវចោទប្រកាន់"[202]។ ដោយពិចារណាថាគោលដៅនិងគោលបំណង នៃវិធានទាំងអស់នេះ មិនមែន "សម្រាប់រឹតបន្តឹង ឬកំណត់ទៅលើសកម្មភាពរបស់ជនរងគ្រោះ ឬសកម្មភាពរបស់ដើមបណ្តឹងរដ្ឋប្បវេណី នៅ អ.វ.ត.ក" ប៉ុន្តែគ្រាន់តែដើម្បីកំណត់លក្ខណៈវិនិច្ឆ័យជាមូលដ្ឋាន សម្រាប់ភាពអាចទទួលយកបាន

[200] បណ្តឹងឧទ្ធរណ៍របស់ ដើមបណ្តឹងរដ្ឋប្បវេណី (ឯកសារ D362/5) កថាខណ្ឌ ៥១-៥២ (ការណ៍នេះពាក់ព័ន្ធជាមួយជនរងគ្រោះ ដែលបានកំណត់អត្តសញ្ញាណ ដោយសហមេធាវីនៅក្នុង ឧបសម្ព័ន្ធ ជ(១) និង ជ(២) នៃបណ្តឹងឧទ្ធរណ៍នេះ។ *សូមមើល* ឧបសម្ព័ន្ធ ជ(១)៖ ទទ្បីករណ៍លើភាពអាចទទួលយកបាន នៃអ្នកដាក់ពាក្យសុំតាំងខ្លួន ជាដើមបណ្តឹងរដ្ឋប្បវេណី ដែលត្រូវបានសម្រេចថាមិនអាចទទួលយកបាន ដោយសារមិនមានភស្តុតាងគ្រប់គ្រាន់ ឬមូលដ្ឋានពាក់ព័ន្ធ (អ្នកដាក់ពាក្យសុំតាំងខ្លួន ដែលមានមេធាវីតំណាងដោយ ក្រុមមេធាវីជាតិនិងអន្តរជាតិ) ឯកសារ D362/5.10។ ឧបសម្ព័ន្ធ ជ(២)៖ ៖ ទទ្បីករណ៍លើភាពអាចទទួលយកបាន នៃអ្នកដាក់ពាក្យសុំតាំងខ្លួន ជាដើមបណ្តឹងរដ្ឋប្បវេណី ដែលត្រូវបានសម្រេចថាមិនអាចទទួលយកបាន ដោយសារមិនមានភស្តុតាងគ្រប់គ្រាន់ ជាដើម (ក្រុមអ្នកច្បាប់ជាតិ) ឯកសារ D362/5.11)។

[201] វិធាន ២៣ ស្ទួន (៤) នៃវិធានផ្ទៃក្នុង. *សូមមើលផងដែរ* សេចក្តីណែនាំអនុវត្ត ស្តីពីការចូលរួមរបស់ជនរងគ្រោះ ខែកុម្ភៈ/ឆ្នាំ ២០០៧/វិសោធនកម្មលើកទីមួយ ធ្វើវិសោធនកម្មនៅថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៨ មាត្រា ៣.២, ៣.៥, ៣.៦។

[202] វិធាន ២៣ ស្ទួន (៤) នៃវិធានផ្ទៃក្នុង។

01647514



នោះ[203] អង្គបុរេជំនុំជម្រះបានអនុម័តចំពោះ "វិធីសាស្ត្របែបបត់បែន" ទាក់ទិននឹងលក្ខខណ្ឌតម្រូវសម្រាប់អ្នកដាក់ពាក្យសុំតាំងខ្លួនទាំងអស់ ដែលត្រូវបង្ហាញភស្តុតាងជាក់លាក់ អំពីអត្តសញ្ញាណរបស់ពួកគេ[204]។

95. ដោយអនុលោមតាមវិធាន ២៣ ស្ទួន (១) នៃវិធានផ្ទៃក្នុង នៅពេលពិចារណាលើភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីនោះ "សហចៅក្រមស៊ើបអង្កេតត្រូវតែមានជំនឿថា អង្គហេតុដែលគាំទ្រដល់ការដាក់ពាក្យសុំតាំងខ្លួន ជាដើមបណ្ដឹងរដ្ឋប្បវេណីនោះ មានភាពពិតប្រាកដ"[205]។ អង្គបុរេជំនុំជម្រះកត់សម្គាល់ថា នៅក្នុងដីកាសម្រេចដែលរងការជំទាស់ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានសម្រេចថាកត្តាកាលៈទេសៈជាក់លាក់ខ្លះ បានសម្រាលដល់កម្រិតនៃបន្ទុកបង្ហាញភស្តុតាង អំពីព្យសនកម្មតាមការតម្រូវ[206] ដូចជា ក) ពេលវេលាកន្លងផុតទៅយូរ ខ) សមត្ថភាពក្នុងការបង្ហាញ ក្នុងការកំណត់ និងធ្វើកំណត់ហេតុឱ្យបានត្រឹមត្រូវអំពីផលប៉ះពាល់លើសុខភាពផ្លូវចិត្ត និង គ) សមត្ថភាពក្នុងការផ្ដល់ភស្តុតាង បញ្ជាក់អំពីកម្មសិទ្ធិ និងប្រាក់ចំណូល ដោយសារតែការផ្លាស់ទីលំនៅដោយបង្ខំ ទៅលើប្រជាជន[207]។ អង្គបុរេជំនុំជម្រះពិចារណាថា វិធីសាស្ត្របែបបត់បែននេះ ចំពោះភស្តុតាងជាឯកសារ និងការបង្ហាញភស្តុតាងអំពីអត្តសញ្ញាណ គឺជាការសមស្រប ដោយពិចារណាទៅលើមូលដ្ឋានសង្គម និងវប្បធម៌ជាក់លាក់ជា

---

[203] សំណុំរឿង ០០២ សាលដីកាលើបណ្ដឹងឧទ្ធរណ៍ របស់ដើមបណ្ដឹងរដ្ឋប្បវេណី (ឯកសារ D404/2/4) កថាខណ្ឌ ៦២។ សំណុំរឿង ០០២ សាលដីកាលើបណ្ដឹងឧទ្ធរណ៍ របស់ដើមបណ្ដឹងរដ្ឋប្បវេណី (ឯកសារ D411/3/6) កថាខណ្ឌ ៦២។

[204] សំណុំរឿង ០០២ សាលដីកាលើបណ្ដឹងឧទ្ធរណ៍ របស់ដើមបណ្ដឹងរដ្ឋប្បវេណី (ឯកសារ D404/2/4) កថាខណ្ឌ ៩៥។ សំណុំរឿង ០០២ សាលដីកាលើបណ្ដឹងឧទ្ធរណ៍ របស់ដើមបណ្ដឹងរដ្ឋប្បវេណី (ឯកសារ D411/3/6) កថាខណ្ឌ ៩៥។

[205] វិធាន ២៣ ស្ទួន (១) នៃវិធានផ្ទៃក្នុង។ *សូមមើលផងដែរ* សំណុំរឿង ០០២ សាលដីកាលើបណ្ដឹងឧទ្ធរណ៍ របស់ដើមបណ្ដឹងរដ្ឋប្បវេណី (ឯកសារ D404/2/4) កថាខណ្ឌ ៨៤។ សំណុំរឿង ០០២ សាលដីកាលើបណ្ដឹងឧទ្ធរណ៍ របស់ដើមបណ្ដឹងរដ្ឋប្បវេណី (ឯកសារ D411/3/6) កថាខណ្ឌ ៨៤។

[206] ដីកាសម្រេចលើដើមបណ្ដឹងរដ្ឋប្បវេណី (សហចៅក្រមស៊ើបអង្កេតអន្តរជាតិ) (ឯកសារ D362) កថាខណ្ឌ ៤២។

[207] ដីកាសម្រេចលើដើមបណ្ដឹងរដ្ឋប្បវេណី (សហចៅក្រមស៊ើបអង្កេតអន្តរជាតិ) (ឯកសារ D362) កថាខណ្ឌ ៤១។

01647515



ពិសេស របស់កម្ពុជា និងកម្រិតជាក់ស្តែងនៃភស្តុតាង ដែលអាចរកបាន ក្រោយពេលបញ្ចប់អំពើសាហាវយង់ឃ្នង ជាទ្រង់ទ្រាយធំ ដែលត្រូវបានចោទប្រកាន់នៅក្នុងសំណុំរឿងនេះ[208]។

96. អង្គបុរេជំនុំជម្រះបានត្រួតពិនិត្យយ៉ាងម៉ត់ចត់ ទៅលើទឡ្ហីករណ៍របស់សហមេធាវី ដែលបានលើកឡើងនៅក្នុង ឧបសម្ព័ន្ធ ជ(១) និង ជ(២) នៃបណ្តឹងឧទ្ធរណ៍ ដើម្បីច្រានចោលការសម្រេចមិនទទួលស្គាល់ ដោយសហចៅក្រមស៊ើបអង្កេតអន្តរជាតិ។ ក្នុងន័យនេះ អង្គបុរេជំនុំជម្រះ បានត្រួតពិនិត្យយ៉ាងប្រុងប្រយ័ត្ន ទៅលើព័ត៌មានដែលផ្តល់ឲ្យដោយអ្នកដាក់ពាក្យសុំតាំងខ្លួន ជាដើមបណ្តឹងរដ្ឋប្បវេណី[209] ដើម្បីវាយតម្លៃថាតើ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ មានកំហុសឆ្គងឬទេ ក្នុងការវាយតម្លៃរបស់គាត់ថាតើ "មានភាពពិតប្រាកដ" ដែលអ្នកដាក់ពាក្យសុំ បានទទួលរងព្យសនកម្ម ពីឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើង នៅក្នុងភូមិភាគកណ្តាលពីចុងឆ្នាំ១៩៧៦ ដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩ នៅក្នុងវិសាលភាពពេលវេលា ឬទីកន្លែង នៃសំណុំរឿង[210]។ ដោយភ្ជាប់ជាឧបសម្ព័ន្ធ ២ គឺសេចក្តីពិចារណារបស់អង្គបុរេជំនុំជម្រះ ទាក់ទងនឹងសារណានីមួយៗទាំងអស់នេះ។ បន្ទាប់ពីបានត្រួតពិនិត្យទៅលើពាក្យសុំតាំងខ្លួននៅក្នុងឧបសម្ព័ន្ធ ២ អង្គជំនុំជម្រះសម្រេចថា សហចៅក្រមស៊ើបអង្កេត មានកំហុសឆ្គងក្នុងសេចក្តីសម្រេចរបស់គាត់ លើភាពអាចទទួលយកបានចំពោះអ្នកដាក់ពាក្យសុំតាំងខ្លួន ជាដើមបណ្តឹងរដ្ឋប្បវេណី ចំនួនប្រាំបីរូប ហើយពិចារណាថា ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីទាំងប្រាំបីដូចខាងក្រោម គួរត្រូវបានទទួលស្គាល់ ដូច

[208] *សូមមើល* សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍ របស់ដើមបណ្តឹងរដ្ឋប្បវេណី (ឯកសារ D404/2/4) កថាខណ្ឌ ៨៣, ៩៥។ សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍ របស់ដើមបណ្តឹងរដ្ឋប្បវេណី (ឯកសារ D411/3/6) កថាខណ្ឌ ៨៣, ៩៥។

[209] នៅពេលត្រួតពិនិត្យលើពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី អង្គជំនុំជម្រះបានពិនិត្យទៅលើ ទម្រង់ព័ត៌មានជនរងគ្រោះ និងឧបសម្ព័ន្ធនានា ហើយក្នុងករណីដែលមាន ពិនិត្យទៅលើព័ត៌មានបន្ថែម របាយការណ៍សង្ខេប កំណត់ហេតុស្តាប់ចម្លើយ និងប្រតិចារឹកនៃសក្ខីកម្មក្នុងតុលាការ ដែលអ្នកដាក់ពាក្យសុំបានផ្តល់ នៅចំពោះមុខ អ.វ.ត.ក។

[210] វិធាន ២៣ ស្ទួន នៃវិធានផ្ទៃក្នុង។ ដីកាសម្រេចលើដើមបណ្តឹងរដ្ឋប្បវេណី (សហចៅក្រមស៊ើបអង្កេតអន្តរជាតិ) (ឯកសារ D362) កថាខណ្ឌ ៣៧-៣៩។

មានផ្តល់ជាសំអាងហេតុនៅក្នុងឧបសម្ព័ន្ធ ២៖16-VSS-00048; 15-VSS-00038; 16-VSS-00042; 16-VSS-00015; 16-VSS-00020; 11-VSS-00032; 11-VSS-00058; និង 12-VSS-00672។[211]

## ខ. មូលដ្ឋានទី ៥÷ ការចោទប្រកាន់ពីការរំលោភលើសិទ្ធិរបស់ជនរងគ្រោះក្នុងការទទួលបានព័ត៌មាន

### *១. សារណា*

97. នៅក្នុងមូលដ្ឋានទី ៥ សហមេធាវីលើកឡើងថា សហចៅក្រមស៊ើបអង្កេតបានរំលោភលើសិទ្ធិរបស់ជនរងគ្រោះក្នុងការទទួលបានព័ត៌មានត្រឹមត្រូវ និងទាន់ពេលវេលានៅក្នុងកិច្ចដំណើរការនីតិវិធីទាំងមូលដែលជាការរំលោភលើវិធាន ២១(១)(គ) នៃវិធានផ្ទៃក្នុង។

98. ជាបឋម សហមេធាវីរម្លឹកនូវការសម្រេចរបស់អង្គបុរេជំនុំជម្រះពាក់ព័ន្ធនឹងសិទ្ធិមួយចំនួនរបស់ជនរងគ្រោះដែលមានចែងក្នុងវិធាន ២១(១)(គ) នៃវិធានផ្ទៃក្នុង[212] ដោយគូសបញ្ជាក់ថា វិធានផ្ទៃក្នុងត្រូវតែអានជាលក្ខណៈមួយដែលការពារដល់ផលប្រយោជន៍របស់ជនរងគ្រោះ[213]។ ទោះបីសហមេធាវីទទួលស្គាល់ថា សហចៅក្រមស៊ើបអង្កេតចងភ្ជាប់កិច្ចដោយវិធានផ្ទៃក្នុងស្តីពីការរក្សាការសម្ងាត់នៃការស៊ើបអង្កេតក្តី តែពួកគេអះអាងថា បទប្បញ្ញត្តិទាំងនេះគួរអានរួមជាមួយគោលការណ៍ជាសារវន្តនៃនីតិវិធីនៅចំពោះមុខ អ.វ.ត.ក ដែលតម្រូវឱ្យ "ជូនដំណឹងដល់ជនរងគ្រោះ" ហើយថា "សិទ្ធិរបស់ជនរងគ្រោះត្រូវបានគោរព*នៅពេញ*ដំណើរការនីតិវិធី"[214]

---

[211] អង្គជំនុំជម្រះសូមកត់សម្គាល់ថា អ្នកដាក់ពាក្យសុំបីនាក់ ក្នុងចំណោមប្រាំបីនាក់ (16-VSS-00020, 11-VSS-00032 និង 12-VSS-00672) ក៏ត្រូវបានដាក់ និងពិចារណាតាមមូលដ្ឋានទីពីរ ដែលក្នុងមូលដ្ឋាននោះ អង្គជំនុំជម្រះសម្រេចថា ពួកគាត់គួរត្រូវបានទទួលស្គាល់ ក្នុងលក្ខណៈប្រហែលគ្នា ដូចខាងលើដែរ។

[212] បណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (D362/5) កថាខណ្ឌ ៥៣ *យោងទៅ* វិធាន ២១(១)(គ) នៃវិធានផ្ទៃក្នុង។

[213] បណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (D362/5) កថាខណ្ឌ ៥៣ *យោងទៅ* សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (D404/2/4) កថាខណ្ឌ ៦១។

[214] បណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (D362/5) កថាខណ្ឌ *៥៤ យោងទៅ* សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (D404/2/4) កថាខណ្ឌ ៥២។

ដែលមិនបានទុកចន្លោះប្រហោងសម្រាប់ការបកស្រាយនោះឡើយ[215]។

99. ជាងនេះទៀត សហមេធាវីសូមអះអាងថា ការទទួលបានព័ត៌មានត្រឹមត្រូវ និងទាន់ពេលវេលាគឺជាគន្លឹះជាពិសេសមួយសម្រាប់ជនរងគ្រោះដែលស្នើសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដោយសារពួកគេអាចចូលពិនិត្យមើលសំណុំរឿងបាន និងសំអាងទៅលើព័ត៌មានដែលផ្សព្វផ្សាយដោយសហចៅក្រមស៊ើបអង្កេត[216]។ សហចៅក្រមស៊ើបអង្កេតមិនបានជូនដំណឹងដល់ជនរងគ្រោះទេ ដោយសារពួកគាត់ដាក់បង្ហាញតែទីតាំងឧក្រិដ្ឋកម្មដែលពាក់ព័ន្ធ ទៅឱ្យជនរងគ្រោះបានដឹង បីឆ្នាំក្រោយពេលដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទី៣ នៅថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០៨ ប៉ុណ្ណោះ[217]។ ជាងនេះទៀត នៅក្នុងការដាក់បង្ហាញលើកទីមួយអំពីទីតាំងឧក្រិដ្ឋកម្មក្នុងសំណុំរឿង ០០៤ នោះ សហចៅក្រមស៊ើបអង្កេតបានធ្វើឱ្យមានការភាន់ច្រឡំ និងធ្វើឱ្យបាត់បង់ទំនុកចិត្តពីជនរងគ្រោះចំពោះលទ្ធផលនៃការស៊ើបអង្កេតដោយបង្ហាញនូវការកត់សម្គាល់អំពី ""វិមតិសង្ស័យច្បាស់លាស់" របស់ខ្លួនអំពីថា តើសំណុំរឿង ០០៤ នឹងបន្តទៅមុខដែរឬអត់"[218]។

100. សហមេធាវីលើកឡើងថា ការខកខានរបស់សហចៅក្រមស៊ើបអង្កេតក្នុងការដាក់បង្ហាញព័ត៌មានឱ្យបានទាន់ពេលវេលា "រារាំងពួកគេក្នុងការវិភាគសមស្របលើភស្តុតាងដែលពាក់ព័ន្ធ និងជាចុងក្រោយកម្រិតសមត្ថភាព របស់ពួកគេក្នុងការផ្តល់ព័ត៌មានពិស្តារពាក់ព័ន្ធនឹងព្យសនកម្មពាក់ព័ន្ធ"[219]។ ពួកគេជំរុញឱ្យអង្គបុរេជំនុំជម្រះគួរ "ពិចារណាលើការរំលោភសិទ្ធិរបស់ជនរងគ្រោះនេះ នៅពេលពិនិត្យលើការបដិសេធក្នុងដីកាដែលរងការជំទាស់" ចំពោះពាក្យសុំ

[215] បណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (D362/5) កថាខណ្ឌ ៥៤ *យោងទៅ* សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (D404/2/4) កថាខណ្ឌ ៥២។

[216] បណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (D362/5) កថាខណ្ឌ ៥៥។

[217] បណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (D362/5) កថាខណ្ឌ ៥៥។

[218] បណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (D362/5) កថាខណ្ឌ ៥៥ *យោងទៅ* សេចក្តីប្រកាសព័ត៌មានរបស់ អ.វ.ត.ក "សេចក្តីប្រកាសព័ត៌មានរបស់សហចៅក្រមស៊ើបអង្កេតទាក់ទងនឹងដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿង ០០៤ (០០៤/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស)" ថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១១ អាចរកបាននៅលើគេហទំព័រ៖ https://www.eccc.gov.kh/en/document/public-affair/press-release-co-investigating-judges-regarding-civil-parties-case-004។

[219] បណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (D362/5) កថាខណ្ឌ ៥៦-៥៧។

តាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី[220]។

## ២. *ការពិភាក្សា*

101. ជាបឋម អង្គបុរេជំនុំជម្រះនឹងពិភាក្សាអំពីច្បាប់ជាធរមានចំពោះការវាយតម្លៃទៅលើកាតព្វកិច្ចរបស់សហចៅក្រមស៊ើបអង្កេតអនុលោមតាមវិធាន ២១(១)(គ) នៃវិធានផ្ទៃក្នុង។ បន្ទាប់មកអង្គជំនុំជម្រះនឹងវាយតម្លៃថា តើសហចៅក្រមស៊ើបអង្កេតបានរំលោភបំពានទៅលើកាតព្វកិច្ចទាំងនេះ ឬយ៉ាង ដោយផ្អែកលើប្រវត្តិនីតិវិធីនៃសំណុំរឿង ០០៤ (ពាក់ព័ន្ធនឹង អោ អាន) និងសំណុំរឿង ០០៤/២ និងសំណួមពរ ប្រសិនបើមាន។

102. វិធាន ២១(១)(គ) នៃវិធានផ្ទៃក្នុងចែងថា "អ.វ.ត.ក *ត្រូវ*ធានាថា ជនរងគ្រោះត្រូវទទួលបានការជូនព័ត៌មាន ហើយសិទ្ធិរបស់ជនរងគ្រោះ ត្រូវបានការពារ*ក្នុងអំឡុងពេល*នៃដំណើរការនីតិវិធីរឿងក្តី"[221]។ ហេតុនេះ ក្នុងការបំពេញកាតព្វកិច្ចរបស់ខ្លួនក្នុងការជូនព័ត៌មានដល់ជនរងគ្រោះឱ្យបានត្រឹមត្រូវ និងទាន់ពេលវេលានោះ សហចៅក្រមស៊ើបអង្កេតត្រូវបំពេញការងារដោយយកចិត្តទុកដាក់ ក្នុងការការពារផលប្រយោជន៍ និងសិទ្ធិរបស់ជនរងគ្រោះ*ក្នុងអំឡុងពេល*នៃដំណាក់កាលស៊ើបអង្កេតទាំងមូល[222]។

103. ទោះបីបទប្បញ្ញត្តិជាក់លាក់មួយចំនួនក្នុងវិធានផ្ទៃក្នុង ទាក់ទងនឹងការរក្សាការសម្ងាត់នៃការស៊ើបអង្កេត ធ្វើឱ្យមានការរឹតបន្តឹងទៅលើព័ត៌មានដែលសហចៅក្រមស៊ើបអង្កេត អាចជម្រាបជូនដល់សាធារណជន[223] ក្តី តែបទប្បញ្ញត្តិទាំងនេះ "ត្រូវបកស្រាយគ្រប់ពេលវេលា ដោយភ្ជាប់

[220] បណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (D362/5) កថាខណ្ឌ ៥៧។

[221] វិធាន ២១(១)(គ) នៃវិធានផ្ទៃក្នុង (គូសបញ្ជាក់បន្ថែម)។

[222] សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (D404/2/4) កថាខណ្ឌ ៥១-៥២។ សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (D411/3/6) កថាខណ្ឌ ៥១-៥២។ *សូមមើលផងដែរ* សំណុំរឿង ០០៤ (អបជ ០១) សេចក្តីពិចារណារបស់អង្គបុរេជំនុំជម្រះ ទាក់ទិននឹងបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចស្តីពីការទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ សេង ចាន់ធារី ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១២ ឯកសារ D5/1/4/2 (មតិយោបល់របស់ចៅក្រម DOWNING និងចៅក្រម LAHUIS) កថាខណ្ឌ ៦។

[223] *សូមមើលឧទាហរណ៍* វិធាន ៥៦(១) នៃវិធានផ្ទៃក្នុង។ *សូមមើលជាទូទៅ* សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (D404/2/4) កថាខណ្ឌ ៥២។ សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (D411/3/6) កថាខណ្ឌ ៥២។

ជាមួយបទប្បញ្ញត្តិស្តីពីគោលការណ៍ជាសារវ័ន្តនៃដំណើរការនីតិវិធីនៅចំពោះមុខ អ.វ.ត.ក" ដែលវិធាន ២១(១)(គ) នៃវិធានផ្ទៃក្នុង បង្កើតជាផ្នែករួមមួយ[224]។ ដូចដែលអង្គបុរេជំនុំជម្រះបាន ទទួលស្គាល់គឺថា ជនរងគ្រោះពឹងផ្អែកទាំងស្រុងលើព័ត៌មានដែលផ្សព្វផ្សាយដោយសហចៅក្រម ស៊ើបអង្កេត ដើម្បីត្រួសត្រាយផ្លូវក្នុងការចូលរួមរបស់ខ្លួនទៅក្នុងកិច្ចដំណើរការនីតិវិធីនៅ អ.វ.ត.ក នៅដំណាក់កាលមុនការជំនុំជម្រះ ដោយសារពួកគេពុំមានសិទ្ធិចូលពិនិត្យមើល សំណុំរឿងដោយស្វ័យប្រវត្តិនោះឡើយ[225]។ ហេតុនេះ អង្គជំនុំជម្រះនឹងដំណើរការវាយតម្លៃ ពីការយកចិត្តទុកដាក់បំពេញការងាររបស់សហចៅក្រមស៊ើបអង្កេត ក្នុងការផ្តល់ព័ត៌មានដល់ ជនរងគ្រោះ ក្នុងអំឡុងពេលកិច្ចដំណើរការនីតិវិធីមុនការជំនុំជម្រះនេះ។

104. ជាពិសេស សហមេធាវីជំទាស់ចំពោះការមិនដាក់បង្ហាញរបស់សហចៅក្រមស៊ើបអង្កេតក្នុងរយៈ ពេលពីថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០៨ រហូតមកដល់ពេលចេញសេចក្តីប្រកាសព័ត៌មានលើកទីមួយ របស់ខ្លួនអំពីការស៊ើបអង្កេតក្នុងសំណុំរឿង ០០៤ ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១១ ("សេចក្តីប្រកាសព័ត៌មានខែសីហា ឆ្នាំ២០១១")[226]។ នាពេលនេះ អង្គជំនុំជម្រះនឹងធ្វើការវាយតម្លៃ ទៅលើការអះអាងនេះ។

105. ទាក់ទិននឹងរយៈពេលពីថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០០៩ (ការបញ្ជូនដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើប សួរលើកទី៣ ទៅការិយាល័យសហចៅក្រមស៊ើបអង្កេត)[227] រហូតដល់ពេលចេញសេចក្តី

---

[224] សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (D404/2/4) កថាខណ្ឌ ៥២។ សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (D411/3/6) កថាខណ្ឌ ៥២។

[225] សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (D404/2/4) កថាខណ្ឌ ៥២។ សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (D411/3/6) កថាខណ្ឌ ៥២។ *សូមមើលផងដែរ* គោលការណ៍ សម្រាប់ជនរងគ្រោះឆ្នាំ១៩៨៥ មាត្រា ៦ ("ការឆ្លើយតបនៃដំណើរការតាមផ្លូវតុលាការ និងរដ្ឋបាលទៅតាមតម្រូវការចាំបាច់ របស់ជនរងគ្រោះគួរត្រូវបានសម្រួលដោយ៖ (១) ជូនព័ត៌មានដល់ជនរងគ្រោះអំពីតួនាទីរបស់ពួកគេ និង វិសាលភាព ពេលវេលា និងវឌ្ឍនភាពនៃកិច្ចដំណើរការនីតិវិធី និងការសម្រេចសេចក្តីទៅលើរឿងក្តីរបស់ពួកគេ ជាពិសេស នៅពេលមាន ការពាក់ព័ន្ធនឹងបទល្មើសធ្ងន់ធ្ងរ និងនៅពេលដែលពួកគេស្នើសុំព័ត៌មានទាំងនេះ")។

[226] *សូមមើល* បណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (D362/5) កថាខណ្ឌ ៥៥។

[227] ទោះបីការពិតថា ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទី៣ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០៨ ក៏ដោយ ក៏អង្គបុរេជំនុំជម្រះ សូមរម្លឹកថា ដីកានេះស្ថិតក្នុងករណីខ្វែងយោបល់គ្នារវាងសហព្រះរាជអាជ្ញាទាំងពីររូប។ រហូតដល់ថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០០៩ ទើបដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទី៣ ត្រូវបានបញ្ជូនទៅការិយាល័យសហចៅក្រមស៊ើបអង្កេត ដើម្បីបើកកិច្ចស៊ើប

ប្រកាសព័ត៌មានខែសីហា ឆ្នាំ២០១១ អង្គជំនុំជម្រះយល់ឃើញថា សហចៅក្រមស៊ើបអង្កេតមិនបានជូនព័ត៌មានដល់ជនរងគ្រោះឱ្យបានត្រឹមត្រូវ និងទាន់ពេលវេលាអំពីការស៊ើបអង្កេតទៅលើ អោ អាន ទេ ដែលជាការរំលោភលើវិធាន ២១(១)(គ) នៃវិធានផ្ទៃក្នុង។

106. សហចៅក្រមស៊ើបអង្កេតបានផ្តល់សំអាងហេតុចំពោះការពន្យារពេល ជូនព័ត៌មានអំពីទីតាំងឧក្រិដ្ឋកម្ម និងព្រឹត្តិការណ៍នៃបទឧក្រិដ្ឋនានាដែលស្ថិតក្នុងការស៊ើបអង្កេត រហូតដល់ថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១១ គឺដោយសារ "វិមតិសង្ស័យ" របស់ខ្លួនអំពីសមត្ថកិច្ចយុត្តាធិការរបស់តុលាការ។ ជាពិសេស៖

> ក្នុងរយៈកាលកន្លងមក ការិយាល័យសហចៅក្រមស៊ើបអង្កេតមិនបានធ្វើការជូនដំណឹងដល់សាធារណជនអំពីទីតាំងឧក្រិដ្ឋកម្មនៅក្នុងសំណុំរឿង ០០៤ នោះទេ ដោយហេតុថា ដោយខុសពីសំណុំរឿង ០០២ សំណុំរឿង ០០៤ មានវិមតិសង្ស័យជាក់ច្បាស់ថាតើជនសង្ស័យនៅក្នុងសំណុំរឿងនេះស្ថិតនៅក្នុងប្រភេទនៃ "អ្នកទទួលខុសត្រូវខ្ពស់បំផុត" ស្របតាមមាត្រា ២ ស្តីអំពីសមត្ថកិច្ចយុត្តាធិការនៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ដែរឬយ៉ាងណា។ ប្រសិនបើតុលាការមិនមានយុត្តាធិការទេនោះ វានឹងមិនមែនជារឿងសមស្របនោះឡើយ ក្នុងការដែលត្រូវជំរុញឱ្យមានការដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី បន្ថែមទៅលើពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីដែលទទួលបានចំនួន ២០០ រួចមកហើយនៅក្នុងសំណុំរឿងនេះ ព្រោះថា ការណ៍នេះអាចនឹងបង្កើតឱ្យមានការរំពឹងទុក ឬក្តីសង្ឃឹម ដែលនឹងមិនអាចសម្រេចបាននាពេលក្រោយតែប៉ុណ្ណោះ។ ទោះជាយ៉ាងណាក្តី ដោយយោងទៅលើហេតុដែលថា មានការកើនឡើងជាខ្លាំងនូវព័ត៌មានដែលមានលក្ខណៈជាការប៉ាន់ស្មាន និងភ័ន្តច្រឡំ ដែលបានចុះផ្សាយនៅក្នុងប្រព័ន្ធផ្សព្វផ្សាយនានា និងនៅលើគេហទំព័រមួយជាក់លាក់ យើងសូមធ្វើការផ្តល់ជូននូវព័ត៌មានដូចខាងក្រោម ដោយនឹងមិនធ្វើឱ្យប៉ះពាល់ដល់បញ្ហាច្បាប់

---

ស្តីប្រឆាំង អោ អាន ក្រោយពេលអង្គបុរេជំនុំជម្រះបានចេញសេចក្តីពិចារណារបស់ខ្លួនលើករណីខ្វែងយោបល់នេះ។ ហេតុនេះ អង្គជំនុំជម្រះនឹងយកចំណុចនេះជាការចាប់ផ្តើមសមរម្យ ដើម្បីវាយតម្លៃទៅលើការអនុវត្តរបស់សហចៅក្រមស៊ើបអង្កេតថាតើវាស្រប ឬមិនស្របទៅនឹងភារកិច្ចរបស់ខ្លួនដែលមានចែងក្នុងវិធាន ២១(១)(គ) នៃវិធានផ្ទៃក្នុងនោះ។

មួយចំនួន ដែលនឹងត្រូវដោះស្រាយនៅក្នុងដីកាដំណោះស្រាយឡើយ [...][228]។

107. អង្គបុរេជំនុំជម្រះយល់ឃើញថា ចំណុចខាងលើពុំមែនជាសំអាងហេតុត្រឹមត្រូវដើម្បីលាក់បាំងព័ត៌មានមិនឱ្យជនរងគ្រោះដឹង អំពីបញ្ហានានាដែលស្ថិតក្រោមការស៊ើបអង្កេតនោះទេ ពាក់ព័ន្ធនឹងអាណត្តិការងាររបស់សហចៅក្រមស៊ើបអង្កេតដែលត្រូវជូនព័ត៌មានដល់ជនរងគ្រោះ អនុលោមតាមវិធាន ២១(១)(គ) នៃវិធានផ្ទៃក្នុង។ អង្គជំនុំជម្រះសូមរម្លឹកថា ជនរងគ្រោះអាចដាក់ជូននូវព័ត៌មាននានាដែលពាក់ព័ន្ធនឹងការវាយតម្លៃទៅលើយុត្តាធិការបុគ្គលរបស់តុលាការ ជាពិសេសតួនាទីដែលជនសង្ស័យអាចមាន ពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មដែលបានចោទប្រកាន់[229]។ រយៈពេលពីរឆ្នាំចាប់ពីការបើកកិច្ចស៊ើបសួរប្រឆាំង អោ អាន និង ការចេញសេចក្តីប្រកាសព័ត៌មានខែសីហា ឆ្នាំ ២០១១ សហចៅក្រមស៊ើបអង្កេតមានកាតព្វកិច្ចត្រូវដាក់ជូនព័ត៌មាន ដើម្បីឱ្យជនរងគ្រោះដែលមានផលប្រយោជន៍ អាចចាប់ផ្តើមរៀបចំពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីឱ្យបានពេញលេញ[230]។ ការពិត ក្រោយមក សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានធ្វើការដាក់បង្ហាញ "អនុលោមតាមវិធាន ២១(១)(គ) នៃវិធានផ្ទៃក្នុង" ដើម្បីជូនព័ត៌មានដល់ជនរងគ្រោះអំពីទីតាំងឧក្រិដ្ឋកម្មបន្ថែមដែលស្ថិតក្នុងការស៊ើបអង្កេតក្នុងសំណុំរឿង ០០៤ នៅខែធ្នូ ឆ្នាំ២០១២[231]។

108. ជាងនេះទៀត អង្គបុរេជំនុំជម្រះរម្លឹកថា កន្លងមក នៅក្នុងសំណុំរឿង ០០២ អង្គជំនុំជម្រះបាន

[228] សេចក្តីប្រកាសព័ត៌មានរបស់ អ.វ.ត.ក "សេចក្តីប្រកាសព័ត៌មានរបស់សហចៅក្រមស៊ើបអង្កេតទាក់ទងនឹងដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿង ០០៤ (០០៤/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស)" ថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១១ អាចរកមើលបាននៅលើគេហទំព័រ៖ https://www.eccc.gov.kh/en/document/public-affair/press-release-co-investigating-judges-regarding-civil-parties-case-004។

[229] *សូមមើល* សំណុំរឿង ០០៤/១ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងដីកាដំណោះស្រាយ (សំអាងហេតុ) (D308/3/1/20) កថាខណ្ឌ ៥៥។ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងដីកាដំណោះស្រាយ (D359/24 & D360/33) កថាខណ្ឌ ៨១។

[230] *សូមមើល* សំណុំរឿង ០០៤ (អបជ ០២) សេចក្តីពិចារណារបស់អង្គបុរេជំនុំជម្រះ ទាក់ទិននឹងបណ្តឹងជំទាស់នឹងដីកាសម្រេចលើការទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់លោក Robert Hamill ចុះថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០១២ ឯកសារ D5/2/4/3 (មតិយោបល់របស់ចៅក្រម DOWNING និងចៅក្រម LAHUIS) កថាខណ្ឌ ៦។

[231] សេចក្តីប្រកាសព័ត៌មានរបស់ អ.វ.ត.ក "សេចក្តីប្រកាសរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិទាក់ទងនឹងទីតាំងឧក្រិដ្ឋកម្មបន្ថែមនៅក្នុងសំណុំរឿង ០០៤" ថ្ងៃទៅ១៩ ខែធ្នូ ឆ្នាំ២០១២ អាចរកមើលបាននៅលើគេហទំព័រ៖ https://www.eccc.gov.kh/en/document/public-affair/statement-international-co-investigating-judge-regarding-additional-crime-sit។

សន្និដ្ឋានថា សហចៅក្រមស៊ើបអង្កេតមិនបានផ្តល់ព័ត៌មានជូនជនរងគ្រោះ ឲ្យបានទាន់ពេលវេលាទេ ចំណែកឯការដាក់បង្ហាញរបស់ពួកគេជាសាធារណៈអំពីការស៊ើបអង្កេតត្រូវបានចេញនៅថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០០៩ ប្រហែលជាពីរឆ្នាំក្រោយពេលសំណុំរឿង ០០២ បានបង្កើតឡើងនៅថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០០៧[232]។ ការពន្យារពេលពីរឆ្នាំស្រដៀងគ្នានៅក្នុងសំណុំរឿងនេះក៏បណ្តាលឲ្យមានការរំលោភលើវិធាន ២១(១)(គ) នៃវិធានផ្ទៃក្នុងដូចគ្នាដែរ ជាពិសេសនៅពេលដែលពុំមានយុត្តិកម្មឲ្យបានត្រឹមត្រូវចំពោះការពន្យារពេលនេះ។

109. ទោះបីមានការរំលោភបំពាននេះក៏ដោយ តែក្នុងការវាយតម្លៃពីសំណូមពរ អង្គបុរេជំនុំជម្រះសង្កេតឃើញថា ព្យសនកម្មនានាចំពោះជនរងគ្រោះដោយសារការពន្យារពេលផ្តល់ព័ត៌មាននោះហាក់ដូចជាមានភាពតិចតួចនៅក្នុងកាលៈទេសៈទាំងនេះ។ ជាពិសេស រយៈពេលជាច្រើនឆ្នាំបានកន្លងផុតទៅ បន្ទាប់ពីព័ត៌មានពាក់ព័ន្ធអំពីការស៊ើបអង្កេតត្រូវបានផ្សព្វផ្សាយជាសាធារណៈ[233] រហូតដល់កាលបរិច្ឆេទចុងក្រោយសម្រាប់ដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដូចដែលនឹងពិភាក្សាខាងក្រោមនេះ។

110. នៅក្នុងចំណុចនេះ អនុលោមតាមវិធាន ២៣*ស្ទួន*(២) នៃវិធានផ្ទៃក្នុង "ជនរងគ្រោះដែលមានបំណងចង់តាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ត្រូវដាក់ពាក្យសុំជាលាយលក្ខណ៍អក្សរ យ៉ាងយូរ(១៥)ថ្ងៃបន្ទាប់ពីសហចៅក្រមស៊ើបអង្កេតជូនដំណឹងដល់ភាគីទាំងអស់ អំពីការបញ្ចប់កិច្ចស៊ើបសួរតាមផ្លូវតុលាការដោយអនុលោមតាមវិធាន ៦៦(១)"។ សហចៅក្រមស៊ើបអង្កេតបានជូនដំណឹងអំពីការបញ្ចប់កិច្ចស៊ើបសួរទៅលើ អោ អាន ចំនួនពីរដង នៅថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៦ និងថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១៧ ជាបន្តបន្ទាប់[234]។ អង្គបុរេជំនុំជម្រះសូមរម្លឹកឡើងវិញនូវ

---

[232] *សូមមើល* សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (D404/2/4) កថាខណ្ឌ ៥១-៥៤។ សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (D411/3/6) កថាខណ្ឌ ៥១-៥៤។

[233] *សូមមើល* សេចក្តីប្រកាសព័ត៌មានរបស់ អ.វ.ត.ក "សេចក្តីប្រកាសព័ត៌មានរបស់សហចៅក្រមស៊ើបអង្កេតទាក់ទងនឹងដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿង ០០៤ (០០៤/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស)" ថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១១ អាចរកមើលបាននៅលើគេហទំព័រ៖ https://www.eccc.gov.kh/en/document/public-affair/press-release-co-investigating-judges-regarding-civil-parties-case-004។

[234] សេចក្តីជូនដំណឹងលើកទី១ អនុលោមតាមវិធាន ៦៦(១) (D334)។ សេចក្តីជូនដំណឹងលើកទី២ អនុលោមតាមវិធាន ៦៦(១) (D334/2)។

ការសន្និដ្ឋានពីមុនរបស់ខ្លួនដែលថា សហចៅក្រមស៊ើបអង្កេតបានប្រព្រឹត្តកំហុសឆ្គងផ្នែកនីតិវិធី ក្នុងការមិនអនុញ្ញាតឱ្យភាគីអាចដាក់ពាក្យសុំបំពេញកិច្ចស៊ើបសួរបន្ថែមទៀតបាន រយៈពេល ១៥ ថ្ងៃ ក្រោយពីថ្ងៃជូនដំណឹងលើកទីពីរ អំពីការបញ្ចប់កិច្ចស៊ើបសួរនោះ[235]។ អង្គជំនុំជម្រះយល់ឃើញថា ការសម្រេចនេះអនុវត្តស្មើគ្នាចំពោះដើមបណ្តឹងរដ្ឋប្បវេណីដែរ ហេតុនេះហើយ ជនរងគ្រោះមានសិទ្ធិដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរយៈពេល ១៥ថ្ងៃ ក្រោយពីថ្ងៃជូនដំណឹងលើកទីពីរ អំពីការបញ្ចប់កិច្ចស៊ើបសួរ[236]។

111. សរុបមក ទោះបីអង្គបុរេជំនុំជម្រះសន្និដ្ឋានថា សហចៅក្រមស៊ើបអង្កេតបានរំលោភទៅលើកាតព្វកិច្ចរបស់ខ្លួនក្នុងការជូនព័ត៌មានឱ្យបានទាន់ពេលវេលាដល់ជនរងគ្រោះក៏ដោយ តែព្យសនកម្មដែលបណ្តាលមកពីការមិនបំពេញកាតព្វកិច្ចហាក់ដូចជាមានភាពតិចតួចទេ[237]។ រយៈពេលជាច្រើនឆ្នាំដែលបានកន្លងទៅ ដើម្បីឱ្យជនរងគ្រោះអាចរៀបចំពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ហាក់ដូចជាសម្រាលដល់ព្យសនកម្មនានា ដែលអាចបណ្តាលមកពីការពន្យារពេលដាក់បង្ហាញព័ត៌មាននៃការស៊ើបអង្កេតរបស់សហចៅក្រមស៊ើបអង្កេត បើទោះបីមិនអាចលុបបំបាត់បានដោយសារបញ្ហាការអនុវត្តន៍ជាក់ស្តែង[238] ក៏ដោយ។

---

[235] សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងដីកាដំណោះស្រាយ (D359/24 & D360/33) កថាខណ្ឌ ៦៥។

[236] សេចក្តីជូនដំណឹងលើកទី២ អនុលោមតាមវិធាន ៦៦(១) (D334/2)។ ហេតុនេះ កាលបរិច្ឆេទចុងក្រោយសម្រាប់ដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងកិច្ចដំណើរការនីតិវិធីនេះគឺនៅថ្ងៃទី១៣ ខែមេសា ឆ្នាំ២០១៧។

[237] អង្គជំនុំជម្រះពុំមានយោបល់ចំពោះថាតើ សហចៅក្រមស៊ើបអង្កេតបានផ្តល់ព័ត៌មានបានត្រឹមត្រូវ និងទាន់ពេលវេលា ឬយ៉ាងណាទេ ទាក់ទិននឹងសំណុំរឿង ០០៣ (មាស មុត) និង សំណុំរឿង ០០៤ (យឹម ទិត្យ)។ កាលៈទេសៈជាក់ស្តែងនៃសំណុំរឿងទាំងនោះ និងកម្រិតនៃសិទ្ធិរបស់ជនរងគ្រោះ និងសិទ្ធិរបស់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីត្រូវរងផលប៉ះពាល់នៅក្នុងសំណុំរឿងទាំងនោះ នឹងត្រូវយកមកពិនិត្យនៅក្នុងបរិបទនៃកិច្ចដំណើរការនីតិវិធីទាំងនោះ។

[238] ចាប់ពីសេចក្តីប្រកាសព័ត៌មានខែសីហា ឆ្នាំ២០១១ មក ជនរងគ្រោះស្របច្បាប់បានដឹងអំពីទីតាំងឧក្រិដ្ឋកម្ម និងព្រឹត្តិការណ៍នៃបទឧក្រិដ្ឋស្ទើរតែទាំងអស់ដែលស្ថិតក្នុងការស៊ើបអង្កេត នៅភូមិភាគកណ្តាល ហើយមានរយៈពេលប្រាំឆ្នាំ ក្នុងការរៀបចំ និងបន្ថែមព័ត៌មានចំពោះពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ខ្លួន។ ទាក់ទិននឹងការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ និងការចោទប្រកាន់ពីការរំលោភផ្លូវភេទវិញ សេចក្តីថ្លែងការណ៍របស់សហព្រះរាជអាជ្ញាអំពីការចោទប្រកាន់ដែលកំពុងពិភាក្សា ព្រមទាំងសេចក្តីថ្លែងការណ៍ជាសាធារណៈរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិអមជាមួយការចោទប្រកាន់លើកទីពីររបស់គាត់ប្រឆាំងនឹង អោ អាន នឹងឆ្ពោះទៅកាត់បន្ថយព្យសនកម្មនានាដែលកើតឡើងនៅកម្រិតនៃការអនុវត្តន៍។ *សូមមើល* សេចក្តីប្រកាសព័ត៌មានរបស់ អ.វ.ត.ក "សេចក្តីថ្លែងការណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ Nicholas Koumjian ស្តីពីសំណុំរឿង

112. សហមេធាវីមិនបានផ្ដល់ឧទាហរណ៍ជាក់លាក់ របស់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី (ឬបុគ្គលដែលអាចក្លាយជាអ្នកដាក់ពាក្យសុំ) ដែលបានទទួលរងព្យសនកម្ម ដោយសារការដាក់បង្ហាញព័ត៌មានមិនបានទាន់ពេលវេលារបស់សហចៅក្រមស៊ើបអង្កេតប្រឆាំងនឹង អោ អាន ទេ។ ពុំមានករណីជាក់ស្ដែងត្រូវបានដាក់ជូនអង្គបុរេជំនុំជម្រះពិនិត្យទេ ឧទាហរណ៍ ការចោទប្រកាន់ពីការពន្យារពេលដែលបណ្ដាលឱ្យអ្នកដាក់ពាក្យសុំដែលមានផលប្រយោជន៍ យឺតយ៉ាវក្នុងការដាក់ជូននូវព័ត៌មានពាក់ព័ន្ធដល់ពាក្យសុំរបស់ខ្លួន ឬថា ជនរងគ្រោះស្រប ច្បាប់ប្រាកដជាបានដាក់ពាក្យសុំ តាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ប្រសិនបើសហចៅក្រម ស៊ើបអង្កេតបានផ្សព្វផ្សាយព័ត៌មានបានទាន់ពេលវេលានោះ។ នៅក្នុងកាលៈទេសៈទាំងនេះ អង្គជំនុំជម្រះយល់ឃើញថា ទឡ្ហីករណ៍របស់សហមេធាវីគឺជាការលើកឡើងស្មានៗប៉ុណ្ណោះ។

113. ចុងក្រោយ អង្គជំនុំជម្រះកត់សម្គាល់ថា សហមេធាវីបានស្នើសុំឱ្យអង្គបុរេជំនុំជម្រះលើកយក ការចោទប្រកាន់ពីការរំលោភបំពានទៅលើវិធាន ២១(១)(គ) នៃវិធានផ្ទៃក្នុង "ទៅពិចារណា" នៅពេលពិនិត្យទៅលើពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីដែលត្រូវបានបដិសេធ[239]។ ចំពោះ វិសាលភាពដែលសហមេធាវីជំទាស់ថា អង្គបុរេជំនុំជម្រះមិនគួរយកចិត្តទុកដាក់ ឬបន្ធូរបន្ថយជាក់ស្ដែងនូវលក្ខខណ្ឌតម្រូវដោយនីតិវិធី ឬច្បាប់ជាធរមានចំពោះការពិចារណាលើភាព អាចទទួលយកជាដើមបណ្ដឹងរដ្ឋប្បវេណីនោះ អង្គជំនុំជម្រះសូមបដិសេធនូវការលើកឡើងនេះ។ ដូចគ្នាដែរ អង្គបុរេជំនុំជម្រះសូមកត់សម្គាល់ចំពោះសំណើលើកទីបីរបស់សហមេធាវី ដែល ស្នើសុំឱ្យអង្គជំនុំជម្រះ "ទទួលយកព័ត៌មានបន្ថែម ដែលត្រូវបានដាក់ជូនដោយសហមេធាវីតំណាង ដើមបណ្ដឹងរដ្ឋប្បវេណី"[240]។ ទាក់ទិននឹងការរំលោភបំពានខាងលើ អង្គជំនុំជម្រះបាន ត្រៀមខ្លួនដើម្បីពិចារណាទៅលើព័ត៌មានបន្ថែម ដែលបានដាក់ជូនដោយអ្នកដាក់ពាក្យសុំតាំងខ្លួនជា ដើមបណ្ដឹងរដ្ឋប្បវេណី ដើម្បីគាំទ្រពាក្យសុំរបស់ខ្លួនដែលបានរកឃើញថាជាលទ្ធផលផ្ទាល់នៃការ

---

០០៤" ថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១៤ អាចរកមើលបាននៅលើគេហទំព័រ៖ https://www.eccc.gov.kh/en/node/30196។ សេចក្ដីប្រកាសព័ត៌មានរបស់ អ.វ.ត.ក "សេចក្ដីថ្លែងការណ៍របស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិទាក់ទងនឹងសំណុំរឿង ០០៤" ថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១៦ អាចរកមើលបាននៅលើគេហទំព័រ៖ https://www.eccc.gov.kh/en/document/public-affair/additional-charges-announced-against-ao។

239 *សូមមើល* បណ្ដឹងឧទ្ធរណ៍របស់ដើមបណ្ដឹងរដ្ឋប្បវេណី (D362/5) កថាខណ្ឌ ៥៧។

240 *សូមមើល* បណ្ដឹងឧទ្ធរណ៍របស់ដើមបណ្ដឹងរដ្ឋប្បវេណី (D362/5) កថាខណ្ឌ ៥៩(៣)។

ខកខានរបស់សហចៅក្រមស៊ើបអង្កេត ក្នុងការផ្តល់ជូនព័ត៌មានដល់ជនរងគ្រោះឱ្យបានទាន់ពេលវេលា។ ទោះជាយ៉ាងណាក្តី សហមេធាវីមិនបានបង្ហាញនូវព័ត៌មានបន្ថែមនេះទេ ហើយដូចគ្នានេះដែរ អង្គជំនុំជម្រះមិនបានរកឃើញសម្ភារៈភស្តុតាងបែបនេះនៅក្នុងការពិនិត្យទៅលើពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី នៅក្រោមមូលដ្ឋានមុនៗនៃបណ្តឹងឧទ្ធរណ៍នេះដែរ។ អនុលោមទៅតាមកាលៈទេសៈទាំងនេះ អង្គជំនុំជម្រះត្រូវសម្រេចបដិសេធសំណើសុំដំណោះស្រាយនេះ។

## សេចក្តីសន្និដ្ឋាន

114. ដីកាសម្រេចលើដើមបណ្តឹងរដ្ឋប្បវេណី (ជាតិ) របស់សហចៅក្រមស៊ើបអង្កេតជាតិ[241] មិនបានរារាំងនូវការចូលរួមនាពេលខាងមុខរបស់ដើមបណ្តឹងរដ្ឋប្បវេណីដែលត្រូវបានទទួលស្គាល់ នៅក្នុងកិច្ចដំណើរការនីតិវិធីនាពេលខាងមុខ ប្រឆាំងនឹង អោ អាន ទេ។ ការបដិសេធពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់ក្នុងសំណុំរឿង ០០៤/២ សហចៅក្រមស៊ើបអង្កេតជាតិ ពឹងផ្អែកទៅលើសំអាងហេតុផ្តាច់មុខរបស់គាត់តែម្នាក់ឯង ចំពោះការសម្រេចលើកលែងបទចោទទាំងអស់ប្រឆាំងនឹង អោ អាន តែប៉ុណ្ណោះ[242]។ កំប៉ុន្តែ ចៅក្រមអន្តរជាតិសូមរម្លឹកថា ដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតជាតិ (ដីកាសម្រេចលើកលែងចោទប្រកាន់) គឺជាការសម្រេចហួសពីសមត្ថកិច្ច ត្រូវទុកជាមោឃៈ និងពុំមានអានុភាពតាមច្បាប់ទេ[243] និងរម្លឹកបន្ថែមថា ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) តម្កល់ទុកជាបានការ និងត្រូវបានបញ្ជូនតាមផ្លូវច្បាប់ទៅអង្គជំនុំជម្រះសាលាដំបូង ទៅតាមខ្លឹមសារនៃវិធាន ៧៧(១៣)(ខ) នៃវិធានផ្ទៃក្នុង[244]។

115. សុពលភាពនៃដីកាសម្រេចលើដើមបណ្តឹងរដ្ឋប្បវេណី (ជាតិ) ដែលសំអាងយ៉ាងច្បាស់ទៅលើដីកា

---

[241] ដីកាសម្រេចលើដើមបណ្តឹងរដ្ឋប្បវេណី (ជាតិ) (D361) កថាខណ្ឌ ៥៩។

[242] ដីកាសម្រេចលើដើមបណ្តឹងរដ្ឋប្បវេណី (ជាតិ) (D361) កថាខណ្ឌ ១៣ ("នៅថ្ងៃនេះ យើងបានលើកលែងការចោទប្រកាន់ទាំងអស់នៅក្នុងសំណុំរឿង ០០៤/២ ពីព្រោះថា អោ អាន ដែលជាជនត្រូវចោទតែម្នាក់គត់នៅក្នុងសំណុំរឿងនេះ មិនស្ថិតនៅក្នុងយុត្តាធិការរបស់ អ.វ.ត.ក ឡើយ")។

[243] សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (D359/24 និង D360/33) កថាខណ្ឌ ៣២៦, ៦៨៣។

[244] សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (D359/24 និង D360/33) កថាខណ្ឌ ៦៨៥-៦៨៧។

ដំណោះស្រាយ (ដីកាសម្រេចលើកលែងចោទប្រកាន់) ជាចំណាងផ្សារភ្ជាប់ទៅនឹងសុពលភាពតាមផ្លូវច្បាប់នៃដីកាដំណោះស្រាយ (ដីកាសម្រេចលើកលែងចោទប្រកាន់) តែម្តង។ ដោយហេតុថា ការចេញដីកាដំណោះស្រាយ (ដីកាសម្រេចលើកលែងចោទប្រកាន់) របស់សហចៅក្រមស៊ើបអង្កេតជាតិ ពុំមានមូលដ្ឋានតាមផ្លូវច្បាប់ នៅក្នុងក្របខណ្ឌជាមូលដ្ឋានរបស់ អ.វ.ត.ក ហើយដីកានេះត្រូវទុកជាមោឃៈតាំងពីដំបូងមក[245] នោះ ចៅក្រមអន្តរជាតិយល់ឃើញថា ដីកាសម្រេចលើដើមបណ្តឹងរដ្ឋប្បវេណី (ជាតិ) ក៏ត្រូវទុកជាមោឃៈដែរ ហើយមិនអាចចាត់ទុកថាមានអានុភាពតាមច្បាប់បានទេ។ ហេតុនេះ ដីកាសម្រេចលើដើមបណ្តឹងរដ្ឋប្បវេណី (អន្តរជាតិ) គឺជាដីកាតែមួយគត់ដែលមានសុពលភាព សម្រេចទៅលើការទទួលស្គាល់ជាដើមបណ្តឹងរដ្ឋប្បវេណី ក្នុងសំណុំរឿង ០០៤/២។

116. ពាក់ព័ន្ធនឹងសំណើរបស់ដើមបណ្តឹងរដ្ឋប្បវេណី នៅក្នុងសេចក្តីសន្និដ្ឋាននៃបណ្តឹងឧទ្ធរណ៍របស់ខ្លួនវិញ[246] ចៅក្រមអន្តរជាតិសូមរម្លឹកថា "លើកលែង និងលុះត្រាតែពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានបដិសេធចោល អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី អាចអនុវត្តសិទ្ធិជាដើមបណ្តឹងរដ្ឋប្បវេណីបាន"[247] ហើយពិចារណាឃើញថា សំណើពាក់ព័ន្ធគ្នាទាំងនេះត្រូវបានដោះស្រាយនៅក្នុងការផ្តល់សំអាងហេតុ និងការធ្វើសេចក្តីសន្និដ្ឋាន នៃសេចក្តីពិចារណាទាំងនេះរួចហើយ។

117. ហេតុនេះ អនុលោមតាមសំអាងហេតុនានាខាងលើ ចៅក្រមអន្តរជាតិនៃអង្គបុរេជំនុំជម្រះសម្រេចថា បណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណីអាចទទួលយកបាន ហើយបដិសេធមូលដ្ឋានទី ១(ក), ១(ខ) និង ៣។ ចៅក្រមអន្តរជាតិសូមតម្កល់មួយផ្នែក និងបដិសេធមួយផ្នែកនូវមូលដ្ឋានទី ២, ៤ និង ៥។ ចៅក្រមអន្តរជាតិយល់ឃើញថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិមានកំហុសនៅក្នុងសេចក្តីសម្រេចរបស់ខ្លួនលើការទទួលស្គាល់ ក្រោមមូលដ្ឋានទី ២ ដែលថា ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីចំនួន ៧ និងឯកសារពាក់ព័ន្ធគួរត្រូវបានទទួលស្គាល់ (ដូចមានផ្តល់

---

[245] សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (D359/24 និង D360/33) កថាខណ្ឌ ៣១៥-៣២៩។

[246] បណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី (D362/5) កថាខណ្ឌ ៥៩។

[247] វិធាន ២៣*ស្ទួន*(២) នៃវិធានផ្ទៃក្នុង។

សំអាងហេតុនៅក្នុងឧបសម្ព័ន្ធ ១)[248] ហើយនៅក្នុងមូលដ្ឋានទី ៤ ផងដែរ ដែលថា ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីចំនួន ៨ គួរត្រូវបានទទួលស្គាល់ (ដូចមានផ្តល់សំអាងហេតុនៅក្នុងឧបសម្ព័ន្ធ ២)[249]។ អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីចំនួន ១២ នាក់ខាងក្រោមនេះគួរត្រូវបានទទួលស្គាល់ ជាដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង ០០៤/២ រួមមាន៖ 13-VSS-00316, 12-VSS-00518, 11-VSS-00059, 12-VSS-00672, 13-VSS-00697, 16-VSS-00020, 11-VSS-00032; 16-VSS-00048; 15-VSS-00038; 16-VSS-00042; 16-VSS-00015 និង 11-VSS-00058[250]។

## វិធាន ៧៧(១៣)(ក) នៃវិធានផ្ទៃក្នុង

118. វិធាន ៧៧(១៣)(ក) នៃវិធានផ្ទៃក្នុងចែងថា ប្រសិនបើសម្លេងភាគច្រើនដែលតម្រូវមិនអាចរកបានទេ សេចក្តីសម្រេចដែលមិនមានសម្លេងគាំទ្ររបស់អង្គជំនុំជម្រះ ពាក់ព័ន្ធនឹងបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ត្រូវតម្កល់ទុកជាបានការ។ ហេតុនេះ ចៅក្រមអន្តរជាតិសន្និដ្ឋានថា ដីកាសម្រេចលើភាពអាចទទួលស្គាល់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ត្រូវតម្កល់ទុកជាបានការ[251]។ ហេតុនេះ ចៅក្រមអន្តរជាតិសម្រេចថា ដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់ដែលសហចៅក្រមស៊ើបអង្កេតអន្តរជាតិបានសម្រេចទទួលស្គាល់ មានសិទ្ធិចូលរួមក្នុងកិច្ចដំណើរការនីតិវិធីនាពេលខាងមុខ ប្រឆាំងនឹង អោ អាន[252]។

---

[248] *សូមមើល* មូលដ្ឋានទី ២ *ខាងលើ* ទាក់ទិននឹងអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីដែលមានរហស្សនាម 13-VSS-00316, 12-VSS-00518, 11-VSS-00059, 12-VSS-00672, 13-VSS-00697, 16-VSS-00020 និង 11-VSS-00032។

[249] សូមមើល មូលដ្ឋានទី ៤ *ខាងលើ* ទាក់ទិននឹងអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីដែលមានរហស្សនាម 16-VSS-00048; 15-VSS-00038; 16-VSS-00042; 16-VSS-00015; 16-VSS-00020; 11-VSS-00032; 11-VSS-00058 និង 12-VSS-00672។

[250] អង្គជំនុំជម្រះរម្លឹកថា អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី (12-VSS-00672, 16-VSS-00020, 11-VSS-00032) ដែលគួរត្រូវបានទទួលស្គាល់ដោយសហចៅក្រមស៊ើបអង្កេត ត្រូវបានដាក់នៅក្រោមមូលដ្ឋានទី ២ និងទី ៤ នៃបណ្តឹងឧទ្ធរណ៍ ហើយត្រូវបានទទួលយកជាបន្តបន្ទាប់នៅក្នុងមូលដ្ឋាននីមួយៗ។

[251] ដីកាសម្រេចលើដើមបណ្តឹងរដ្ឋប្បវេណី (អន្តរជាតិ) (D362)។

[252] ដីកាសម្រេចលើដើមបណ្តឹងរដ្ឋប្បវេណី (អន្តរជាតិ) (D362)។

**រាជធានីភ្នំពេញ ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២០**

**Olivier BEAUVALLET** **Kang Jin BAIK**